ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Nov-2011, 11:02
CMS/CFO: Kauv Keoratanak

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# បើកសេចក្តីសន្និដ្ឋានចោទប្រកាន់

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១**

**ម៉ោង ០៩: ០១នាទី**

**សវនាការលើកទី២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក យ៉េត ចរិយា

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក ហ្សាក់ វែកហ្សេស

*(Mr. Jacques VERGES)*

លោក អាកទួរ វែកកែន

(Mr. Arthur VERCKEN)

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉ែន ពៅ

លោក ហុង គីមសួន

កញ្ញា បាណាបេ ណេគ្វី *(Ms.Barnabé NEKUIE)*

លោក ប៉ាទ្រីក បូឌូន *(Mr. Patrick BAUDOIN)*

លោកស្រី ម៉ារី ហ្គីរ៉ូដ *(Ms. Marie GUIRAUD)*

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SARKARATI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| អាង ឧត្តម | ខ្មែរ |
| គង់ សំអុន | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឌុច ផារី | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០១:១៥]

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេប។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអធ្យាស្រ័យ លោកប្រធាន លោក លោកស្រីចៅក្រម។ ពីម្សិលមិញគឺថាសូមលើកពីម្សិលមិញម្តងហើយ ថ្ងៃនេះម្តងទៀត ដែលថាកូនក្តីរបស់ខ្ញុំមានការព្រួយបារម្ភដែលថា រំលោភទៅដល់សិទ្ធិមនុស្ស សិទ្ធិរបស់គាត់ដោយបង្ខំគាត់ឲ្យចូលរួមនៅក្នុងសវនាការនេះ គាត់ឈឺក្បាលពេញមួយរសៀលពីម្សិលមិញ គាត់មិនអាចស្តាប់ យកចិត្តទុកដាក់ស្តាប់បាន ហើយការបង្ខំឲ្យគាត់នៅទីនេះ គឺជាការរំលោភទៅដល់សិទ្ធិរបស់គាត់ក្នុងការចូលរួមទៅដល់ដំណើរការនីតិវិធីនេះ ហើយសូមសំណូមពរថាមិនត្រូវមានការធ្វើបែបនេះតទៅទៀតទេ។ ហើយអ្វីដែលថា មិនអាចបំភ្លេចបាន គឺសិទ្ធិរបស់ជនជាប់ចោទទាំងអស់ក៏ដូចជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូច្នេះដែរ។ លោក អៀង សារី មានបំណងចូលរួម ប៉ុន្តែគាត់មិនអាចចូលរួមបាន ប្រសិនណាគាត់មិនអាចស្តាប់បានអំពីដំណើរការនីតិវិធី គាត់សូមទៅស្តាប់នៅជាន់ខាងក្រោម។

[០៩:០២:៥៨]

គាត់មានឆន្ទៈធ្វើដូច្នេះ ប៉ុន្តែគាត់ត្រូវបានបង្ខំឲ្យនៅទីនេះ ហើយគាត់បានយកកាសស្តាប់ចេញពីត្រចៀករបស់គាត់។ បើគាត់មិនស្តាប់មិនបាន ហើយបង្ខំគាត់ឲ្យធ្វើដូច្នេះ នោះជាការបង្ខំឲ្យគាត់ចូលរួមនៅក្នុងសវនាការមួយ ដែលជាសវនាការដោយបង្ខំ និងសវនាការដែលគួរឲ្យអៀនខ្មាស។ ដូច្នេះ ខ្ញុំសូមសំណូមពរដល់លោកប្រធាន ជាមួយសហការីរបស់ខ្ញុំនេះ គឺសូមឲ្យសម្រេចទៅលើបញ្ហានេះឈានដល់សេចក្តីសម្រេចមួយ ដោយថាបើធ្វើដូច្នោះវាចោទបញ្ហាដែលបន្តតទៅទៀត ដោយសារពិភពលោកកំពុងតែពិនិត្យមើលដំណើរការនីតិវិធីរបស់តុលាការនេះ។ ហើយម្សិលមិញសហព្រះរាជអាជ្ញាបានស្នើសុំ

ដែលលើកយកបញ្ហាយុត្តិធម៌នៅក្នុងរឿងរបស់ ដែកសិន។

[០៩:០៣:៥០]

ហើយខ្ញុំសូមសំណូមពរឲ្យដំណើរការនីតិវិធី ដំណើរការទៅបានរលូនមិនមានសវនាការអន្តរជាតិនៅតុលាកាអន្តរជាតិណាមួយ ដែលបង្ខំឲ្យជនជាប់ចោទត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការនោះទេ ដូចជាតុលាការនៅអតីតយូហ្គោស្លាវី រវ៉ាន់ដា តុលាការសម្រាប់ប្រទេសសៀរ៉ាឡេអូន ឡេបាណន់ ឬក៏តុលាការ អាយ.ស៊ី.ស៊ី។

យើងធ្វើការកត់សម្គាល់ ដោយសារយើងមានការព្រួយបារម្ភថា ចៅក្រមមិនបានយកចិត្តទុកដាក់ ឬក៏ពេញចិត្តចំពោះបញ្ហាជនជាប់ចោទនោះទេ។ ហេតុដូច្នេះឯងបានយើងខ្ញុំសំណើទទូចសុំទៅដល់លោកប្រធាន ដោយក្តីគោរពបំផុត ថាសូមឲ្យលោកប្រធានមេត្តាពិចារណា ឬក៏ពិចារណាឡើងវិញ នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឲ្យគាត់ចុះទៅជាន់ខាងក្រោមសម្រាកស្តាប់ដំណើរការនីតិវិធី សម្រួលឥរិយាបថរបស់គាត់ សម្រួលសុខភាពរបស់គាត់។ គាត់កំពុងតែចូលរួមនៅពេលនេះ ហើយគាត់មានបំណងចូលរួម ហើយអនុញ្ញាតគាត់ឲ្យចូលរួម ដើម្បីធានាថា ទៅដល់ការគោរពសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌របស់គាត់។ សូមអរគុណលោកប្រធាន។

[០៩:០៥:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក អាន់ទ្រូ ខេលី៖**

ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីនូវអ្វីដែលលោក ម៉ៃខល កាណាវាស បានលើកឡើង។ មេធាវីការពារក្តីរបស់ អៀង សារី បានជម្រាបជូនទុកដល់តុលាការ ខ្ញុំគិតថាការកត់សម្គាល់នេះត្រូវបានច្រានចោល។ ជំហររបស់យើងខ្ញុំ គឺយើង តុលាការមិនបានពិចារណាទៅលើរឿងនេះណ៎ា លោក កាណាវាស សូមអនុញ្ញាតឲ្យខ្ញុំបញ្ចប់សិន។

ជាសំខាន់ គឺជនជាប់ចោទត្រូវតែមានវត្តមាននៅក្នុងដំណើរការនីតិវិធី នេះគឺជាចំណុច-- ប៉ុន្តែបើសិនណាតុលាការសម្រេចអនុញ្ញាតឲ្យលោក អៀង សារី តាមដានដំណើរការនីតិវិធីនៅជាន់ខាងក្រោម លោក កាណាវាស បាននិយាយថា កូនក្តីរបស់គាត់មិនអាចផ្តល់នូវការណែនាំណាមួយដល់រូបគាត់បានទេ ប្រសិនដែរ បើសិនជាអង្គជំនុំជម្រះអនុញ្ញាតឲ្យ អៀង សារី តាមដានដំណើរការនីតិវិធី

នៅជាន់ក្រោម គឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ហេតុផលដែលយើងលើកឡើងដូច្នេះ គឺយើងខ្ញុំមិនចង់ថា នៅក្នុងដំណើរការប្តឹង-- បើមានការប្តឹងសាទុក្ខថា ខ្លួនមិនបានតាមដានដំណើរការនីតិវិធី ឬក៏យ៉ាងណានេះ។ ដូច្នេះយើងខ្ញុំយល់ស្របជាមួយនឹងលោក កាណាវាស ប្រសិនណាជាអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក អៀង សារី ទៅតាមដានដំណើរការនីតិវិធីនៅជាន់ខាងក្រោម គឺជាសេចក្តីសម្រេចរបស់តុលាការ។

[០៩:០៧:០៤]

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមកែតម្រូវបន្តិច ទីមួយ ការកត់សម្គាល់របស់យើងខ្ញុំ គឺមិនត្រូវបានច្រានចោលនោះទេ។ ទីពីរ សហព្រះរាជអាជ្ញាមិនបានដាក់សំណើណាមួយនោះទេ ប៉ុន្តែគេបានប្តឹងសំណើសុំណាមួយផ្សេងនោះទៅវិញ។ ដូច្នេះ ជំហររបស់ខាងយើងខ្ញុំ គឺខុសពីជំហររបស់សហព្រះរាជអាជ្ញា។ នៅពេលដែលយើងខ្ញុំបានដាក់ជូននូវការកត់សម្គាល់ យើងបានដាក់ដោយយោងទៅលើមូលដ្ឋាននៃសវនាការបឋម ហើយការកត់សម្គាល់នេះ ជាមួយនឹងការកត់សម្គាល់នេះយើងបាន លើកសិទ្ធិរបស់ អៀង សារី ឬក៏ជនជាប់ចោទណាមួយ ដែលគាត់ស្នើសុំមិនមានវត្តមាន។

ទីពីរ ខ្ញុំក៏អាចនិយាយផងដែរថា សហព្រះរាជអាជ្ញាបាននិយាយថា បើជនជាប់ចោទមិនមានវត្តមាននៅទីនេះ គាត់អាចចូលរួមតាមដានដំណើរការនីតិវិធីនៅជាន់ខាងក្រោម វាជាការគួរឲ្យអៀនខ្មាស។ ទីបី ទោះបីជាលោក អៀង សារី ចង់ស្តាប់នៅក្នុងបន្ទប់ឃុំឃាំងរបស់គាត់ក៏ដោយ ក៏គាត់នៅតែមានសិទ្ធិស្នើសុំធ្វើដូច្នេះបាន។ នេះជាបទដ្ឋានអន្តរជាតិ យើងខ្ញុំបាននិយាយហើយ គឺថា យើងបានលើកលែងសិទ្ធិនេះ នេះគឺជាសំណើសុំរបស់យើងខ្ញុំ។ ដូច្នេះគាត់ ព្រឹកនេះគាត់អង្គុយនៅទីនេះ ហើយសម្រាប់ខ្ញុំ គឺថាវាជាបញ្ហាមួយយើងបានរៀបចំត្រៀមខ្លួនចូលរួមរួចជាស្រេចហើយ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បានពិនិត្យមើលបន្ទប់នៅខាងក្រោមនេះដែរ ដើម្បីធានាថា ជនជាប់ចោទអាចនឹងចូលរួមស្តាប់នៅជាន់ខាងក្រោមនេះ។ ជនជាប់ចោទមិនអាចនឹងផ្តល់សេចក្តីណែនាំពីពេលមួយទៅពេលមួយភ្លាមៗដល់មេធាវីការពារក្តី ទោះនៅតុលាការទីក្រុងហេក(Hague) ឬទីណាក៏ដោយ។ ការណែនាំពីជនជាប់ចោទមកមេធាវីរបស់ខ្លួន អាចធ្វើឡើងនៅពេលសម្រាក។

[០៩:០៩:១៩]

បើគាត់មិនអាចចូលរួមបានទេ ដូចជាពីម្សិលមិញគាត់បាននិយាយថា ក្រោយពីរយៈពេលមួយ

ម៉ោងហើយកន្លះរួចមក គាត់បានមើលឃើញនូវអ្វីដែលសហព្រះរាជអាជ្ញាបាននិយាយ ក៏ប៉ុន្តែគាត់មិនយល់អ្វីដែលសហព្រះរាជអាជ្ញានិយាយ ដោយសារថាតែគាត់មិនអាចផ្តោតការយកចិត្តទុកដាក់តាមដានដំណើរការនីតិវិធីបានទេ។ ដើម្បីជម្រះនូវបញ្ហានេះ ហើយដើម្បីបង្ហាញនូវសេចក្តីអាណិតអាសូរដល់គាត់នោះ ដោយសារសហព្រះរាជអាជ្ញាបាននិយាយថា មិនត្រូវបង្ហាញនូវសេចក្តីអាណិតអាសូរណាមួយនោះទេ។ ខ្ញុំ គឺថាធ្វើការវាយតម្លៃតែទៅលើការពិតតែប៉ុណ្ណោះ ដែលតុលាការដទៃទៀតបានធ្វើឡើងនៅទូទាំងពិភពលោក ហើយដូច្នេះហើយបានជាខ្ញុំស្នើសុំដូច្នេះ។ ប៉ុន្តែបើជនជាប់ចោទមិនអាចមានវត្តមាន គាត់មានវត្តមាន តែខួរក្បាលរបស់គាត់មិនដំណើរការទេ នេះគឺជាការពិតហើយ។ ហេតុដូច្នេះឯងបានជាជនជាប់ចោទម្នាក់ គឺថាមិនមានវត្តមាននៅទីនេះទេក្នុងព្រឹកនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំៈ**

សូមអញ្ជើញ!

ម៉េចទៅ ម្តងពេលដែលគេនិយាយ ហើយពេលដល់ពេលនិយាយទៅ វាត្រូវលោក កាណាវាសនិយាយម្តងទៀត បានន័យថាឆ្លើយឆ្លងជាមួយលោកម្តងទៀត។ វាគួរតែត្រូវបានលោកមេធាវីហ្នឹងនិយាយ ស្នើនិយាយបន្ទាប់ពីសហព្រះរាជអាជ្ញា ដើម្បីជាសរុបមេធាវីការពារក្តីអាចធ្វើការកត់សម្គាល់ចុងក្រោយបង្អស់។

[០៩:១០:៥២]

ប្រសិនបើលោកស្នើសុំ ដូច្នេះបានន័យថាមេធាវីការពារក្តី គាត់មានឱកាស និងសិទ្ធិរបស់គាត់ហ្នឹងត្រូវកត់សម្គាល់ម្តងទៀត។ ហើយប្រសិនបើធ្វើរបៀបនេះច្រើនលើកច្រើនសានៅក្នុងអំឡុងពេលសវនាការសំណុំរឿងក្តីនេះ អាចត្រូវចំណាយពេលរបៀបនេះដោយឥតបានការ គិតទៅរាប់ខែ អាចពន្យារពេលរាប់ខែ ដោយសារមូលហេតុនៃកិច្ចដំណើរការនីតិវិធីនេះមិនប្រាកដប្រជា។

ដូច្នេះចាប់ពីពេលក្រោយទៅ ប្រសិនបើលោកមានបំណងក្នុងការនិយាយ គឺលោកព្យាយាមធ្វើម៉េចខិតខំប្រឹងប្រែងបន្ទាប់ពីសហព្រះរាជអាជ្ញា គឺលោកមានឱកាសក្នុងការលើក ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត គឺប្រធានបទដែលត្រូវអនុញ្ញាត អង្គជំនុំជម្រះអនុញ្ញាតដើម្បីឲ្យកាត់បន្ថយពេលវេលាទុកលទ្ធភាពឲ្យសហមេធាវីការពារក្តីគេសរុបតែម្តង។

សូមអញ្ជើញ!

[០៩:១១:៤៤]

**លោក ពេជ អង្គុះ**

បាទ សូមគោរពលោក។ ដោយសារថាខ្ញុំមានបំណងនៅក្នុងការលើកយោបល់ ហើយលោក-- បន្ទាប់ពីពេលលោកសហព្រះរាជអាជ្ញាគាត់បានលើកដែរ ប៉ុន្តែភ្លាមបន្ទាប់ពីលោកសហព្រះរាជអាជ្ញាបានចាប់ផ្ដើម គឺលោក កាណាវាស បានងើបឈរដើម្បីមានយោបល់។ ដូច្នេះ ខ្ញុំគ្មានឱកាសនៅក្នុងការបង្ហាញថា មានចេតនានៅក្នុងការលើកអំពីយោបល់របស់ខ្លួន។ ដូច្នេះខ្ញុំបាទគ្មានបំណងថានឹងពន្យារពេលទៅដល់ដំណើរការរបស់តុលាការទេ។

[០៩:១២:១៦]

ខ្ញុំគ្រាន់តែចង់ជម្រាបអំពីចេតនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីបន្តិច គឺថាសំខាន់ណាស់ដែលថាលោក អៀង សារី មានវត្តមាននៅពេលនេះ។ ដោយសារថា រយៈពេល៣០ឆ្នាំហើយ ដែលដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះរង់ចាំឲ្យមានសវនាការនេះកើតឡើង។ ហើយដែលមានអ្នកខ្លះរហូតដល់ពេលនេះ គាត់ដេកឃំ ដែលថាមានសវនាការនេះកើតឡើង។ ហើយប្រសិនបើ-- សម្រាប់ពួកគាត់វត្តមានរបស់លោក អៀង សារី នៅកន្លែងនេះដើម្បីស្ដាប់នូវការចោទប្រកាន់ ការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺមានតម្លៃណាស់សម្រាប់ពួកគាត់ ដែលបញ្ជាក់ថា លោក អៀង សារី មានចេតនានៅក្នុងការចូលរួមនៅក្នុងការស្វែងរកយុត្តិធម៌ផងដែរ។

[០៩:១២:៥៥]

ដូច្នេះហើយដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំថា គួរតែលោក អៀង សារី មានវត្តមាននៅទីនេះ ហើយបង្ហាញពីការខំប្រឹងរបស់ខ្លួន ដើម្បីចូលរួមនៅក្នុងការស្ដាប់ ការលើកអំពីការចោទប្រកាន់ដោយត្រួសៗពីព្រះរាជអាជ្ញានេះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៤:០៦]

**ប្រធានអង្គជំនុំ៖**

បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ ដែលធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ដោយសុំមិនចូលរួមដោយផ្ទាល់នៅបន្ទប់សវនាការនេះ។ ដោយសូមដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅបន្ទប់ខាងក្រោមតាមរយៈប្រព័ន្ធសោតទស្សន៍។

បានស្តាប់សម្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញា បានស្តាប់សម្តីកត់សម្គាល់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះយល់ឃើញថា បញ្ហាដំណើរការសវនាការនាពេលនេះ គឺជាការធ្វើសេចក្តីសន្និដ្ឋានសង្ខេបអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងដើម្បីបង្ហាញដល់ភាគី និងសាធារណជនទាំងអស់ ឲ្យបានដឹងកាន់តែច្បាស់ថាជនជាប់ចោទពិតជាបានស្តាប់ និងបានដឹងនូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួនគាត់។

ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំរបស់ជនជាប់ចោទ តម្រូវឲ្យជនជាប់ចោទនៅក្នុងបន្ទប់សវនាការនេះ ដើម្បីតាមសវនាការជាបន្ត។

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:១៥:៤០]

**លោក អាន់ឌ្រូ ខេលី៖**

សូមគោរពតុលាការ ខ្ញុំសូមធ្វើការកត់សម្គាល់ទៅលើពេលវេលាដែលយើងបានប្រើប្រាស់ពីថ្ងៃនេះ គឺ៤៥នាទីម្នាក់ទាក់ទងទៅនឹងបញ្ហាដំណើរការនីតិវិធី។ ដូច្នេះ ខ្ញុំសូមឲ្យធ្វើការពិចារណាទៅលើពេលវេលាសម្រាប់ព្រឹកនេះ។ បន្ទាប់ខ្ញុំសូមចូលទៅដល់ការបង្ហាញជូននូវដីកាសម្រេចក្នុងខែមិថុនា ដែលត្រូវលើកឡើងនៅក្នុងសេចក្តីបើកការចោទប្រកាន់នេះ ហើយខ្ញុំសូមនិយាយអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ឬរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ។

[០៩:១៦:២៩]

បើសិនណាអាចបង្ហាញទៅលើតារាងខាងលើនេះបាន ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមមេត្តាពិនិត្យមើលឃើញថា មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការត្រួតត្រាទៅលើអង្គភាពចំនួនបី៖ ទី១) អង្គការភូមិភាគ ទី២) អង្គភាពយោធាដែលបានបង្កើតទៅជាកងទ័ពបដិវត្តន៍កម្ពុជា និងទី៣) ក្រសួងនានាដែលត្រូវរាយការណ៍ទៅជូនគណៈមជ្ឈិម។

[០៩:១៧:០៨]

ពីដើមឡើយអង្គការកម្ពុជាប្រជាធិបតេយ្យ បានបែងចែកទៅជាប្រាំពីរភូមិភាគ និងតំបន់ស្វយ័តពីរ ដែលភូមិភាគ និងតំបន់នីមួយៗបានរាយការណ៍ដោយផ្ទាល់ជូនគណៈអចិន្ត្រៃយ៍។ ហើយដូចខ្ញុំបាទបង្ហាញជូននៅក្នុងផែនទីនេះ គឺភូមិភាគទាំងប្រាំពីរមាន ភូមិភាគពាយ័ព្យ ភូមិភាគបស្ចិម ភូមិភាគនិរតី ភូមិភាគបូព៌ា ភូមិភាគឦសាន ភូមិកណ្តាល ឧត្តរ ព្រមទាំងតំបន់ស្វយ័តគឺមណ្ឌលគិរី ហៅថាតំបន់១០៥

និងខេត្តក្រចេះ ហៅថាតំបន់៥០៥។

[០៩:១៧:៤៥]

ភូមិភាគកណ្ដាល និងភូមិភាគឧត្តរពីមុនជាភូមិភាគតែមួយ ប៉ុន្តែនៅពាក់កណ្ដាលឆ្នាំ៧៧ ខេត្តព្រះវិហារ និងសៀមរាប ហៅតំបន់១០៣ និងតំបន់១០៦ ក្លាយជាភូមិភាគឧត្តរថ្មី។ ចំណែកឯខេត្តកំពង់ធំ និងពាក់កណ្ដាលភាគខាងលិចនៃខេត្តកំពង់ចាម បានក្លាយជាភូមិភាគកណ្ដាល។

ភូមិភាគនីមួយៗបែងចែកទៅជាតំបន់ ហើយតំបន់នីមួយៗ បែងចែកទៅជាស្រុក ស្រុកបែងចែកជាឃុំ ឬក៏ទៅជាភូមិ។ ដូចបានបង្ហាញនៅក្នុងតារាងអង្គការលេខនេះ អង្គភាពទាំងនេះបង្កើតបានទៅជាអង្គការចាត់តាំងទៅតាមឋានានុក្រម ដែលត្រូវរាយការណ៍ទៅអង្គការថ្នាក់លើ ហើយបទបញ្ជានិងគោលនយោបាយត្រូវបញ្ជូនពីថ្នាក់លើឲ្យទៅកម្មាភិបាលនៅមូលដ្ឋាន។

[០៩:១៨:៤២]

ភូមិភាគ តំបន់ ស្រុក និងឃុំនីមួយៗ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការបក្សដែលមានសមាសភាពបីនាក់ គឺលេខាមួយរូប អនុលេខាមួយរូប និងសមាជិក។ ប្រធានភូមិភាគពីរ គឺតាម៉ុក លេខាភូមិភាគនិរតី និង សោ ភឹម លេខាភូមិភាគបូព៌ា គឺជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ហើយភូមិភាគ ឬតំបន់នីមួយៗយ៉ាងហោចណាស់ក៏មានតំណាងពីររូបនៅក្នុងគណៈមជ្ឈិមដែរ។ ដូចដែលលោក លោកស្រីចៅក្រមនឹងបានស្ដាប់ពីអ្នកយាម និងអ្នកបើកបរដែលបានធ្វើការនៅមន្ទីរដឹកនាំបក្ស ក-១ និង ក-៣ ជននេះត្រូវបានជួបប្រជុំនៅភ្នំពេញជាមួយនឹងភូមិភាគ និងប្រធានតំបន់ដើម្បីជួបជាមួយកម្មាភិបាល។ រៀងរាល់ឆ្នាំថ្នាក់ដឹកនាំស្រុកត្រូវបានតម្រូវឲ្យមកភ្នំពេញ ដើម្បីទទួលការបណ្ដុះបណ្ដាលនយោបាយរយៈពេលមួយខែដែលឧទ្ទេសនាមដោយ នួន ជា និង ខៀវ សំផន។

[០៩:១៩:៤៣]

ភស្តុតាងនឹងបង្ហាញឲ្យឃើញថាជនជាប់ចោទ និងមេដឹកនាំដទៃទៀតនៅភ្នំពេញត្រូវបានទទួលដំណឹងពេញលេញ អំពីការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅតាមបណ្ដាខេត្តនានា ដែលមានប្រព័ន្ធដាច់ខាតមួយ ដែលត្រូវតែអនុវត្តចេញនៅដើមឆ្នាំ១៩៧៧។ ហើយលោក លោកស្រីចៅក្រមនឹងឃើញនៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យថ្នាក់នីមួយៗនៅក្នុងឋានានុក្រមបក្សរាយការណ៍ជូនអង្គការថ្នាក់លើបន្ទាប់ អំពីសភាពការណ៍របស់អង្គភាពខ្លួន និងការអនុវត្តផែនការបក្ស។ នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី៨ មីនា ៧៦ ដែលបានស្នើឲ្យ

របាយការណ៍ប្រចាំសប្តាហ៍ពីភូមិភាគតំបន់។ ដូច្នេះ គណៈអចិន្ត្រៃយ៍បានដឹកនាំដើម្បីផ្តល់ការណែនាំឲ្យទាន់ពេលវេលា ហើយនៅក្នុងសេចក្តីសម្រេចថ្ងៃទី៣០ មីនា ៧៦ របស់គណៈអចិន្ត្រៃយ៍ដែលបានបង្កើតរបបនយោបាយប្រចាំសប្តាហ៍មកមន្ទីរ៨៧០។

អង្គជំនុំជម្រះនឹងបានស្តាប់ឮពីអ្នកបញ្ជូនសារទូរលេខដែលធ្វើការនៅមន្ទីរភូមិភាគ ឬតំបន់ ដែលបានរៀបរាប់អំពីការបញ្ជូនសារប្រចាំថ្ងៃនៅថ្នាក់ដឹកនាំនៅភ្នំពេញ និងការទទួលចម្លើយតបមកវិញ។ សាក្សីនានាមកពីមន្ទីរតំបន់១០៥ នឹងផ្តល់សក្ខីកម្មថា សារទូរលេខទាក់ទងនឹងសភាពការណ៍ខ្លាំងត្រូវបញ្ជូនទៅ នួន ជា និងអតីតលេខាតំបន់ និងបញ្ជាក់អះអាងថា សារទូរលេខាដែលគាត់បានបញ្ជូនតែងតែបានទទួលការឆ្លើយតបពី ប៉ុល ពត ឬ នួន ជា។

[០៩:២១:៣១]

លោក លោកស្រីចៅក្រម ក៏នឹងបានស្តាប់ចម្លើយពីកម្មាភិបាលម្នាក់ដែលទទួលខុសត្រូវនៅមន្ទីរនៅភ្នំពេញ ដែលបានទទួលសារទូរលេខ បន្ទាប់មកបកប្រែ រួចបញ្ជូនទៅមេដឹកនាំនៅមន្ទីរក-១។ គាត់នឹងពន្យល់ ថាតើសារទូរលេខនោះ ត្រូវចែកចាយទៅប្រធានមន្ទីរក-១ នេះ ដោយរបៀបណា? ដោយយោងទៅលើការណែនាំទទួលបានពីមេដឹកនាំបក្ស។ ឧទាហរណ៍ នៅចំពោះមុខ លោក លោកស្រីចៅក្រម ផ្ទុះបញ្ចាំងពីការបែងចែកជូននូវសារទូរលេខជាស្តង់ដារដែលរួមមានសមាជិកមជ្ឈិមនីមួយៗដែលស្នាក់នៅភ្នំពេញ គឺប៉ុល ពត ដែលហៅថា អ៊ំ, នួន ជា ជាទូទៅហៅថា អ៊ំនួន, អៀង សារី ហៅក្រៅថា វ៉ាន់, សុន សេន ហៅក្រៅថា ខៀវ និង វន វេត ឬហៅថា បងវន។ តាមការអនុវត្តទូទៅរបស់ពួកគេ អត្ថបទថតចម្លងនៃសារទូរលេខទាំងនេះ ត្រូវផ្ញើជូនជាប្រចាំទៅមន្ទីរ និងកន្លែងតម្កល់ឯកសារ។ សាក្សីដដែលនេះ នឹងពន្យល់ឲ្យដឹងផងដែរ ថាតើឯកសារពីមន្ទីរនេះ ក៏បានបញ្ជូនទៅ ខៀវ សំផន នៅមន្ទីរ ៨៧០ ចំណែកឯអត្ថបទថតចម្លងសម្រាប់តម្កល់ឯកសារ ឬនៅបណ្ណសារត្រូវបានរក្សាទុកនៅមន្ទីរសារទូរលេខ។ ហើយសារទូរលេខនេះ ត្រូវបញ្ជូនទៅមន្ទីរក-១ ពីរឬបីដងក្នុងមួយថ្ងៃ។

[០៩:២៣:០៤]

របាយការណ៍ដែលបានទទួលពីភូមិភាគនានា ត្រូវធ្វើតាមជាទម្រង់ជាស្តង់ដារមួយ។ ភូមិភាគនេះត្រូវរាយការណ៍ជាពិសេសអំពីសភាពការណ៍ខ្លាំងទាំងផ្ទៃក្នុង និងផ្ទៃក្រៅ។ ផ្នែកក្រៅពីនេះ ត្រូវរាយការណ៍អំពីបញ្ហានៅតាមព្រំដែនសៀម ព្រំដែនយួន និងឧបទ្ទវហេតុនៃជម្លោះប្រដាប់អាវុធ។ ផ្នែកនីមួយៗអំពីសត្រូវផ្ទៃក្នុងគឺរៀបរាប់អំពីបញ្ហាជាមួយនឹងកម្មាភិបាល ប្រជាជនថ្មី ឬប្រជាជនមូលដ្ឋាន ដោយស្មើ

សុំឲ្យមានការណែនាំពីមជ្ឈិមបក្សអំពីការចាត់វិធានការនានា ការចាប់ខ្លួន ការសួរចម្លើយ និងការប្រហារជីវិត។

[០៩:២៣:៤១]

សារទូរលេខថ្ងៃទី១៥ មិថុនា ១៩៧៧ មកពីលេខាភូមិភាគពាយ័ព្យបានចម្លងជូន នួន ជា, អៀង សារី និង ខៀវ សំផន តាមរយៈមន្ទីរ៨៧០ បានរៀបរាប់អំពីថាតើកងពល៨០១ បានចាប់និងឃុំខ្លួនទាហានជនជាតិចារ៉ាយមកពីប្រទេសវៀតណាមដោយរបៀបណា? និងស្នើសុំបញ្ជាក់ថាត្រូវចាត់វិធានការបែបណា បន្ទាប់អ្នកទោសទាំងនេះត្រូវបានសួរចម្លើយរួចមក? ក្នុងអំឡុងនៃការបញ្ជូនសារទូរលេខនេះ អ្នកអ្នកទោសជនជាតិចារ៉ាយមួយក្រុមធំ ត្រូវបានចាប់ខ្លួនមកពីប្រទេសវៀតណាម ត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខអូរកន្សែង ក្នុងខេត្តរតនគិរី ដោយអនុវត្តតាមបញ្ជាដែលបានបញ្ជូនមកពីមន្ទីរភូមិភាគពាយ័ព្យ ដែលលោក លោកស្រីចៅក្រម នឹងបានស្ដាប់ចម្លើយពីប្រធាន អនុប្រធានពន្ធនាគារនេះ។

សារទូរលេខចុះថ្ងៃទី១០ មករា ១៩៧៨ មកពី កង ចាប ហៅ សែ លេខាភូមិភាគឧត្តរត្រូវបានចម្លងជូន នួន ជា, អៀង សារី និងខៀវ សំផន តាមរយៈមន្ទីរ៨៧០ ដោយរាយការណ៍ថា ពួកខ្មាំងបានជ្រៀតចូលពីតំបន់ ស្រុក ឃុំ ហើយបញ្ជាក់ថា សែ មានការផែនការចុះទៅតំបន់១០៣ ដើម្បីស្រាវជ្រាវរែករកខ្មាំង។ ពីរខែក្រោយមក លេខាភូមិភាគដដែលនេះ បានរាយការណ៍ថាពួកគេបានបោសសម្អាតជាប្រព័ន្ធនូវពួកខ្មាំងដែលជាប់ទាក់ទងនឹងអតីតប៉ូលិស ទាហាន មន្ត្រីរដ្ឋការ ព្រមទាំងប្រជាជនថ្មី ហើយពួកគេមានផែនការនឹងចាប់ប្រជាជនបន្ថែមទៀត។ របាយការណ៍ទៀងទាត់បានបញ្ជូនមកភ្នំពេញក៏មានផ្នែករៀបរាប់អំពីស្ថានភាពបង្កបង្កើនផល ការលើកទំនប់ ការជីកប្រឡាយ សុខភាព-- របស់ប្រជាជននៅតាមមូលដ្ឋាន ជាពិសេសជម្រាបជូនថ្នាក់ដឹកនាំបក្សអំពីការខ្វះស្បៀងអាហារ និងការផ្ទុះជំងឺ។

[០៩:២៥:៣៤]

រចនាសម្ព័ន្ធអង្គការចាត់តាំង និងរចនាសម្ព័ន្ធរបាយការណ៍ប្រហាក់ប្រហែលគ្នានេះ គឺថាវាមានសម្រាប់កងទ័ព គឺមានកងពលកងទ័ពចំនួនប្រាំបួន និងកងវរសេនាធំឯករាជ្យមួយចំនួនទៀត ដែលបានរាយការណ៍ជូនមេដឹកនាំបក្សតាមរយៈអគ្គសេនាធិការនៅភ្នំពេញ។ កងកម្លាំងយោធាដែលស្ថិតនៅក្រោមការគ្រប់របស់មជ្ឈិមរួមមាន កងពលជើងទឹកលេខ១៦៤ ដែលមានទីតាំងនៅកំពង់សោម កងពលជើងអាកាសនៅលេខ៥០២ មានទីតាំងនៅក្នុងភ្នំពេញ និងជុំវិញភ្នំពេញ ទទួលខុសត្រូវការពារ

មេដឹកនាំបក្ស។

[០៩:២៦:១៤]

ហើយកងពលនានាដែលនៅមូលដ្ឋានមណ្ឌលគិរីគឺកងពល៩២០ និងរតនគិរីកងពល៨០១។ មេកងពលបានចូលរួមជាទៀងទាត់ជាមួយនាយអគ្គសេនាធិការ សុន សេន ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ដែលរស់នៅជាមួយជនជាប់ចោទ នៅមន្ទីរក-៣ ហើយធ្វើការជាមួយគ្នានៅមន្ទីរក-១។

កំណត់ហេតុនៃអង្គប្រជុំថ្នាក់កងពលនេះបានបង្ហាញថា តើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុវត្តដោយរបៀបណានៅក្នុងជួរកងទ័ពពាក់ព័ន្ធទៅនឹងការបោសសម្អាត និងការកម្ទេចខ្មាំងនៅក្នុងជួរ? កងពលនានាក៏ត្រូវរាយការណ៍ដូចគ្នាទៅនឹងភូមិភាគ និងបញ្ជូនរបាយការណ៍ទៀងទាត់ទៅឲ្យ សុន សេន ដោយរៀបរាប់អំពីសភាពការណ៍ខ្មាំង ស្ថានភាពបង្កបង្កើនផល និងការដ្ឋាននានា។

លោក លោកស្រីចៅក្រម នឹងបានស្តាប់ចម្លើយសកម្មពីកម្មាភិបាលដែលធ្វើទំនាក់ទំនងនៅអគ្គ-សេនាធិការដ្ឋានដែលបាននិយាយថា ព័ត៌មានទទួលបានពីកងពលនានាត្រូវបានរាយការណ៍ជូន សុន សេន។ សុន សេន រាយការណ៍ជូនថ្នាក់ដឹកនាំបក្សដទៃទៀត។ លោក លោកស្រីចៅក្រម ក៏នឹងបានឃើញឧទាហរណ៍មួយចំនួនពីកងពលដែលមានជាពិសេសគឺចំណារផ្ទាល់ដៃពី សុន សេន បញ្ជូនរបាយការណ៍ទៅអង្គការ ឬមន្ទីរ៨៧០ ដូចជាឯកសារនេះជាដើម។

[០៩:២៧:៣៧]

ក្រសួងនានាក៏បានរាយការណ៍ជាទៀងទាត់ និងដោយផ្ទាល់ជូនថ្នាក់ដឹកនាំបក្ស។ ដោយសារក្រសួងនានាមានទីតាំងនៅភ្នំពេញ របាយការណ៍របស់ពួកគេត្រូវរាយការណ៍ផ្ទាល់មាត់ជូនកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឬកិច្ចប្រជុំប្រចាំខែរបស់គណៈមន្ទីរ ដោយចូលរួមដោយ ប៉ុល ពត។

ដូច្នេះ ជនជាប់ចោទ មិនអាចអះអាងឲ្យជឿជាក់បានថា ពួកគេមិនដឹង និងមិនបានគ្រប់គ្រងទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីខែមេសា ៧៥ ដល់ មករា ៧៩ នោះទេ។ ផ្ទុយពីនេះស្រឡះការត្រួតត្រារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅលើផ្នែកទាំងអស់នៃសង្គមកម្ពុជាគឺជាការធ្វើឲ្យមានការភ័យខ្លាចទូទៅ និងទាំងស្រុង។

[០៩:២៨:២៤]

លោក លោកស្រីចៅក្រមក៏នឹងបានស្តាប់ចម្លើយដឹងឮអំពីការត្រួតត្រានេះ ដោយគ្រាន់តែអានរបាយការណ៍លម្អិត និងសារទូរលេខដែលបានផ្ញើជូនមេដឹកនាំបក្សនៅភ្នំពេញ។ ជនជាប់ចោទក៏បាន

ទទួលដំណឹងក្នុងមួយខែៗអំពីចំនួនទឹកភ្លៀង អំពីការត្អូញត្អែរពីកម្មវិធីសហករណ៍។ ហើយនិងបានរាយការណ៍ថា តើមានទឹកភ្លៀងប៉ុន្មានក្នុងមួយខែៗ និងអំពីបញ្ហារបស់ជនដែលបានត្អូញត្អែរអំពីកម្មវិធីសហករណ៍របស់បក្ស និងការខ្វះស្បៀងអាហារ។ ប្រសិនបើជនជាប់ចោទ ចង់បានផ្លែក្រូចពីខេត្តពោធិ៍សាត់នោះ គេនឹងវេចខ្ចប់ផ្លែពោធិ៍សាត់ នឹងបញ្ជូនមកឲ្យពួកគេ។ ប៉ុន្តែប្រសិនបើឪពុកម្ដាយម្នាក់បានបេះផ្លែឈើ ឬចាប់ត្រីដើម្បីឲ្យកូនដែលកំពុងតែស្រេកឃ្លាននោះទៅវិញ នោះពួកគាត់នឹងត្រូវចាប់ខ្លួនរួចហើយត្រូវបានរាយការណ៍ជូនបក្ស និងបញ្ជូនទៅធ្វើការអប់រំកែប្រែ។

[០៩:២៩:២៣]

សេចក្ដីស្លាប់អាចមានមកដល់មួយរំពេច ប៉ុន្តែមិនអាចបញ្ឈប់ទារុណកម្មនោះបានទេ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រាល់សកម្មភាពមិនស្ដាប់បង្គាប់ទាំងអស់ត្រូវបានគេយល់ឃើញថា ជាការគំរាមកំហែងមួយ និងបានចាត់ទុកថាជាខ្មាំងវិទ្ធង្សនាដែលត្រូវតែរាយការណ៍ជូនអង្គការ នឹងត្រូវដោះស្រាយតាមវិធានការសមស្រប។

លោក លោកស្រីចៅក្រម ជាទីគោរព! ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនជាព្រឹត្តិការណ៍ដោយចៃដន្យដែលបានសន្មតចំពោះកម្មាភិបាលកាចសាហាវទាំងនោះៗទេ។ ពួកគេក៏មិនអាចទម្លាក់កំហុសទៅលើ ប៉ុល ពត បានដែរ។ ដូចដែលជនជាប់ចោទខ្លះអាចត្រូវជំនុំជម្រះទោសនៅក្នុងសវនាការនេះស្រាប់។ ឧក្រិដ្ឋកម្មទាំងនេះគឺជាលទ្ធផលនៃផែនការដែលបានរៀបចំឡើងដោយជនជាប់ចោទ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានអនុវត្តជាប្រព័ន្ធនៅទូទាំងភូមិភាគ អង្គភាពយោធា និងស្ថាប័នរាជរដ្ឋាភិបាលដែលជនជាប់ចោទត្រួតត្រា។ ការពិតដែលមិនអាចប្រកែកបាននោះគឺថា មានការចូលរួមដោយស្ម័គ្រចិត្តពីមនុស្សរាប់រយរហូតដល់រាប់ពាន់ឯណោះដើម្បីឈានទៅដល់ការព្រមព្រៀងយ៉ាងពេញលេញមួយ និងការកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីដឹកនាំរបបមួយក្នុងរយៈពេលជាងបីឆ្នាំដែលបានធ្វើទោសកម្មទៅលើប្រទេសជាតិទាំងមូល និងបានប្រហារជីវិតប្រជាជនអស់ជាងមួយលាននាក់។ ការសម្លាប់រង្គាលនេះមិនអាចទទួលខុសត្រូវដោយសារតែមនុស្សម្នាក់នោះបានទេ។

[០៩:៣០:៥០]

ផ្ទុយទៅវិញ នៅក្នុងសវនាការនេះ សហព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទត្រូវបានប្រព្រឹត្តឡើងតាមរយៈផែនការឧក្រិដ្ឋកម្ម ឬសហឧក្រិដ្ឋកម្មរួម ដែល នួន ជា, អៀង សារី,

ខៀវ សំផន គឺជាអ្នកចូលរួមដោយដឹងឮ និងដោយឆន្ទៈ។

ឥឡូវនេះ ខ្ញុំនឹងលើកឡើងអំពីគោលនយោបាយឧក្រិដ្ឋកម្មនីមួយៗដោយចាប់ផ្ដើមពីការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងទៅកាន់ទីជនបទនានា។ ប្រជាជនរាប់លាននាក់ត្រូវបានបង្ខំឲ្យបោះបង់ផ្ទះសម្បែងរបស់ខ្លួននៅទីក្រុងភ្នំពេញ និងទីក្រុង និងទីរួមខេត្តដទៃទៀត។ សាលារៀន ទីវត្តអារាម និងទីផ្សារត្រូវបានបិទទ្វារ។ គិតមកត្រឹមថ្ងៃ១៦ មេសា ទោះជាអ្នកនោះធ្វើការជាអ្វីក៏ដោយ ដូចជា គ្រូបង្រៀន ជានិស្សិត ជាមេធាវី ជាវេជ្ជបណ្ឌិត ជាលោកសង្ឃ ជានគរបាល ឬជាម្ចាស់ភោជនីយដ្ឋាន គឺគិតដល់ថ្ងៃទី១៧ មេសា អាយុជីវិតរបស់ទាំងនោះ គឺជាកម្មសិទ្ធិរបស់បក្សហើយ។ អ្វីដែលបានកើតឡើងនៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ មិនមែនជាគោលនយោបាយថ្មីរបស់បក្ស ហើយគោលនយោបាយនេះ ក៏មិនមែនជាការឆ្លើយតបទៅនឹងព្រឹត្តការណ៍តាមកាលៈទេសៈជាបន្ទាន់នោះទេ។ តែផ្ទុយទៅវិញ វាគឺជាគោលនយោបាយដែលធ្វើផែនការយ៉ាងប្រុងប្រយ័ត្ន ដោយបានរៀបចំនិងអនុវត្តដោយជនជាប់ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតអស់រយៈពេលជាច្រើនឆ្នាំ នៅក្នុងបូរណភាពដែនដីដែលពួកគេត្រួតត្រា។

[០៩:៣២:៣២]

នៅក្នុងអំឡុងសង្គ្រាមចេនឡាពីរ គឺឆ្នាំ១៩៧១ ដែលបក្សបានបង្កើតកលល្បិចដំបូង ដែលពួកគេហៅថា "ការជម្លៀសប្រជាជនចេញពីទីក្រុង រួចសម្លាប់អ្នកណាម្នាក់ក្នុងចំណោមប្រជាជនទាំងនោះដែលគេគិតថាជា ខ្មាំងវណ្ណៈ"។ កលល្បិចនេះត្រូវបានអនុវត្តនៅខេត្តក្រចេះ បាណាម និងនៅក្នុងខេត្តកំពង់ចាម នៅក្នុងឆ្នាំ១៩៧៣។

នៅខេត្តកំពង់ចាម បក្សកុម្មុយនីស្តកម្ពុជាបានជម្លៀសប្រជាជន មួយម៉ឺនប្រាំពាន់នាក់ ក្រោយពីការកាន់កាប់ទីក្រុងនេះជាបណ្ដោះអាសន្ន ហើយបន្ទាប់មួយបានសម្លាប់អស់ប្រជាជនអស់មួយម៉ឺននាក់។ កលល្បិចដូចគ្នានេះត្រូវបានអនុវត្តដោយជនជាប់ចោទនៅឧដុង្គ ក្នុងឆ្នាំ១៩៧៤។ នេះគឺការរៀបរាប់ព្រឹត្តការណ៍របស់ ហ្វីលីប ស៊ិត ដែលថាក្រោយពីការរឹបអូសបានក្រុងឧដុង្គ ក្នុងខែមីនា ១៩៧៤។ ខ្ញុំសូមដកស្រង់សម្ដី "ប្រជាជនចំនួន២០០ពាន់នាក់ ត្រូវបានចាប់ខ្លួន និងបណ្ដើរទៅកាន់ព្រៃបាហាល មុនពេលឲ្យដាក់ទៅរស់នៅក្នុងសហករណ៍ក្នុងភូមិភាគពិសេសនិងភូមិភាគនិរតី។ មន្ត្រីទាហានស្លៀកពាក់ឯកសណ្ឋានត្រូវបានបំបែកចេញពីក្រុមនេះ រួចបណ្ដើរទៅសម្លាប់ចោល"។

[០៩:៣៣:៥២]

ក្នុងឋានៈជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិលោក ខៀវ សំផន គឺជាមេដឹកនាំមួយរូបនៃបក្សកុម្មុយនីស្តកម្ពុជាដែលដឹកនាំយុទ្ធសាស្ត្រនេះយ៉ាងសកម្ម។ នៅក្នុងសុន្ទរកថាដែលបានអាននៅក្នុវខាងជើង នៅខែមេសា ឆ្នាំ១៩៧៤ ដែលលោក អៀង សារី និង អៀង ធីរិទ្ធ បានចូលរួមនោះ លោកបាននិយាយអួតអាងថា បានកម្ទេចខ្មាំងជាងប្រាំម៉ឺននាក់។ ប្រហែលពីរសប្តាហ៍មុនពេលភ្នំពេញបានដួលរលំក្នុងឆ្នាំ១៩៧៥ កិច្ចប្រជុំមួយត្រូវបានធ្វើឡើងនៅទីបញ្ជាការរបស់ ប៉ុល ពត នៅក្បែរក្រុងឧដុង្គ ដែលចេញបញ្ជាចុងក្រោយ ដើម្បីជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ អ្នកយាមដែលវត្តមាននៅក្នុងទីនោះក្រោយមកបានក្លាយជាប្រធានមន្ទីរសន្តិសុខនៅក្រសួងការបរទេស និងផ្តល់សក្ខីកម្មថា នួន ជា, ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំនោះ និងបានយល់ព្រមលើផែនការជម្លៀសទីក្រុងភ្នំពេញ។

ខៀវ សំផន គាត់បានទទួលស្គាល់ថាគាត់បាននៅទីនោះជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងពេលនេះ។

[០៩:៣៤:៥៧]

លោក អៀង សារី បានស្ថិតនៅក្នុងទីក្រុងប៉េកាំងនៅពេលដែលចេញបញ្ជាចុងក្រោយទៅឲ្យយោធា។ ប៉ុន្តែគាត់ជាសមាសភាពនៅក្នុងថ្នាក់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបានកសាងយុទ្ធសាស្ត្រជម្លៀសប្រជាជនក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ជាពិសេស អៀង សារី បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជារៀបចំផែនការដើម្បីជម្លៀសទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៤ ជាមួយ ប៉ុល ពត។

[០៩:៣៥:២៤]

គោលបំណងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀតរបស់ខ្មែរនៅឆ្នាំ ១៩៧៣, ១៩៧៤, ១៩៧៥ គឺមិនមែនដើម្បីការពារប្រជាជនទេ ហើយវាក៏មិនមែនជាការឆ្លើយតបទៅនឹងបញ្ហាផ្គត់ផ្គង់ស្បៀងអាហារនោះដែរ។ វាក៏មិនមែនជាគំនិតដែលបានប្រកាសប្រាប់ប្រជាជនភ្នំពេញ ដែលថាចេញ គេត្រូវចេញ ពីព្រោះមានការគំរាមកំហែងពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនោះទេ។

ការជម្លៀសភ្នំពេញ គឺកើតចេញពីយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលថាតំបន់ទីក្រុងគឺជាសរសៃឈាមរបស់វណ្ណៈក្បត់ វណ្ណៈខ្មាំង ដែលសម្រេចថា ត្រូវដេញចេញ ហើយបំបែកចេញ និងសម្លាប់ពួកគេ។ ចេតនាឧក្រិដ្ឋដែលនៅពីក្រោយការជម្លៀសនេះ គឺផ្ទុះបញ្ចាំងនៅក្នុងសេចក្តីថ្លែងការណ៍ជាច្រើនដែលបញ្ជាក់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងជនជាប់ចោទ។

[០៩:៣៦:២៨]

ក្នុងសុន្ទរកថាខែមករា ឆ្នាំ១៩៧៧ ទៅកាន់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា នួន ជា បានរៀបរាប់ពីការជម្លៀសឆ្នាំ១៩៧៥ ថាជាយុទ្ធសាស្ត្ររបស់បក្ស គឺជាការកាត់ផ្តាច់ក្បាល និងកន្ទុយរបស់ខ្មាំង ហើយនិងដើម្បីក្តោបក្តាប់ប្រជាជន។

នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បានរៀបរាប់ពីវិធីសាស្ត្រថា មានខ្មាំងតិចតួចនៅក្នុងជនបទ ប៉ុន្តែមានខ្មាំងច្រើននៅក្នុងទីក្រុង ហើយត្រូវតែធ្វើការជម្លៀស ហើយបញ្ជូនពួកគេទៅជនបទដើម្បីកម្ទេចបណ្តាញពួកភ្នាក់ងារខ្មាំង។

លោក ខៀវ សំផន បានទទួលស្គាល់ថា ការជម្លៀសទីក្រុងភ្នំពេញ គឺជាលទ្ធផលនៃសេចក្តីសម្រេចសមូហភាពដែលគាត់បានចូលរួម ហើយគាត់បាននិយាយការពារថា សេចក្តីសម្រេចនេះបាននិយាយថា ដកស្រង់មាត់ថា ជនបទគឺជាគ្រឹះដ៏សំខាន់សម្រាប់បដិវត្តន៍ ប៉ុន្តែទីក្រុងគឺជាក្បាលម៉ាស៊ីនរបស់វណ្ណៈកាន់អំណាច និងពួកចក្រពត្តិនិយម ហើយជាទីកន្លែងដែលខ្មាំងបដិវត្តន៍អាចប្រឆាំងនឹងបដិវត្តន៍ កម្ទេចបដិវត្តន៍បាន។

[០៩:៣៧:៤០]

ទង់បដិវត្តន៍គឺជាទស្សនាវដ្តីរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលបែងចែកទៅឲ្យតែសមាជិករបស់បក្សប៉ុណ្ណោះ និយាយអំពីការរៀបចំជម្លៀសប្រជាជនចេញពីក្រុង គឺជាការតស៊ូវណ្ណៈ។ ក្នុងអំឡុងសន្និសីទនៅក្រុងប៉េកាំងនៅថ្ងៃទី៣ តុលា ឆ្នាំ១៩៧៧ ដែលមានលោក អៀង សារី ឈរនៅក្បែរ ប៉ុល ពត បាននិយាយថា “ការជម្លៀសប្រជាជនចេញពីទីក្រុងគឺដើម្បីបំបែកប្រជាជនឲ្យទៅនៅតាមជនបទសហករណ៍ ដើម្បីអាចនឹងកម្ទេចបានងាយស្រួល”។

លោក លោកស្រីបានជ្រាបពីម្សិលមិញពីលោកជំទាវ ជា លាង ទាក់ទងទៅនឹងបទឧក្រិដ្ឋដ៏សែនរន្ធត់ដែលបានកើតឡើងក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ និងថ្ងៃបន្តបន្ទាប់ដែលប្រជាជនត្រូវបានបោសសម្អាត ហើយប្រជាជនរាប់លានត្រូវបានបង្ខំឲ្យបោះបង់ចោលទីកន្លែង ផ្ទះសម្បែង ទ្រព្យសម្បត្តិរបស់ខ្លួន។

ទីតាំងឧក្រិដ្ឋកម្មជាមូលដ្ឋាននៃការចោទប្រកាន់ ជនជាប់ចោទ រួមទាំងទួលពោធិ៍ជ្រៃ កន្លែងសម្លាប់នៅពោធិ៍សាត់ ហើយនិងទីក្រុងនៅកំពង់ចាម ដែលជាកន្លែងសម្លាប់ពួកកងទ័ព លន់ នល់ ជាដើម។

**លោក គង់ សំអុន៖**

លោកប្រធាន សូមមេត្តាជម្រាបជូនលោកសហព្រះរាជអាជ្ញា យឺតៗបន្តិច ព្រោះលឿនពេកទៅ ខ្ញុំបាទតាមមិនសូវទាន់បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ សូមលោកព្រះរាជអាជ្ញាបន្ថយល្បឿនបន្តិច។

[០៩:៣៩:៣៣]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ពីចំណុច ទីតាំងឧក្រិដ្ឋកម្មដែលមូលដ្ឋាននៃការចោទប្រកាន់ជនជាប់ចោទ រួមទាំងទួលពោធិ៍ជ្រៃ ទីកន្លែងសម្លាប់នៅខេត្តពោធិ៍សាត់ ជាទីកន្លែងដែលទាហាន និងមន្ត្រីរាប់ពាន់របស់ទាហាន លន់ នល់ ត្រូវបានប្រមូលផ្តុំ និងប្រហារជីវិតក្នុងរយៈជាងពេលមួយសប្តាហ៍ និងស្រុកមួយក្នុងកំពង់ឆ្នាំងដែលជាមូលដ្ឋានបក្សកុម្មុយនីស្តកម្ពុជាជាយូរមកហើយនោះ ជាកន្លែងដែលសម្រិតសម្រាំងអ្នកជម្លៀសមកពីភ្នំពេញ និងកន្លែងផ្សេងៗទៀត និងអ្នកដែលនឹងត្រូវកំណត់អត្តសញ្ញាណថា ជាទាហាន លន់ នល់ ឬមន្ត្រី លន់ នល់ ម្ចាស់ដី អាជីវករ ខ្មាំងវណ្ណៈត្រូវបានគេយកទៅសម្លាប់ចោល។

ជនជាប់ចោទបានសម្រេច និងបញ្ជាដោយផ្ទាល់ឲ្យសម្លាប់រង្គាលមន្ត្រី និងទាហានរដ្ឋាភិបាល លន់ នល់។ សេចក្តីសម្រេចរបស់សមាជថ្នាក់ជាតិរបស់រណសិរ្សរួបរួមជាតិ ដែលចុះហត្ថលេខាដោយ ខៀវ សំផន នៅចុងខែកុម្ភៈ ឆ្នាំ៧៥ បានអំពាវនាវឲ្យមានការប្រហារជីវិតមេដឹកនាំប្រាំពីររូបរបស់របប លន់ នល់ ដែលគេហៅថា ជនមហាក្បត់។

[០៩:៤១:០៧]

ក្នុងចំណោមបុគ្គលទាំងប្រាំពីររូបនេះ មានពីរនាក់គឺនាយករដ្ឋមន្ត្រី ឡុង បូរ៉េត និងទ្រង់សិរិមតៈ បានសម្រេចមិនចាកចេញពីប្រទេសកម្ពុជា ក្នុងខណៈពេលដែលខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ។ លោក ឡុង បូរ៉េត បានប្រគល់ខ្លួនរបស់គាត់ឲ្យទៅបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទ្រង់សិរិមតៈ បានជ្រកកោននៅស្ថានទូតបារាំងក្នុងទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែដោយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាព័ទ្ធជុំវិញ និងគំរាមកំហែងវាយប្រហារស្ថានទូតបារាំង រូបគាត់ និងខ្មែររាប់រយនាក់ត្រូវបានបង្ខំឲ្យចេញពីស្ថានទូតបារាំងនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ហើយពួកគេត្រូវ

បាននាយទាហានបក្សកុម្មុយនីស្តកម្ពុជាយកទៅឃុំខ្លួន។

[០៩:៤២:០៥]

ការប្រហារជីវិតសិរិមតៈ និង ឡុង បូរ៉េត ត្រូវបានប្រកាសជូនពិភពលោកបានឮដោយ អៀង សារី នៅសន្និសីទទីក្រុងបាងកក នៅដើមឆ្នាំ១៩៧៥ ខែវិច្ឆិកា។ បទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជា នៅពីដំបូងដើមនៃរបបពួកគេ គឺគ្រាន់តែជាការចាប់ផ្ដើមតែប៉ុណ្ណោះ។

ឥឡូវនេះខ្ញុំនឹងនិយាយអំពីគោលនយោបាយទីពីរ ដែលជាផ្នែកមួយនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលជាការចោទប្រកាន់លើជនជាប់ចោទ គឺជាការបង្កើតសហករណ៍ និងការដ្ឋានដែលពលរដ្ឋកម្ពុជាត្រូវបានគេដាក់ទៅជាទាសករ។

ឥឡូវនេះខ្ញុំ-- នៅពេលដែលគេជម្លៀសប្រជាជនហើយ គេបញ្ជូនអ្នកទាំងនោះទៅសហករណ៍ជនបទ ហើយបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌដ៏អាក្រក់ និងរបបអាហារខ្វះខាត។ ដូចក្នុងករណីនៃការជម្លៀសដោយបង្ខំនោះដែរ ការបង្កើតសហករណ៍ គឺជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលចងក្រងឡើងដោយបក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥។

[០៩:៤៣:២៧]

នៅខែឧសភា ឆ្នាំ១៩៧២ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានឯកភាពផែនការសម្រាប់សមូហភាវូបនីយកម្មកសិកម្ម។ សហករណ៍ត្រូវបានបង្កើតឡើងជាផ្លូវការនៅតំបន់នានា ដែលខ្មែរក្រហមបានកាន់កាប់។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី២០ ឧសភា ឆ្នាំ១៩៧៣ ជាថ្ងៃដែលបក្សកុម្មុយនីស្តកម្ពុជាកំណត់ថាជាថ្ងៃកំណើតអង្គការសហករណ៍កសិករ។ ការធ្វើសមូហភាវូបនីកម្មសង្គមខ្មែរមានន័យថា ជាការលុបបំបាត់ទីផ្សាររូបិយប័ណ្ណ ទ្រព្យសម្បត្តិឯកជន និងការបំផ្លាញមធ្យោបាយផលិតកម្មកសិកម្មដែលមានស្រាប់។

[០៩:៤៤:១៨]

កសិករដែលធ្លាប់ ដែលបានទទួលប្រាក់ខែទាបអំពីសក្តិភូមិម្ចាស់ដី បានក្លាយទៅជាទាសករគ្មានតម្លៃរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅពេលដែលបានអនុវត្តទូទាំងប្រទេសបន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាបានកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាទាំងមូលបានក្លាយទៅជាគុកឥតជញ្ជាំង។ ដូចដែលលោក អៀង សារី បានប្រកាសនៅដើមឆ្នាំ១៩៧៦ ឥឡូវនេះប្រទេសទាំងមូលក្លាយទៅជាការដ្ឋានដាច់កន្ទុយភ្នែក។

[០៩:៤៤:៥៨]

ជនជាប់ចោទ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ការណែនាំទៅកម្មាភិបាលអំពីរបៀបរៀបចំសហករណ៍តាមរយៈការបោះពុម្ពផ្សាយដូចជាទស្សនាវដ្តីទង់បដិវត្តន៍ និងការអប់រំនយោបាយ និងការបណ្តុះបណ្តាលដែលមេដឹកនាំបានអនុវត្តដោយផ្ទាល់។ អង្គជំនុំជម្រះនឹងបានស្តាប់សក្ខីកម្មអំពីអតីតលេខាឃុំមកពីខេត្តក្រចេះ ដែលរៀបរាប់អំពីសុន្ទរកថារបស់ នួន ជា ទៅកាន់កម្មាភិបាលតំបន់ស្រុក ឃុំ នៅឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៤ ពន្យល់អំពីការបង្កើតសហករណ៍នោះ។ ការអនុវត្តសហភាវូបនីយកម្មកសិកម្ម មិនមែនជាការស្ម័គ្រចិត្តនោះទេ យើងមិនអាចដាំដំណាំបន្លែដោយខ្លួនឯងបានទេ យើងមិនមានសេរីភាពក្នុងទិតៀននយោបាយរបស់បក្សបានឡើយ។ ចំណុចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសុន្ទរកថារបស់ នួន ជា នៅក្នុងសន្និសីទប្រចាំឆ្នាំនៅភូមិភាគបស្ចិមនៅខែកក្កដា ឆ្នាំ១៩៧៧ និងត្រូវបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តន៍នៅក្នុងខែនោះដែរ។

[០៩:៤៦:២២]

ក្នុងសុន្ទរកថានេះ នួន ជា បាននិយាយថា កម្មាភិបាលភូមិភាគបស្ចិមម្នាក់ត្រូវបានរកឃើញថាជាខ្មាំងបង្កប់ក្នុងជួរបក្ស។ គាត់បាននិយាយរិះគន់ដំណើរការសមូហភាវូបនីយកម្មចំពោះកម្មាភិបាលរូបនេះ ហើយគាត់និយាយថា គោឯកជនធាត់ជាងគោរបស់សមូហភាព កម្មាភិបាលនោះ គឺ អ៊ូ ពិន ហៅ ហាម គឺជាអនុលេខាតំបន់៣២ នៃភូមិភាគបស្ចិម។ កាលពីដើមឆ្នាំ១៩៧៥ គេបានចាប់ខ្លួនគាត់ ហើយបញ្ជូនទៅ ស-២១ សួរចម្លើយជាច្រើនខែរហូតទាល់តែគាត់បានចុះហត្ថលេខាលើចម្លើយសារភាពដ៏វែងមួយ។ គេប្រើគាត់ជាគំរូអ្នកណាដែល-- សម្រាប់អ្នកណាដែលចោទសួរអំពីនយោបាយរបស់បក្ស។

[០៩:៤៧:២៣]

លោក លោកស្រីចៅក្រមជាទីគោរព! សហព្រះរាជអាជ្ញានឹងបង្ហាញថា គ្រប់ទិដ្ឋភាពនៃការកម្មវិធីសហករណ៍ដែលកំណត់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គណៈអចិន្ត្រៃយ៍ ដូចជាចំនួនស្រូវអង្ករដែលត្រូវផលិត របបអាហារដែលត្រូវប្រជាជនត្រូវហូបចុក ចំនួនកម្មករដែលត្រូវប្រើនៅក្នុងតំបន់នីមួយៗសុទ្ធតែកំណត់ដោយមេដឹកនាំទាំងអស់។

ក្នុងខែសីហា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បានទៅទស្សនាភូមិភាគពាយ័ព្យ និងសន្និដ្ឋានថា ភូមិភាគនេះត្រូវការកម្មករបន្ថែមបួនសែន ទៅប្រាំសែននាក់បន្ថែមទៀត ដើម្បីបង្កបង្កើនផលលើដីមានជីវជាតិឲ្យបានគ្រប់ទាំងស្រុងនៅភូមិភាគនោះ។ នៅខែបន្ទាប់មេដឹកនាំបក្សបានសម្រេចជម្លៀសដោយបង្ខំ

កន្លះលាននាក់បន្ថែមទៀត ពីភូមិភាគផ្សេងៗទៅភូមិភាគនេះ ហើយបានណែនាំតាមសារាចរណ៍របស់បក្សចុះថ្ងៃទី១៩ កញ្ញា ឆ្នាំ១៩៧៥។

[០៩:៤៨:៣៨]

ដូចដែលបានបញ្ជាក់នៅក្នុងឯកសាររបស់ខ្លួន សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង ទោះបីជាខ្លួនបានដឹងថា ប្រជាជនជម្លៀសពីមុន ឬក៏ប្រជាជនថ្មីត្រូវបានគេបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យពីភ្នំពេញ និងពីកន្លែងផ្សេងនៅដើមឆ្នាំនោះ មានការខ្វះខាតទាំងស្បៀងអាហារ និងថ្នាំសង្កូវក្តី។ ចំពោះប្រជាជនជម្លៀសដែលនៅរស់ពីការជម្លៀសលើកទីពីរនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ជោគវាសនាអាក្រក់កំពុងរង់ចាំពួកគេ។ គេបានបញ្ជូនប្រជាជនកន្លះលាននាក់ទៅតំបន់ ដែលមិនមានអាហារ ទីជម្រកចាំបាច់សម្រាប់ពួកគេ។ ប្រជាជនរាប់ម៉ឺននាក់បានស្លាប់ដោយអត់អាហារនៅក្នុងភូមិភាគពាយ័ព្យ។

ដូចបានរាយការណ៍ដោយតំបន់៥ នៃភូមិភាគពាយ័ព្យក្នុងស្រុកតែមួយប៉ុណ្ណោះក្នុងឆ្នាំ១៩៧៦ មនុស្សពីរម៉ឺននាក់បានស្លាប់ដោយសារអត់អាហារ គឺជាជនជាប់ចោទទាំងនេះ និងមេដឹកនាំបក្សទាំងនេះហើយ ដែលបានសម្រេចទាំងបរិមាណអង្ករ របបអាហារសម្រាប់ឲ្យពួកគេហូប និងចំនួនស្រូវដែលផលិត។ បញ្ហាទាំងនេះត្រូវបានពិភាក្សា និងដឹកនាំនៅក្នុងសន្និបាតបក្ស ស្តីពីបញ្ហាសេដ្ឋកិច្ច និងសេចក្តីសម្រេចរបស់ពួកគេត្រូវបានបញ្ជូនទៅ តាមរយៈឯកសារផែនការទៅកម្មាភិបាលថ្នាក់ក្រោមដើម្បីអនុវត្តទូទាំងប្រទេស។ នៅក្នុងសមាជសន្និបាតបក្សទូទាំងប្រទេសទីមួយ ដែលបានប្រារព្ធឡើងនៅខែវិច្ឆិកាឆ្នាំ១៩៧៥ បានកំណត់ចំនួនផែនការថា ធ្វើស្រូវបីតោនក្នុងមួយហិកតាក្នុងឆ្នាំ១៩៧៦ ដែលបានបោះពុម្ពផ្សាយ ហើយបានចែកទៅឲ្យកម្មាភិបាលថ្នាក់ក្រោម តាមរយៈទស្សនាវដ្តីទង់បដិវត្តន៍។

[០៩:៥០:៤៨]

បីតោនក្នុងមួយហិកតា បានត្រូវក្លាយទៅជាពាក្យស្លោកដែលគេនិយាយដដែលមិនចេះចប់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការប្រជុំសុន្ទរកថា ដូចជានៅក្នុងទង់បដិវត្តន៍ ហើយបានបញ្ជាក់ថា ជាការកត្តាសំខាន់នៅក្នុងការការពារជាតិ ការតស៊ូវណ្ណៈក្នុងពេលកំពុងអភិវឌ្ឍបន្ត។ ការពិតដែលថាទឹកន្លែងជាច្រើន ដីរបស់កម្ពុជាមិនមានជីវជាតិគ្រប់គ្រាន់ឲ្យបានផលស្រូវបីតោននោះ ក៏មិនជាកត្តាគិតគូរដែរ។ ការពិតដែលថាភ្លៀងអាចមិនធ្លាក់នោះនៅក្នុងតំបន់មួយចំនួន ក៏មិនយកមកគិតគូរទេ។ ការពិតដែលថាអាចមានកណ្តុរ សត្វចង្រៃ ឬក៏ជំងឺរុក្ខជាតិ មិនមានគ្រាប់ពូជគ្រប់គ្រាន់ក៏មិនយកពិចារណាអ្វីទាំងអស់។

[០៩:៥១:៤១]

អង្គហេតុ ដែលថាប្រជាជនអាចនឹងអស់កម្លាំង បាក់កម្លាំង ខ្សោយពេកដោយគ្មានអាហារ ឈឺខ្លាំងដោយសារជំងឺមិនអាចធ្វើការបាន ក៏គេមិនយកគិតគូរដែរ។ ការពិតដែលថា ប្រជាជនថ្មីមិនចេះដឹងពីវិធីដកស្ទូងស្រូវ ក៏មិនត្រូវយកមកពិចារណាឡើយ។ ប្រសិនបើមិនសម្រេចបានបីតោនក្នុងមួយហិកតាទេ គេនឹងចោទប្រកាន់អ្នកថា អ្នកឯងបរាជ័យ និងគេចាត់ទុកថា ជាជនក្បត់ ហើយចាត់ទុកជាខ្មាំងរបស់បក្ស។

ក្នុងផ្នែកនៃនយោបាយនេះ ដែលការបង្កើតសហករណ៍ និងការដ្ឋានជនជាប់ចោទ ក៏បានសម្រេចឲ្យមានប្រព័ន្ធធារាសាស្ត្រទូទាំងប្រទេសមួយឡើង។ ក្នុងខែឧសភា ឆ្នាំ១៩៧៥ នួន ជា បានជូនដំណឹងទៅកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាអំពីសេចក្តីសម្រេច ដើម្បីកសាងទំនប់ ប្រឡាយទូទាំងប្រទេសដោយចាប់ផ្តើមពីឆ្នាំ១៩៧៦ តទៅ។ ផែនការបួនឆ្នាំរបស់បក្ស ដែលបានរៀបចំក្នុងឆ្នាំ១៩៧៦ ត្រូវតម្រូវឲ្យមានបណ្តាញទំនប់ ប្រឡាយ ហើយនិងក្នុងសន្និបាតសេដ្ឋកិច្ចលើកទីពីរទូទាំងប្រទេសនៅឆ្នាំ១៩៧៦ បានសង្កត់ធ្ងន់លើតម្រូវការបង្កើនការផ្គត់ផ្គង់ទឹកឲ្យបានពីរទៅបីដង ខ្លាំងជាងមុនក្នុងឆ្នាំ១៩៧៦ និងកសាងទំនប់ ប្រឡាយ និងអាងទឹកថ្មីៗឲ្យបានច្រើនទៀត។

[០៩:៥៣:៣៤]

គម្រោងធារាសាស្ត្រធំបំផុតពីររបស់បក្សកុម្មុយនីស្តកម្ពុជា គឺសាងទំនប់ ១មករា នៅកំពង់ធំ និងទំនប់ត្រពាំងថ្ម នៅបន្ទាយមានជ័យ។ ទាំងនេះគឺជាការដ្ឋានដ៏ធំធេង ដែលកម្មកររាប់ម៉ឺននាក់ត្រូវបានចាត់តាំងឲ្យទៅធ្វើការ។ ទំនប់ ១មករា នេះមានទំហំធំណាស់ ដែលគេអាចមើលឃើញអំពីអវកាសបាន។ ដូចជាខ្ញុំបង្ហាញរូបភាពថតពីអវកាស ដោយ *ហ្គូហ្គលអឺដ*។ ទោះបីជាគម្រោងនេះមានទំហំដ៏មហិមាក៏ដោយ ក៏មេដឹកនាំបក្សកម្រិតរយៈពេលឲ្យបញ្ចប់នោះគឺខ្លីជាទីបំផុត។ ជាឧទាហរណ៍ ប្រធានការដ្ឋានទំនប់ ១មករា បញ្ជាក់ថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចង់ឲ្យបញ្ចប់ទំនប់៦០គីឡូម៉ែត្រមិនឲ្យតិចជាង-- មិនឲ្យលើសពីរយៈពេលមួយឆ្នាំឡើយ។

[០៩:៥៤:៤៥]

ការណែនាំមិនពិតប្រាកដដែលកំណត់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាផ្នែកមួយនៃគោលការណ៍មហាលោតផ្លោះ ដែលបានបណ្តាលឲ្យកម្មករត្រូវធ្វើការទាំងថ្ងៃទាំងយប់នៅការដ្ឋានក្នុងលក្ខខណ្ឌអាក្រក់បំផុត ដែលមិនអាចនឹកដល់។ អង្គការតម្រូវឲ្យពួកយើងធ្វើការពីម៉ោងប្រាំព្រឹក រហូតដល់ម៉ោង

ដប់យប់។ ពួកគេមិនបានទទួលអាហារគ្រប់គ្រាន់ បានថ្នាំគ្មានគុណភាពនិងកម្មករជាច្រើនបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារបាក់កម្លាំង អត់អាហារ ឬមានជំងឺ។

ការកសាងទំបន់ដ៏ធំទាំងពីរនេះ ត្រូវបានធ្វើឡើងដោយដៃទទេ ដូចដែលលោក លោកស្រីចៅក្រមបានឃើញនៅក្នុងខ្សែភាពយន្តឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជាបែបនេះ។

[០៩:៥៥:៥៨]

ជនជាប់ចោទបានដឹងយ៉ាងច្បាស់អំពីស្ថានភាពអមនុស្សធម៌នៅតាមការដ្ឋានទាំងនេះ ដែលគេបានដាក់ឲ្យប្រជាជនខ្មែរធ្វើនោះ។ នៅក្នុងឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បានសម្រេចចំណាយពេលជាងពាក់កណ្តាលរបស់ខ្លួន ដើម្បីតាមដានមូលដ្ឋាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយបង្កបង្កើនផលរបស់ខ្លួន។

ដូច្នេះហើយជនជាប់ចោទបានធ្វើដំណើរជាញឹកញាប់ទៅជនបទ ដើម្បីត្រួតពិនិត្យទំនប់នានា និងការដ្ឋានទាំងឡាយ។ ដូចដែលលោកចៅក្រមបានឮអំពីអ្នកបើកបរដែលបានជូនពួកគាត់ទៅទីកន្លែងនោះ។ អ្នកបើកបរម្នាក់នោះបាននិយាយថា "នួន ជា, អៀង សារី, ខៀវ សំផន បានទៅធ្វើទស្សនកិច្ចនៅកន្លែងនោះ ក៏បានកត់សម្គាល់អំពីការលំបាក ហើយនិងស្ថានភាពដ៏អាក្រក់បំផុតអាចមើលងាយ ហើយជនជាប់ចោទអាចមើលឃើញបានយ៉ាងងាយ"។ អ្នកបើកបរដដែលនេះបានបញ្ជាក់ថា គាត់បានជូនគាត់ទៅគ្រប់ខេត្តទាំងអស់ ហើយ នួន ជា បានចុះទៅមើលការដ្ឋានជាញឹកញាប់ប្រហែលប្រាំ ទៅប្រាំមួយដងក្នុងមួយខែ។ នៅក្នុងទស្សនកិច្ចនោះគាត់នឹងបានជួបកម្មាភិបាលមូលដ្ឋាន អំពីការបង្កបង្កើនផល និងកសាងទំនប់ជាដើម។ ដំណើរទស្សនកិច្ចខ្លះរបស់ជនជាប់ចោទត្រូវបានរាយការណ៍តាមវិទ្យុជាតិរបស់រដ្ឋកម្ពុជា ត្រូវបានកត់ត្រា តាមដានប្រតិចារឹក ហើយនិងផ្សព្វផ្សាយតាមព័ត៌មានអន្តរជាតិ ឬតាមការផ្សាយព័ត៌មានសង្ខេបរបស់វិទ្យុ ប៊ី.ប៊ី.ស៊ី ។

[០៩:៥៧:៤០]

លោក អៀង សារី នៅក្នុងខែឧសភា ឆ្នាំ១៩៧៦ ទៅកាន់ការដ្ឋាននៅក្នុងខេត្តសៀមរាប ហើយបានទស្សនាកម្មករពីពីរម៉ឺន ទៅពីរម៉ឺនកន្លះ។ សាក្សីទាំងឡាយបានចងចាំថា អៀង សារី, នួន ជា, ខៀវ សំផន បានធ្វើទស្សនកិច្ចនៅទំនប់១មករា ហើយ នួន ជា បានចូលរួមក្នុងពិធីសម្ពោធការកសាងទំនប់នេះ។

ជនជាប់ចោទក៏បានធ្វើទស្សនកិច្ចនៅការដ្ឋានទំបន់ត្រពាំងថ្ម និងការដ្ឋានសាងសង់ព្រលានយន្ត

ហោះកំពង់ឆ្នាំងដែរ។ ការដ្ឋាននេះត្រូវបានសម្រេចដោយកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលចូលរួមដោយនួន ជា, អៀង សារី, ខៀវ សំផន និងលោក អៀង សារី បានប្រើការដ្ឋាននេះដើម្បីដាក់ទណ្ឌកម្មបុគ្គលិក កម្មករក្រសួងការបរទេសដែលមានកំហុសតិចតួច ឬមិនខំធ្វើការ ឬក៏ឈឺច្រើន។ ក្រៅពីការធ្វើទស្សនកិច្ចជាបុគ្គល ជនជាប់ចោទក៏បានទទួលរបាយការណ៍ជាទៀងទាត់ពីភូមិភាគអំពីស្ថានការណ៍ និងលក្ខខណ្ឌការងារនៅការដ្ឋានទាំងនេះ។

[០៩:៥៩:០៤]

ក្នុងកិច្ចប្រជុំខែឧសភា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍ដោយមានវត្តមានរបស់ នួន ជា, ខៀវ សំផន លេខាតំបន់សៀមរាប តំបន់១០៦ បានរាយការណ៍ថា មានការផ្ទុះឡើងនូវជំងឺអាសន្នរោគ និងជំងឺអុតស្វាយដែលបណ្តាលឲ្យមនុស្សស្លាប់ជាច្រើន៥០ភាគរយ។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ លេខាភូមិភាគកណ្តាលបានរាយការណ៍ថា ត្រូវកសាងទំនប់តាមផែនការ ដូចដែលអង្គការបានកំណត់ ទោះបីជាមានជំងឺរាគរូស គ្រុនក្តៅខ្លាំង ដោយសារការធ្វើការខ្លាំង និងកម្តៅខ្លាំងយ៉ាងណាក៏ដោយ។

លោក លោកស្រីចៅក្រម នឹងស្តាប់សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ដែលឆ្លុះបញ្ចាំងនូវការដឹងឮអំពីស្ថានភាពដែលកើតមាននៅការដ្ឋាន និងសហករណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាជនជាប់ចោទបានដឹងឮអំពីការឈឺចាប់របស់ប្រជាជនខ្មែរក៏ដោយ ជនជាប់ចោទទាំងនោះនៅតែបានបន្តជំរុញឲ្យមានការកសាងឲ្យបានលឿនលើទំនប់ប្រឡាយ។ នៅក្នុងឆ្នាំ១៩៧៨ ជនជាប់ចោទបានបង្កើនកូតាផលិតផលស្រូវឲ្យដល់ចំនួន៣,៥តោនក្នុងមួយហិកតា។ ជនជាប់ចោទបានណែនាំឲ្យប្រើប្រាស់ដីដាំដំណាំពីរមុខឲ្យបានទ្វេដង។ អាក្រក់ជាងនេះទៅទៀតនោះ ទោះបីជាដឹងថាប្រជាជនបានស្លាប់ពីការអត់អាហារនៅក្នុងតំបន់ជាច្រើន ជនជាប់ចោទបានណែនាំថា ស្រូវ និងម្ហូបជាច្រើនត្រូវដកហូតពីសហករណ៍ប្រជាជនដើម្បីយកមកប្រើប្រាស់ដើម្បីនាំចេញ។

[១០:០១:០១]

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ទោះបីជនជាប់ចោទបានបំបាត់ចោលប្រទេសមូលធននិយម និងបោសសម្អាតពួកមូលធននិយម ជនជាប់ចោទនៅតែត្រូវការមូលធន និងទុន ដដែល។ ពីព្រោះជនជាប់ចោទលុបបំបាត់លុយ របស់តែមួយគត់ដែលជនជាប់ចោទអាចប្រើប្រាស់សម្រាប់ចំណាយលើទុននោះ គឺស្រូវនិងម្ហូបអាហារ។ ដូច្នេះ នៅក្នុងផែនការបួនឆ្នាំ ជនជាប់ចោទបានគិតឃើញថាចំពោះស្រូវ១០ម៉ឺនតោនដែលនាំចេញ ជនជាប់ចោទអាចទទួលបានប្រាក់សុទ្ធចំនួន២០លានដុល្លារមកវិញ។

ដោយផ្អែកលើតម្រូវការលើទុន និងប្រាក់ទាំងអស់នេះហើយ ទើបជនជាប់ចោទបានកំណត់ថាតើត្រូវការស្រូវចំនួនប៉ុន្មានពីតំបន់នីមួយ? ជារៀងរាល់ឆ្នាំ យោងតាមផែនការនេះ ស្រូវត្រូវបានរឹបអូសពីកម្មករ ឬក៏អ្នកស្រែដែលកំពុងស្រេកឃ្លាន ដើម្បីយកមកឲ្យមេដឹកនាំបក្សទិញម៉ាស៊ីន ប្រេង និងសម្ភារៈផ្គត់ផ្គង់ផ្សេងទៀត។

[១០:០២:១០]

នេះគឺជាកេរដំណែលចុងក្រោយ នៃគោលនយោបាយសមូហភាវូបនីយកម្មនៃបក្សកុម្មុយនីស្តកម្ពុជា ពោលយកជីវិតនៃកម្មករដែលត្រូវបានជិះជាន់មកដូរជាទុននិងប្រាក់។ នៅពេលនេះ ខ្ញុំសូមអនុញ្ញាតចូលទៅដល់ផ្នែកទីបី ដែលពាក់ព័ន្ធទៅនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួម គឺស្តីអំពីការអប់រំកែប្រែលើសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង។ ក្នុងចំណោមឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជាគ្មានអ្វីដែលត្រូវចងចាំ និងឈឺចាប់ ដូចការចាប់ខ្លួនដោយខុសច្បាប់ ការឃុំខ្លួន ការធ្វើទារុណកម្ម និងការកាប់សម្លាប់ប្រជាជនកម្ពុជាចំនួនរាប់សែននាក់ នៅតាមបណ្តាលមន្ទីរសន្តិសុខ និងមន្ទីរអប់រំកែប្រែទាំងអស់នោះ។ នៅក្នុងថ្ងៃនេះ មុននេះបន្តិច ខ្ញុំបានធ្វើការសន្និដ្ឋានអំពីរបៀបដែល នួន ជា និងអៀង សារី និងស្ថាបនិកផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជាបានអនុម័តគោលនយោបាយ ឬមាគ៌ាបក្សនៅក្នុងខែកញ្ញា ១៩៦០ ដើម្បីប្រើប្រាស់អំពើហិង្សាប្រដាប់អាវុធបង្ក្រាបពួកសក្តិភូមិ ពួកនាយទុន ពួកប្រតិកិរិយា ដែលត្រូវបានចាត់ទុកថាជាខ្មាំង។

[១០:០៣:៤២]

មាគ៌ានយោបាយនេះ មានសារៈសំខាន់ចំពោះកម្មវិធីរបៀបវារៈរបស់ជនជាប់ចោទ និងជាកម្មវត្ថុរបស់បុគ្គលនីមួយៗដែលបានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបញ្ជាក់ការឯកភាពនឹងគ្នា។ ដូច ខៀវ សំផន បានសរសេរឡើងសមាជិកទាំងអស់ទាមទារឲ្យដាក់ពាក្យសុំរបស់ខ្លួនឡើងវិញ ដើម្បីសុំចូលបក្ស ក្រោយពីការអនុម័តមាគ៌ាបក្សថ្មីៗ នៅក្នុងឆ្នាំ១៩៦០។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជឿថាខ្លួនបានរកឃើញការសម្ងាត់នៃការធ្វើបដិវត្តន៍កុម្មុយនីស្ត ការសម្ងាត់ដែលជនកុម្មុយនីស្តមុនៗពុំបានដឹង។ ជនជាប់ចោទជឿថា បដិវត្តន៍កុម្មុយនីស្តមុនៗបរាជ័យ ពីព្រោះតែខ្មាំងវណ្ណៈបានជ្រៀតចូល និងធ្វើឲ្យបំផ្លាញដល់បដិវត្តន៍។

ដំណោះស្រាយដែលជនជាប់ចោទប្រកាន់យក គឺសាមញ្ញបំផុត ដោយត្រូវបំបាត់ចោលខ្មាំងវណ្ណៈឲ្យហ្មត់។ ខណៈដែលសេចក្តីសម្រេចក្នុងប្រើប្រាស់អំពើហិង្សាប្រឆាំងខ្មាំងនយោបាយអាចទំនង

ធ្វើឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដើម្បីជាមធ្យោបាយឈ្នះអំណាចក្នុងការបះបោរស៊ីវិល។ គោលនយោបាយនេះបានបន្តក្រោយពីជនជាប់ចោទ បានចូលកាន់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះហើយ វាបានក្លាយជាមធ្យោបាយមួយសម្រាប់ការពារអំណាចដែលកាន់កាប់នាពេលនោះដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីទប់នឹងប្រជាជនកម្ពុជាទាំងអស់ដែលគ្រោងនឹង/ឬដែលបានប្រឆាំងតវ៉ា ឬមិនគោរពតាមកម្មវិធីរបៀបវារៈរបស់ខ្លួន។ មកទល់ពេលនេះ នួន ជា នៅទទូចថាប្រជាជនដែលខ្លួនបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាខ្មាំង ឬក៏ពួកក្បត់។

[១០:០៦:០០]

*(ការបង្ហាញឯកសារជារូបភាពវីដេអូ ចាប់ពីម៉ោង ១០:០៦:០០ ដល់ម៉ោង ១០:០៧:៤៥)*

គេអាចសួរថា តើនរណាជាខ្មាំងទាំងអស់នេះ? តើជនជាប់ចោទសំដៅទៅលើនរណាខ្លះនៅពេលលើកឡើងណែនាំកម្មាភិបាលបក្សឲ្យកម្ទេច ឬបោសសម្អាតខ្មាំងទាំងនោះឲ្យអស់។ ការពិតនោះបង្ហាញឲ្យយើងឃើញថា មនុស្សដែលជនជាប់ចោទចាត់ទុកថាជាខ្មាំងនៃបក្សកុម្មុយនីស្តកម្ពុជា គឺក្រុមមនុស្សដែលតែងតែវិវឌ្ឍន៍ និងពង្រីកពីតូចទៅធំជានិច្ច។ ពីដំបូងខ្មាំងដែលត្រូវកម្ចាត់ចោលគឺពួកសក្តិភូមិ ពួកនាយទុន និងពួកប្រតិកិរិយា។

នៅក្នុងការបោះពុម្ពផ្សាយដែលបានផ្តល់ជូនដោយសម្ងាត់ទៅសមាជិកបក្ស មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ថា នរណាខ្លះដែលត្រូវដាក់បញ្ចូលនៅក្នុងក្រុមខ្មាំងទាំងអស់នេះ? ពួកសក្តិភូមិរួមមាន ម្ចាស់ដី និងស្តេច ព្រមទាំងមន្ត្រីជាន់ខ្ពស់ដូចជារដ្ឋមន្ត្រី អភិបាលខេត្ត ចៅហ្វាយស្រុក រហូតទៅដល់មេឃុំ។ ពួកនាយទុនជាចម្បងនោះ គឺអ្នកដែលប្រើប្រាស់ធនធានធម្មជាតិជាតិ មធ្យោបាយ និងកម្លាំងពលកម្ម គឺការប្រើប្រាស់កម្មករសម្រាប់ផលិតកម្ម និងអ្នកដែលប្រមូលផលស្រូវ ឬគ្រាប់ធញ្ញជាតិផ្សេងទៀតយកទៅលក់ឲ្យបរទេស។

[១០:០៩:១៥]

ទោះបីជាយ៉ាងនេះក្តី ក្រុមនេះត្រូវបានពង្រីកបន្ថែមដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដោយដាក់បញ្ចូលពួកនាយទុនដែលជាបញ្ញវន្ត និស្សិត និងមន្ត្រីរាជការដែលប្រើប្រាស់បញ្ញវន្តរបស់ខ្លួនសម្រាប់ការចិញ្ចឹមជីវិត។ ដោយសារសេចក្តីសម្រេចនេះហើយ ទើបនិស្សិត គ្រូ វេជ្ជបណ្ឌិត អ្នកច្បាប់ និងអ្នកប្រកបវិជ្ជាជីវៈផ្សេងទៀត បានក្លាយជាខ្មាំងវណ្ណៈ ដែលត្រូវគេបានកំណត់គោលដៅសម្រាប់សម្លាប់ចោលដោយបក្សកុម្មុយនីស្តកម្ពុជា។

[១០:០៩:៤៨]

បញ្ជីវាយនាមខ្មាំង ដែលត្រូវសម្លាប់ចោលដោយបក្សកុម្មុយនីស្តកម្ពុជា បានកើនរហូតដល់ការដាក់បញ្ចូលទាហាន និងមន្ត្រីក្នុងរបបមុនៗដែលខ្មែរក្រហមបានវាយប្រយុទ្ធលើរបបនេះ ពោលគឺរបបលន់ នល់ និងសាធារណរដ្ឋ និងរបបសង្គមរាស្ត្រនិយម។ ជនសង្ស័យក៏ជាអ្នកភ្នំពេញ និងតាមបណ្តាទីប្រជុំជនផ្សេងទៀត ដែលត្រូវបានជម្លៀសទៅទីជនបទនៅពេលបក្សកុម្មុយនីស្តក្តោបក្តាប់អំណាច ពោលគឺប្រជាជនដែលគេហៅថា "ពួក១៧ មេសា ឬប្រជាជនថ្មី"។ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យដំណើរការទៅមុខ និងមេដឹកនាំ ដែលមានការភ័យខ្លាចរបស់បក្សកុម្មុយនីស្តកម្ពុជាជឿលើខ្លួនឯងថាការបរាជ័យរបស់ខ្លួនគឺបណ្តាលមកពី សេ.អ៊ី.អា, កា.ហ្សេ.បេ ឬគិញវៀតណាម។ ការផ្តោតលើខ្មាំងចាប់ផ្តើមងាកទៅរកខ្មាំងផ្ទៃក្នុងដែលបានជ្រៀតចូលជួរបក្ស។ កាបោសសម្អាតទាំងនេះបានចាប់ផ្តើមដោយការចាប់ខ្លួនទាហានមួយចំនួនក្រោយពីការផ្ទុះគ្រាប់បែកនៅព្រះបរមរាជវាំង។ ការបោកសម្អាតទាំងនេះបានរីករាលដល់មេបញ្ជាការកងពល និងចុងក្រោយទៅដល់កម្មាភិបាលនៅគ្រប់ភូមិភាគក្រសួង និងកងពលទាហាននៅទូទាំងប្រទេស ដែលត្រូវបានគេឆ្លើយដាក់ នៅក្នុងចម្លើយសារភាពទទួលបានដោយមន្ទីរសន្តិសុខរបស់គណៈអចិន្ត្រៃយ៍ ដែលលោក លោកស្រី ចៅក្រមបានស្គាល់រួចហើយ ថាជាមន្ទីរស-២១។

[១០:១១:២១]

នៅក្នុងឆ្នាំចុងក្រោយនៃរបបនេះ ដោយសារជម្លោះប្រដាប់អាវុធបានកើនឡើងយ៉ាងខ្លាំងរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។ ជនជាតិវៀតណាមគឺជាជនជាតិ បានក្លាយទៅជាខ្មាំងលំដាប់ទីមួយ ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានផ្តោតការយកចិត្តទុកដាក់។ ចលនា រលកនៃការកាប់សម្លាប់បានរីករាយដាលរហូតដល់បុគ្គលដែលមានទំនាក់ទំនង ឬដែលពាក់ព័ន្ធទៅនឹងវៀតណាម ដែលក្នុងនោះរួមមានអ្នកនៅភូមិភាគបូព៌ាដែលមានកំហុស ដោយសាររស់នៅជាប់ពេកទៅនឹងព្រំដែនវៀត-ណាម និងសហគមន៍ខ្មែរក្រោមគឺជនជាតិខ្មែរដែលមានជីដូនជីតាធ្លាប់រស់នៅក្នុងទឹកដីវៀតណាម។ ជនទាំងអស់នោះត្រូវបានគេចោទថា "មានខ្លួនខ្មែរតែក្បាលយួន"។

ជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានសម្រេចថា ជនជាតិចាមគឺជាខ្មាំងផងដែររបស់រដ្ឋ។ ដូច្នេះអ្នកទាំងអស់នោះត្រូវបានគេសម្លាប់ចោល ដែលអ្នកទាំងអស់នោះរស់នៅតាមទីកន្លែងប្រវត្តិសាស្ត្រ ដូចជានៅតាមដងទន្លេមេគង្គក្នុងខេត្តកំពង់ចាម។ មិនត្រឹមតែជនដែលស្ថិតក្នុងចង្កោមនេះប៉ុណ្ណោះទេ ដែលជា

ក្រុមដែលគេកំណត់គោលដៅ ហើយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាប្រកាសថា “ជាខ្មាំង ឬជនក្បត់”។ អ្នកដែលជាប់ពាក់ព័ន្ធ ឬទាក់ទងទៅនឹងពួកគេក៏ត្រូវបានចាត់ទុកដូច្នោះដែរ គឺថា “ដកស្មៅត្រូវដកទាំងឫស” ដែលនេះជាពាក្យស្លោករបស់បក្សកុម្មុយនីស្តកម្ពុជា។

[១០:១៣:០២]

នៅក្នុងលោកទស្សនៈរបស់ខ្មែរក្រហម“កំហុសគឺជាប់ទាក់ទងទៅនឹងហ្សែន”។ ដូច្នេះខ្មែរក្រហមមិនត្រឹមតែបានសម្លាប់ខ្មាំងប៉ុណ្ណោះទេ ខ្មែរក្រហមជារឿយៗបានសម្លាប់រង្គាលគ្រួសារទាំងមូលរបស់ជនដែលគេកំណត់ថាជា “ខ្មាំង” រួមមានប្រពន្ធ កូន និងក្នុងករណីជាច្រើន រហូតដល់ឪពុកម្ដាយ ឬបងប្អូនបង្កើត។ អ្នកទាំងអស់នោះត្រូវបានចាប់ខ្លួន ឬចាត់ទុកថាជនសង្ស័យដែលត្រូវបានគេតាមដានយ៉ាងស្អិតរកមើលសកម្មភាពខ្មាំង។ មាគ៌ាបក្សពាក់ព័ន្ធទៅនឹងខ្មាំងដែលត្រូវបង្កើតដោយជនជាប់ចោទ និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតត្រូវបានបញ្ជូនទៅកម្មាភិបាលតាមរយៈមធ្យោបាយមួយចំនួន។ ការអប់រំ ឬការបណ្ដុះបណ្ដាលនយោបាយជាទៀងទាត់បានធ្វើឡើងដោយ នួន ជា, ខៀវ សំផន និង អៀង សារី នៅតាមទីតាំងក្នុងទីក្រុងភ្នំពេញ ដូចជា បុរីកីឡា ឬស្តាតអូឡាំពិក ដែលនៅពេលនោះបានចូលរួមដោយកម្មាភិបាលមកពីតាមស្រុក តំបន់ ភូមិភាគ និងកងពលទ័ពនៅទូទាំងប្រទេស។

[១០:១៤:០៧]

រូបភាពនេះដែលលោក លោកស្រីទើបតែមើលអម្បាញ់មិញនេះ គឺបង្ហាញអំពីកិច្ចប្រជុំមួយដែលដឹកនាំដោយ ខៀវ សំផន, អៀង សារី, សុន សេន និង ហ៊ូ នឹម ហើយរូបភាពខ្សែវីដេអូនេះបង្ហាញនូវ ប៉ុល ពត និងនួន ជា ដឹកនាំកិច្ចប្រជុំធំមួយរបស់កម្មាភិបាល។ អៀង សារី ក៏បានផ្ដល់ការអប់រំវគ្គនយោបាយនៅក្រសួងការបរទេស និងមន្ទីរអប់រំកែប្រែបឹងត្របែក ដែលគេប្រើប្រាស់សម្រាប់បញ្ញវន្ត ឬនិស្សិត និងអតីតមន្ត្រីទូតដែលត្រឡប់មកបរទេស។

លោក លោកស្រីចៅក្រមនឹងស្ដាប់សក្ខីកម្មរបស់សាក្សីមួយចំនួន ដែលជាប់នៅក្នុងមន្ទីរទាំងអស់នោះ។

[១០:១៥:០៤]

ឯកសារមួយយកមកពីក្រសួងការបរទេស បានកត់ត្រានូវឧទាហរណ៍មួយអំពីការណែនាំដូច្នេះ។ នៅពេលសន្និបាតក្រសួងឆ្នាំ ក្នុងថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦ កម្មាភិបាលបានត្រូវគេប្រាប់ថា មានចំនួនមួយទៅប្រាំភាគរយនៅក្នុងប្រទេសគឺជា “ជនក្បត់ស៊ីរូងផ្ទៃក្នុង” និងបង្គាប់ឲ្យស៊ើបអង្កេតប្រវត្តិរូប ធ្វើ

ស្វ័យទិតៀន តាមដានគ្រប់សកម្មភាពរបស់សមាជិកខ្មែរក្រហម និងចាត់ចែងលើខ្មាំងស៊ីរូងផ្ទៃក្នុង ដើម្បីកុំឲ្យជ្រៀតចូលក្រសួងរបស់ខ្មែរក្រហម។ មធ្យោបាយចម្បងមួយទៀត ដែលមាគ៌ាបក្សបានបញ្ជូនទៅកម្មាភិបាល គឺតាមរយៈសេចក្តីណែនាំមកពីមន្ទីរ៨៧០ និងតាមរយៈទង់បដិវត្តន៍ប្រចាំខែរបស់បក្ស ដែលត្រូវបានចែកផ្សាយនៅទូទាំងប្រទេស ហើយតម្រូវឲ្យសមាជិកបក្សទាំងអស់អាន។

នៅក្នុងទង់បដិវត្តន៍ទាំងនោះ ខ្លឹមសារដូចគ្នាត្រូវបានលើកឡើងដដែលៗ និងពីការចេញផ្សាយពីមួយខែទៅមួយខែ។ ខ្លឹមសារទាំងនោះមានភាពចាំបាច់សម្រាប់កំណត់អត្តសញ្ញាណ និងកម្ទេចខ្មាំងរបស់បក្ស។

លោក លោកស្រីចៅក្រមជាទីគោរព! ឧបសម្ព័ន្ធទីពីរនៃបញ្ជីឯកសារតុលាការរបស់សហព្រះរាជអាជ្ញាបង្ហាញនូវការបោះពុម្ពផ្សាយសេចក្តីណែនាំ និងសេចក្តីបង្គាប់បញ្ជាដែលបានចេញផ្សាយដោយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជូនកម្មាភិបាលនៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ ដែលឯកសារទាំងអស់នោះមាន៨៦ច្បាប់។

នៅក្នុងការបោះពុម្ពផ្សាយចំនួន៨៦ របស់បក្សកុម្មុយនីស្តកម្ពុជា ពាក្យថា “ខ្មាំង ឬ ជនក្បត់” លើកឡើងយ៉ាងហោចណាស់ចំនួន៤.៧០៧ ដង។ ពោលគឺលើកឡើងពីរដង រៀងរាល់ពីរទំព័រ។

[១០:១៧:២៥]

ផលវិបាកដែលកើតចេញពីការណែនាំឲ្យបោសសម្អាតនៅក្នុងប្រទេស គឺមានការចាប់ខ្លួន ការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់ប្រជាជនកម្ពុជារាប់សែននាក់នៅមន្ទីរស-២១ និងនៅតាមមន្ទីរសន្តិសុខចំនួន២០០ផ្សេងទៀត ដែលមាននៅទូទាំងប្រទេសនេះ។

ករណីនេះហើយ អាចឲ្យយើងឃើញដោយផ្ទាល់នៅក្នុងទូរសារ ឬរបាយការណ៍ផ្ញើមកពីភូមិភាគរហូតដល់មជ្ឈិមបក្ស ដែលបង្ហាញយ៉ាងច្បាស់ថា “គោលនយោបាយលើខ្មាំងរបស់ជនជាប់ចោទ ជាគោលនយោបាយទទួលខុសត្រូវលើការចាប់ខ្លួន និងការសម្លាប់ក្នុងលក្ខណៈរីករាលដាល ដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ” ដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើងជូនអង្គសវនាការកាលពីម្សិលមិញនេះ។

[១០:១៨:២២]

ក្រៅពីតួនាទីដែលបង្កើតនយោបាយលើខ្មាំងនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងនាមជាសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ជនជាប់ចោទនីមួយៗក៏បានចូលរួមដោយផ្ទាល់នៅក្នុងការអនុវត្តផែនការ

នេះជាក្រុម ឬជាលក្ខណៈបុគ្គល។

នួន ជា, អៀង សារី, និង ខៀវ សំផន បានចូលរួមៗគ្នានៅក្នុងការសម្រេចលើការចាប់ខ្លួនក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលពួកគេបានចូលរួម។ ឧទាហរណ៍ នៅក្នុងពេលប្រជុំថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ អនុលេខាភូមិភាគឧត្តរ បានរាយការណ៍អំពីសកម្មភាពខ្មាំង និងការចាប់ខ្លួនបុគ្គលផ្សេងៗនៅក្នុងតំបន់របស់គាត់ ហើយបានស្នើសុំការណែនាំការចាត់ចែងលើក្រុមដែលបានប៉ុនប៉ងគេចទៅប្រទេសវៀតណាម។

[១០:១៩:២៤]

ឆ្លើយតបទៅនឹងការស្នើសុំនោះ គណៈអចិន្ត្រៃយ៍បានបង្គាប់ឲ្យឃុំខ្លួន និងសួរចម្លើយមនុស្សទាំងអស់នោះ ដោយឲ្យរាយការណ៍ជាលទ្ធផលជូនថ្នាក់លើ ដោយភ្ជាប់សំណុំរឿងទាំងនោះទៅជាមួយផង។

សាក្សីសំខាន់មួយរូបនៅក្នុងកិច្ចដំណើរការសវនាការរបស់យើងនេះ ដែលវាពាក់ព័ន្ធ ដែលបង្ហាញ ពាក់ព័ន្ធអំពីតួនាទីរបស់គណៈអចិន្ត្រៃយ៍ និងជនជាប់ចោទនៅក្នុងការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ គឺសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធាន ស-២១។

កម្មាភិបាលមួយរូបដែលជនជាប់ចោទបានសម្រេចលើជោគវាសនានោះ គឺជាសមាជិកគណៈមជ្ឈិម ដែលមានឈ្មោះថា សួស នៅ ហៅឈូក ដែលជាលេខាតំបន់២៤ នៃភូមិភាគបូព៌ា។ ឈូកត្រូវបានគេឆ្លើយដាក់ថាជាខ្មាំងតាមរយៈកងពល១៧០ គឺ ចាន់ ចក្រី ហើយកម្មាភិបាលផ្សេងទៀតត្រូវបានចាប់ខ្លួន និងសួរចម្លើយនៅមន្ទីរស-២១ ក្នុងពាក់កណ្ដាលឆ្នាំ១៩៧៦។ ឌុច នឹងរៀបរាប់អំពីរបៀបដែលគេស្នើសុំគាត់ឲ្យផ្ដល់សម្រង់ចម្លើយសារភាពចំនួនប្រាំពីរច្បាប់ ដែលឆ្លើយដាក់បន្ទុក ឈូក គឺចម្លើយសារភាពនីមួយៗសម្រាប់សមាជិកគណៈអចិន្ត្រៃយ៍។ ឌុច នឹងផ្ដល់សក្ខីកម្មថា តើគេចាប់ ឈូក នៅខែសីហា ឆ្នាំ១៩៧៦ ដោយរបៀបណា?

នួន ជា បានធ្វើដំណើរទៅមន្ទីរនីរសារ ក-៧ នៅមាត់ទន្លេ ដើម្បីពិនិត្យមើលការចាប់ខ្លួន ឈូក។ កុយ ធួន ហៅធុច គឺជាកម្មាភិបាលជាន់ខ្ពស់មួយរូបទៀត ដែលត្រូវបានគេសង្ស័យនៅពេលនោះ។ កុយ ធួន គឺជាសមាជិកគណៈមជ្ឈិមយូរមកហើយ ពីដំបូងធ្វើការងារជាលេខាភូមិភាគឧត្តរ និងក្រោយមកជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

[១០:២១:៣៩]

នៅក្នុងនេះ លោក លោកស្រីចៅក្រម ឃើញរូបភាព កុយ ធួន ដែលជាប់នៅមន្ទីរស-២១។

ក្រោយពេលចាប់ខ្លួនធ្វើឡើងតាមបញ្ជាគណៈអចិន្ត្រៃយ៍នៅក្នុងខែមេសា ឆ្នាំ១៩៧៦ កុយ ធួន ត្រូវបានគេឃុំនៅក្នុងផ្ទះមួយក្នុងទីតាំងមន្ទីរក-១ រយៈពេលជាងប្រាំបួនខែ។ ទីតាំងនោះ ជាមន្ទីរដែលជនជាប់ចោទម្នាក់ទៅពិនិត្យមើលស្ទើររាល់ថ្ងៃ។

លោក លោកស្រីចៅក្រម នឹងស្ដាប់សក្ខីកម្មពីឆ្មាំយាមមួយរូប ដែលធ្វើការនៅមន្ទីរក-១ ដែលអ្នកយាមនោះយកអាហារឲ្យ កុយ ធួន នៅក្នុងផ្ទះនោះ។ អង្គហេតុពាក់ព័ន្ធនឹងការចាប់ខ្លួន កុយ ធួន ក៏បានសរសេរបញ្ជាក់ដោយ ខៀវ សំផន នៅក្នុងស្នាដៃសៀវភៅមួយរបស់ជននោះផងដែរ។ កុយ ធួន ត្រូវបានបញ្ជូនពីមន្ទីរក-១ ទៅមន្ទីរ ស-២១ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ដែល ឌុច ផ្ទាល់ជាអ្នកសួរចម្លើយ។ ក្រោយមក កុយ ធួន ទទួលរងការធ្វើទារុណកម្មធ្ងន់ធ្ងរតាមរយៈបញ្ជារបស់សមាជិកគណៈអចិន្ត្រៃយ៍មួយរូបគឺ សុន សេន។ ចម្លើយសារភាពរបស់ កុយ ធួន និង ឈូក ធ្វើឲ្យបក្សចាប់ផ្ដើមបាត់លំនឹង ចម្លើយសារភាពនីមួយៗឆ្លើយដាក់ក្រុមជនក្បត់យ៉ាងច្រើន ក្នុងនោះការឃុបឃិតប្រឆាំងនឹងបក្សនៅទូទាំងប្រទេសនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ការបោសសម្អាតផ្ទៃក្នុងដែលបានរីករាលដាលនៅទូទាំងក្បាលម៉ាស៊ីននៃបក្សកុម្មុយនីស្តកម្ពុជាទាំងមូល ហើយបាននាំឲ្យមានការចាប់ខ្លួន និងកាប់សម្លាប់កម្មាភិបាលបក្សរាប់ម៉ឺននាក់ដូចបានបង្ហាញនៅក្នុងតារាងនេះ។

[១០:២៤:០៦]

រដ្ឋមន្ត្រីឃោសនាការ ហ៊ូ នឹម គឺស្ថិតនៅក្នុងលេខរៀងទី១៣ ក្នុងបញ្ជីជនក្បត់ដែលឆ្លើយដាក់ដោយ កុយ ធួន។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ហ៊ូ នឹម ត្រូវបានចាប់ខ្លួននាំយកទៅមន្ទីរស-២១ ការឆ្លើយតបភ្លាមៗរបស់ ហ៊ូ នឹម គឺគាត់បានសរសេរលិខិតមួយច្បាប់ទៅមនុស្សដែលទទួលខុសត្រូវលើការចាប់ខ្លួនគាត់ គាត់ដោយបដិសេធថា គាត់ពុំបានក្បត់បក្សឡើយ។ ក្នុងនាមជារដ្ឋមន្ត្រី និងជួរដឹកនាំនៅក្នុងទីក្រុងភ្នំពេញ ហ៊ូ នឹម បានយល់យ៉ាងច្បាស់អំពីបុគ្គលដែលជាមេដឹកនាំបក្ស ដែលគ្រប់គ្រងនិងសម្រេចលើជោគវាសនារបស់គាត់។

[១០:២៤:៥០]

ដូច្នេះ ហ៊ូ នឹម បានសរសេរចម្លើយសារភាពថា ខ្លួនគាត់ជាជនស្លូតត្រង់ ហើយគាត់បានសរសេរទៅកាន់ នួន ជា, អៀង សារី, វន វ៉េត, ប៉ុល ពត, សុន សេន និង ខៀវ សំផន។ លើសពីនេះក្នុងនាមជាសមាជិកនៃគណៈមជ្ឈិមនៃបក្សកុម្មុយនីស្ត នួន ជា, អៀង សារី និង ខៀវ សំផន បានអនុញ្ញាតឲ្យមានការកាប់សម្លាប់នៅក្នុងជួរ និងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជាតាមរយៈសេចក្ដីសម្រេច

ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ នៅក្នុងសេចក្តីសម្រេចនេះ ជនជាប់ចោទផ្តល់អំណាចដល់គណៈកម្មាធិការភូមិភាគឲ្យសម្លាប់នៅតាមមូលដ្ឋាន។ គណៈកម្មាភិបាលមជ្ឈិមដែលសំដៅលើមន្ទីរ៨៧០ ត្រូវបានអនុញ្ញាតឲ្យកម្ទេចបរិវេណជុំវិញមន្ទីរមជ្ឈិម។ ការកាប់សម្លាប់នៅតាមតំបន់ឯករាជ្យ និងស្វយ័តត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍ និងមន្ទីរសេនាធិការយោធារបស់ សុន សេន ដោយទទួលសិទ្ធិកម្ទេចនៅក្នុងជួរយោធារបស់មជ្ឈិមបក្ស។

[១០:២៦:១០]

សេចក្តីសម្រេចរបស់ជនជាប់ចោទក្នុងការផ្តល់អំណាចធំធេង ដល់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការអនុវត្តគោលនយោបាយបក្សលើខ្មាំងបានបណ្តាលឲ្យមានការស្លាប់រាប់មិនអស់ ហើយសេចក្តីចម្រេចនេះ គឺជាភស្តុតាងយ៉ាងច្បាស់បង្ហាញចេតនារបស់ជនជាប់ចោទនៅក្នុងការកាប់សម្លាប់។ ក្រៅពីសកម្មភាពរួម ចេតនារួម ក្នុងនាមសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមសហព្រះរាជអាជ្ញានឹងបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ អំពីការចូលរួមរបស់ជនជាប់ចោទម្នាក់ៗ ដែលបង្ហាញអំពីតួនាទីជាក់លាក់របស់ជនជាប់ចោទទាំងនោះដោយសង្ខេប ហើយខ្ញុំនឹងបង្ហាញតួនាទីនីមួយៗរបស់ជនជាប់ចោទ ដែលពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងការកាប់សម្លាប់ខ្មាំង ដែលគេចាត់ទុកថា ជាខ្មាំង។

ខ្ញុំមិនដឹងថា តើនៅពេលនេះលោក លោកស្រីចៅក្រម គិតថា យើងគួរតែសម្រាកសិនឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

អរគុណលោកសហព្រះរាជអាជ្ញា។ ឥឡូវនេះពេលវេលាសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១០:២៨ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តធ្វើបទបង្ហាញសេចក្តីសន្និដ្ឋានចោទប្រកាន់។

សូមអញ្ជើញ!

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ មុនពេលឈប់សម្រាកខ្ញុំបានបង្ហាញថា ខ្ញុំនឹងលើកឡើងដោយសង្ខេបអំពីតួនាទីរបស់ជនជាប់ចោទនីមួយៗក្នុងចំណោមជនជាប់ចោទទាំងបី ដែលតួនាទីនោះវាពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងសម្លាប់ខ្មាំង។

[១០:៥៥:០៨]

ជាបឋមខ្ញុំសូមលើកឡើងពាក់ព័ន្ធទៅនឹងលោក អៀង សារី។ អៀង សារី គឺជារដ្ឋមន្ត្រីការបរទេស។ អៀង សារី ទទួលខុសត្រូវលើការកំណត់ខ្មាំងនៅក្នុងក្រសួងការបរទេស និងកំណត់កម្មាភិបាលក្រសួងដែលត្រូវបញ្ជូនទៅការដ្ឋានលត់ដំ និងត្រូវកំណត់អ្នកដែលត្រូវចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១។ ការចូលរួមរបស់ អៀង សារី នៅក្នុងការងារទាំងនេះនឹងបង្ហាញតាមរយៈចម្លើយសាក្សី ព្រមទាំងឯកសារជាភស្តុតាង។ ក្នុងនាមប្រធានស-២១ ឌុច បានពន្យល់ថា ប្រធានមន្ទីរ ក្រសួងម្នាក់ៗ មានការពាក់ព័ន្ធនៅពេលកម្មាភិបាលរបស់ខ្លួនត្រូវបានឆ្លើយដាក់ថាជាជនក្បត់នៅក្នុងចម្លើយសារភាព ដែលបានទទួលបានដោយអ្នកសួរចម្លើយមន្ទីរស-២១។

[១០:៥៦:១៦]

ដំបូង ឌុច បញ្ជូនចម្លើយសារភាពទាំងនោះទៅ សុន សេន ឬ នួន ជា ដែលជនទាំងពីរនេះនឹងបញ្ជូនចម្លើយសារភាពទាំងអស់នោះ ឬបញ្ជីកម្មាភិបាលដែលត្រូវបានគេឆ្លើយដាក់ទៅប្រធានមន្ទីរក្រសួងដែលពាក់ព័ន្ធ។ សេចក្តីសម្រេចរួមលើបុគ្គលដែលត្រូវចាប់ខ្លួន នឹងធ្វើឡើងដោយ នួន ជា, សុន សេន និងគណៈអចិន្ត្រៃយ៍ រួមជាមួយនឹងប្រធានមន្ទីរ ក្រសួង ដែលពាក់ព័ន្ធនីមួយៗ។

យោងតាមក្រឹត្យក្រមអនុវត្តចម្លើយសារភាព ដែលឆ្លើយដាក់បន្ទុកកម្មាភិបាលក្រសួងការបរទេស ឬអតីតមន្ត្រីទូត ឬបុគ្គលដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ អៀង សារី រួមមានបញ្ញវន្ត ដែលវិលត្រឡប់ពីបរទេសមកវិញ។ ចម្លើយសារភាពទាំងអស់នោះ ត្រូវបញ្ជូនជាប្រចាំទៅ អៀង សារី ដើម្បីពិនិត្យឡើងវិញ និងផ្តល់យោបល់។

[១០:៥៧:២៧]

សាក្សីក្នុងពេលសវនាការ TCW564 នឹងបញ្ជាក់ថា អៀង សារី ពិតជាបានទទួលចម្លើយសារភាពពីមន្ទីរស-២១។ សក្ខីកម្មនេះស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសារភាពមួយចំនួនមកពីមន្ទីរ ស-២១ ដែលមានចំណារដោយផ្ទាល់ដៃ ដែលបញ្ជាក់ថា ផ្ញើជូនសមមិត្ត វ៉ាន់ ដែលជាឈ្មោះហៅក្រៅរបស់ អៀង សារី។ ដូចជាចម្លើយសារភាពរបស់អតីតឯកអគ្គរដ្ឋទូតប្រចាំប្រទេសឡាវឈ្មោះ មាយ ទូច។ គាត់បានចូលមកមន្ទីរស-២១ នៅថ្ងៃ២០ វិច្ឆិកា ១៩៧៧ ហើយត្រូវបានប្រហារជីវិតបួនខែក្រោយមក គឺនៅថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៨។ អតីតកម្មាភិបាលដទៃទៀតមកពីក្រសួងការបរទេសក៏នឹងឆ្លើយដាក់ អៀង សារី នៅក្នុងដំណើរការនេះដែរ។ អង្គជំនុំជម្រះនឹងបានស្តាប់ចម្លើយសាក្សី យ៉ាងហោចណាស់ពីរនាក់ដែរ ដែលត្រូវបានចោទប្រកាន់ថាជនក្បត់ ហើយត្រូវបាន អៀង សារី ណែនាំឲ្យសរសេរប្រវត្តិរូប។

[១០:៥៨:៤៦]

ប្រវត្តិរូបមួយក្នុងចំណោមកម្មាភិបាលទាំងពីរនេះ គឺសាក្សីសម្រាប់សវនាការ TCW724 ចាប់ផ្តើមជាមួយនឹងចម្លើយថា “សមមិត្តយើងដែលទទួលខុសត្រូវវាយការណ៍ថា ខ្មាំងវណ្ណៈរបស់យើងបានចោទប្រកាន់មករូបខ្ញុំ”។ សហព្រះរាជអាជ្ញានឹងសូមដាក់ចូលជាភស្តុតាងនូវប្រវត្តិរូបមួយច្បាប់នេះ ដែលជាភស្តុតាងប្រត្យក្សនៃការចូលរួមរបស់ អៀង សារី នៅក្នុងបញ្ហានានាដែលសម្រេចពីការស្លាប់រស់របស់កម្មាភិបាលនៅក្រោមឱវាទគាត់។

[១០:៥៩:២៩]

លោក លោកស្រី ក៏នឹងឮនៅក្នុងករណីនេះ ថាតើ អៀង សារី បានការពារការចាប់ខ្លួនបុគ្គលិករបស់គាត់ដោយរបៀបណា? គឺអ្នកដែលជាមិត្តភក្តិរបស់គាត់ ឬជាអ្នកដែលគាត់បានស្គាល់តាំងពីពេលដែលគាត់នៅជានិស្សិតនៅប្រទេសបារាំង។ ប្រសិនបើលោក លោកស្រីចៅក្រមទទួលស្គាល់ថា អៀង សារី បានព្យាយាមសង្គ្រោះអាយុជីវិតមនុស្ស នោះគឺជាបញ្ហាដែលគួរតែផ្តល់ការកោតសរសើរដល់រូបគាត់។ តែទន្ទឹមនឹងនេះសារៈសំខាន់ពិតនៃភស្តុតាងនេះ គឺថា អៀង សារី ពិតជាមានសិទ្ធិអំណាចត្រួតត្រាទៅលើអ្នកណាដែលត្រូវចាប់ខ្លួន និងអ្នកណាដែលមិនត្រូវចាប់ខ្លួន។

[១១:០០:១៦]

អង្គហេតុនេះបំបាត់ចោលនូវការមន្ទិលសង្ស័យ ដែលថាគាត់មានការទទួលខុសត្រូវចំពោះអតីតបុគ្គលិកអ្នកការទូត បញ្ញវន្ត ដែលវិលត្រឡប់មកប្រទេសវិញ សមាជិកគ្រួសារចំនួន២០០នាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួន និងកម្ទេចចោលនៅមន្ទីរស-២១។ ការអនុវត្តគោលនយោបាយកម្ចាត់ខ្មាំង

របស់បក្សកុម្មុយនីស្តកម្ពុជា នៅក្រសួងរបស់ អៀង សារី រាប់បញ្ចូលនូវការប្រជុំអប់រំនយោបាយ ដែលគាត់បានណែនាំបុគ្គលិករបស់គាត់ថា ការបោសសម្អាតផ្ទៃក្នុងចាំបាច់ត្រូវតែធ្វើដោយសារភ្នាក់ងារសម្ងាត់របស់ខ្មាំងកំពុងតែបង្កប់ខ្លួន និងការប្រជុំជីវភាពប្រចាំខែ ព្រមទាំងការប្រជុំស្វ័យទិតៀន ដែលគាត់បានដឹកនាំ ហើយដែលត្រូវបានធ្វើឡើង ដើម្បីកំណត់អត្តសញ្ញាណកម្មាភិបាល ដែលគេសង្ស័យនៅក្នុងក្រសួងនេះ។ ឯកសារផ្ទៃក្នុងបានលើកឡើងពីកិច្ចប្រជុំរបស់ក្រសួងក្នុងខែកញ្ញា ១៩៧៧ បង្ហាញថាពួកគេបានកម្ទេច និងបោសសម្អាតខ្មាំងដែលជា សេ.អ៊ី.អា, កា.ហ្សេ.បេ និង យួនលេបត្របាក់ទឹកដី និងសុំឲ្យប្រឹងប្រែងបន្តទៅទៀត ដើម្បីបោសសម្អាតខ្មាំងដែលនៅសេសសល់នៅក្នុងក្រសួងទាំងស្រុង។

[១១:០១:៤៩]

លោក លោកស្រីចៅក្រម ក៏នឹងបានស្តាប់ចម្លើយថាតើ អៀង សារី ទទួលខុសត្រូវ និងបានពង្រីកដល់កម្មាភិបាលដែលគេសង្ស័យមកពីទូទាំងប្រទេស ដែលត្រូវបានចាត់តាំងជាថ្មីឲ្យមកធ្វើការនៅក្រសួងការបរទេស ដែលជាមធ្យោបាយមួយរបស់ពួកគេមកកាន់ស-២១ ដោយរបៀបណានោះ។

អៀង សារី បានសារភាពថា គាត់ដឹងថា ក្រសួងរបស់គាត់ត្រូវបានប្រើប្រាស់ជាកន្លែងរក្សាទុកកម្មាភិបាលដែលគេបានសង្ស័យ ដោយសារតែតួនាទីរបស់គាត់ក្រសួងការបរទេសត្រូវបានគេហៅថាកន្លែងរង់ចាំសេចក្តីស្លាប់ ដោយអតីតកម្មាភិបាលម្នាក់ ហើយដូចដែលលោក លោកស្រីចៅក្រមនឹងបានស្តាប់ចម្លើយពីឌុច ការអនុវត្តនេះគឺជាការបង្ហាញឲ្យឃើញយ៉ាងគ្រប់គ្រាន់ថា នួន ជា បានប្រើពាក្យថាបញ្ជូនពួកគេឲ្យទៅធ្វើជាអ្នកទូត ដើម្បីជាលេសសម្រាប់ការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលទាំងនោះ។ ការដឹងឮរបស់ អៀង សារី អំពីការចាប់ខ្លួន និងការសម្លាប់ទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងចម្លើយពីមុនៗមួយចំនួនទៀតដែរ។ ឧទាហរណ៍ ក្នុងពេលថ្លែងសុន្ទរកថាមួយដល់សហគមន៍អ្នកការទូតនៅថ្ងៃ១៧ មេសា ១៩៧៧ គាត់បានប្រកាសថា ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា បានកម្ទេចគ្រប់ល្បិចកលរបស់ខ្មាំង និងបានកម្ចាត់ខ្សែបណ្តាញគិញ្ចរបស់ពួកវាទាំងអស់។

[១១:០៣:២៤]

ហើយនៅក្នុងកិច្ចសម្ភាសន៍មួយក្នុងខែមេសា ១៩៧៨ ជាមួយនឹងតំណាងនៃចលនាកុម្មុយនីស្តអាមេរិកម្នាក់ អៀង សារី បានរៀបរាប់ថាតើភ្នាក់ងារវៀតណាម និងភ្នាក់ងារ កា.ហ្សេ.បេ ដែលបានរៀបចំធ្វើរដ្ឋប្រហារប្រឆាំងនឹងពួកយើងត្រូវបានចាប់ខ្លួន ក្នុងខែមេសា និងខែកញ្ញា ៧៦ ដោយរបៀបណានោះ និងថាតើភ្នាក់ងារ សេ.អ៊ី.អា ដែលបានបន្លំខ្លួនធ្វើជាជនបដិវត្តន៍ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧០

ដូចរបៀបណានោះ។

លោក លោកស្រីចៅក្រមជាទីគោរព! លោក លោកស្រីចៅក្រមក៏នឹងបានដឹងថាតើតំណាងជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ថាតើនឹងការពារ ហើយបដិសេធការសម្លាប់ និងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដោយរបៀបណា នៅពេលដែលគេបានបញ្ជាក់ជូនមកគាត់ទាក់ទងទៅនឹងលិខិតឆ្លើយឆ្លងផ្លូវការមួយចំនួន។

របាយការណ៍មួយក្នុងចំណោមរបាយការណ៍ទាំងនេះ ត្រូវបានចេញនៅថ្ងៃទី១៤ ខែសីហា ១៩៧៨ អនុលោមទៅតាមសម័យប្រជុំលើកទី៣១ នៃអនុគណៈកម្មាធិការនៃក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីអំពីការការពារ និងការរើសអើង និងការការពារអប្បភាគជន គឺជាស្ថាប័នរបស់អង្គការសហប្រជាជាតិដែលមានរបាយការណ៍មួយពីរដ្ឋាភិបាលកាដាណា ផ្ញើជូនក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីឲ្យស៊ើបអង្កេតឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។

[១១:០៥:០១១]

រដ្ឋាភិបាលកាណាដាបានលើកឡើងថា ខ្ញុំសូមដកស្រង់សម្តី៖ "ចាប់តាំងពីខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុងមក បានអំពាវនាវថ្ងៃនេះថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យពិភពលោកទាំងមូលមានការរន្ធត់ញាប់ញ័រ និងបានដឹងពីប្រភពស៊ីសង្វាក់គ្នាផ្សេងៗថា មានអំពើប្រល័យពូជសាសន៍ដ៏គួរឲ្យរន្ធត់បានប្រព្រឹត្តទៅលើកុមារ ទារក ស្ត្រី បុរស ចំនួនពីរលាននាក់ អំពីការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ និងពីទីក្រុងកន្លែងដទៃទៀត ដោយមិនមានការលើកលែងចំពោះ និងអំពីការដែលថា រដ្ឋាភិបាលហៅខ្លួនឯងថា បក្សកុម្មុយនីស្តកម្ពុជានោះ ហើយបានប្រើកុមារឲ្យបាញ់សម្លាប់អ្នកដែលត្រូវគេប្រហារជីវិត"។

[១១:០៦:១១]

ដោយសារហេតុផលទាំងអស់នេះ មានការគាំទ្រដល់រដ្ឋសភាកាណាដាដែលបញ្ជាក់អំពី ដែលជាអំពើមួយអាក្រក់នៅក្នុងប្រវត្តិមនុស្សជាតិ និងស្នើសុំឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បញ្ឈប់ការបង្ហូរឈាមនោះជាបន្ទាន់ ហើយនាយករដ្ឋមន្ត្រី ប៉ុល ពត ឲ្យទទួលស្គាល់ជាបន្ទាន់នូវសេចក្តីសម្រេចដែលបានបោះឆ្នោតគាំទ្រដល់រដ្ឋាភិបាលកាណាដា នៅថ្ងៃទី៨ មីនា ១៩៧៨។

នៅក្នុងកិច្ចប្រជុំទី៥០ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ និងរដ្ឋាភិបាលទាំងអស់ដែលបានការពារទំនាក់ទំនងជាមួយរដ្ឋាភិបាល។ ជាការឆ្លើយតប របាយការណ៍នេះត្រូវបាន

ចេញនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨ អៀង សារី បានបញ្ជូនតេឡេក្រាមមួយ ដោយបានថាយើងសូមបដិសេធនូវសេចក្តីសម្រេចរបស់អនុគណៈកម្មការ ដែលបានជ្រៀតជ្រែកចូលដល់កិច្ចការផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ។ តាមរយៈសេចក្តីសម្រេចនេះ ការគាំទ្ររបស់អនុគណៈកម្មការ គឺគាំទ្រដល់សកម្មភាពរបស់ជនក្បត់ និងគាំទ្រដល់កលល្បិចរបស់ចក្រពត្តិអាមេរិក និងបក្សពួករបស់វា ដែលក្រោយពីប្រព្រឹត្តឧក្រិដ្ឋកម្មមិនអាចរាប់រែងបានប្រឆាំងប្រជាជនកម្ពុជា ហើយប្រជាជនជាងពីរលាននាក់ និងបានបំផ្លិចបំផ្លាញទឹកដីកម្ពុជាអស់៨០ភាគរយ និងបានបន្តបង្ខូចកេរ្តិ៍ឈ្មោះកម្ពុជាប្រជាធិបតេយ្យ ដើម្បីលុបបំបាត់ឧក្រិដ្ឋកម្មរបស់ខ្លួន។ ដូចមាននៅក្នុងពីពេលមុន ប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺថានឹងមិនទទួលស្គាល់នូវគ្រប់កលល្បិចឧក្រិដ្ឋកម្មរបស់ចក្រពត្តិ និងបក្សពួករបស់ពួកវា។ ពួកគេនឹងមិនយោគយល់ទៅដល់ មិនគាំទ្រដល់ទៅដល់អធិតេយ្យភាពរបស់កម្ពុជាឡើយ”។ សូមបញ្ចប់ការដកស្រង់។

[១១:០៨:៤៦]

នៅថ្ងៃទី១៣ ខែមិថុនា ១៩៧៨ អៀង សារី បានឆ្លើយតបទៅនឹងរបាយការណ៍ ដែលបានដាក់ជូនសម័យប្រជុំលើកទី៣១ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងកំណត់ហេតុមួយដែល អៀង សារី បានផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានចែកជូនទៅដល់អង្គការសហប្រជាជាតិ និងរដ្ឋភាគីសមាជិកទាំងអស់។ គាត់បានលើកឡើងថា ដកស្រង់សម្តី៖ “ម៉ាស៊ីនឃោសនារបស់ចក្រពត្តិ របស់ពួកវាតទីនិយម បានលើកឡើងនិងបានអំពាវនាវអំពីបញ្ហាសិទ្ធិមនុស្ស ដែលជាការបង្ខូចទៅដល់សេចក្តីថ្លៃថ្នូររបស់កម្ពុជាប្រជាធិបតេយ្យ។ ការបង្ខូចកេរ្តិ៍ឈ្មោះប្រឆាំងប្រជាជនកម្ពុជានេះ មិនមែនជារឿងថ្មីទេ ហើយមិនមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលដល់ប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះទេ”។

លោក លោកស្រីចៅក្រមជាទីគោរព! តាមរយៈរបាយការណ៍នេះ និងសេចក្តីថ្លែងការណ៍របស់ អៀង សារី ដែលបានធ្វើជូនទៅសហគមន៍អន្តរជាតិ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺបានបង្ហាញច្បាស់ហើយថា គាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងប្រទេសនេះ។

[១១:១០:១០]

បន្ទាប់នេះខ្ញុំសូមចូលលើអំពីបញ្ហា ខៀវ សំផន។ ក្នុងខណៈដែលមនុស្សគ្រប់រូបដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានដឹងអំពីការចាប់ខ្លួន និងការបាត់ខ្លួនមនុស្សភ្លាមៗនៅជុំវិញខ្លួន។ ខៀវ

សំផន បានបញ្ជាក់នៅក្នុងកំណត់ហេតុស្សួរចម្លើយរបស់គាត់ជូនសហចៅក្រមស៊ើបអង្កេតថា គាត់មិនបានអំពីចាប់ខ្លួនណាមួយនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយទើបតែបានដឹងអំពីបញ្ហានេះបន្ទាប់ពីខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រម នេះគឺជាការភូតកុហកដែលមិនអាចឲ្យជឿបាន និងត្រូវបានជំទាស់ដោយភស្តុតាងដ៏រឹងមាំដែលផ្ទុយពីការអះអាងនេះ។ ភស្តុតាងភាគច្រើនត្រូវបានពិភាក្សារួចមកហើយ មានកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី០៨ មីនា ៧៦ ដែលបានកត់ត្រាវត្តមានរបស់ ខៀវ សំផន នៅក្នុងការពិភាក្សាទាក់ទងទៅនឹងការចាប់ខ្លួនខ្មាំងនៅភូមិភាគឧត្តរ និងវិធានការដែលត្រូវធ្វើចំពោះអ្នកទាំងនោះ។

[១១:១១:២៨]

មានសារទូរលេខ និងរបាយការណ៍ជាច្រើនដែលបានបញ្ជូនមកឲ្យ ខៀវ សំផន នៅមន្ទីរ៨៧០ ដែលបានរៀបរាប់អំពីការចាប់ខ្លួន និងការស្សួរចម្លើយ និងការសម្លាប់។ ប៉ុន្តែនៅមានច្រើនទៀត ខៀវ សំផន បានទទួលស្គាល់ថា គាត់ និង សឿ វ៉ាស៊ី ហៅ ឌឿន គឺជាសមាជិកតែពីរនាក់គត់នៃមន្ទីរនយោបាយ៨៧០ និងត្រូវបានហៅថា គណៈកម្មាធិការមន្ទីរ៨៧០ ផងដែរ។ ដូចគ្នានឹង ខៀវ សំផន ដែរ ឌឿន គឺជាអ្នកចូលរួមប្រជុំទៀងទាត់នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ការទទួលខុសត្រូវនៃមន្ទីររបស់ពួកគេ គឺរួមមាន ការតាមដានការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងការបែងចែងរបស់របរសម្ភារៈទៅឲ្យអង្គភាពរបស់កម្ពុជាប្រជាធិបតេយ្យនៅទូទាំងប្រទេស។

[១១:១២:៣២]

សេចក្តីសម្រេចថ្ងៃទី៣០ មីនា ១៩៧៦ របស់គណៈមជ្ឈិមក៏បានធ្វើប្រតិភូកម្មអំណាចទៅឲ្យមន្ទីរគណៈមជ្ឈិមនូវអំណាចកម្ទេចប្រជាជននៅជុំវិញមន្ទីរមជ្ឈិមនេះ។ ចំណែកឯ ឌឿន ដែលជាប្រធានមន្ទីរនេះតាំងពីដើមមកត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ទុកឲ្យ ខៀវ សំផន នៅគ្រប់គ្រងមន្ទីរនេះតែឯង។

[១១:១៣:០៦]

លោក លោកស្រីចៅក្រមជាទីគោរព! នេះមិនអាចឲ្យជឿបានទេថា ខៀវ សំផន មិនបានដឹងអំពីការសម្លាប់ ឌឿន ដែលជាមិត្តភក្តិរួមមន្ទីររបស់គាត់នោះ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសុំឲ្យគាត់រៀបរាប់អំពីការបាត់ខ្លួនឈ្មោះ ឌឿន នៅក្នុងអំឡុងពីរឆ្នាំចុងក្រោយនៃរបបកម្ពុជាប្រជា

ធិបតេយ្យ ខៀវ សំផន គ្រាន់តែផ្តល់ការពន្យល់ថា ឌឿន បានធ្វើដំណើរជាញឹកញាប់តែប៉ុណ្ណោះ។ ហើយនៅពេលដែល ខៀវ សំផន លើកឡើងថា ការដាក់ជំនួស ឌឿន អាចជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ នោះគឺជាភស្តុតាងដែលបង្ហាញថា ប៉ង់ ក៏ត្រូវបានចាប់ខ្លួននឹងសម្លាប់នៅមន្ទីរស-២១ ដែលជាផ្នែកមួយនៃការបោសសម្អាតផ្ទៃក្នុងដែលបញ្ជាដោយមជ្ឈិមបក្ស។

លោក លោកស្រីចៅក្រមជាទីគោរព! ខៀវ សំផន មិនមែនគ្រាន់តែបានដឹងពីការចាប់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែសាក្សីម្នាក់បានរៀបរាប់ថា ខៀវ សំផន បានប្រាប់ដល់កម្មាភិបាលទាំងឡាយក្នុងវគ្គបំពាក់បំប៉ននយោបាយថា ប៉ង់ ត្រូវចាប់ខ្លួន ដោយសារតែវាជាគិញរៀតណាម។ ក្រោយពីដក ឌឿន មក ខៀវ សំផន មានតួនាទីគ្រប់គ្រងមួយពាក់ព័ន្ធជាមួយក្រសួងពាណិជ្ជកម្ម ដែលជាអង្គភាពមួយដែលត្រូវបានបោសសម្អាតយ៉ាងសាហាវបំផុត ដោយកម្មាភិបាលរាប់រយនាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១។ ការពាក់ព័ន្ធរបស់ ខៀវ សំផន និងការដឹងឮចំពោះការចាប់ខ្លួនទាំងនេះ គឺលើសពីវិមតិសង្ស័យ។ លោក លោកស្រី នឹងបានឃើញភស្តុតាងនៃការគ្រប់គ្រងដោយសកម្មនៅក្នុងក្រសួងពាណិជ្ជកម្ម។

[១១:១៥:០១]

កម្មាភិបាលក្រសួងពាណិជ្ជកម្មម្នាក់ដែលធ្វើការនៅឃ្លាំងសម្ភារៈនៅទួលទំពូង ក្នុងក្រុងភ្នំពេញ បានបញ្ជាក់ថា នៅក្នុងខែមករា ឆ្នាំ១៩៧៩ ខៀវ សំផន, នួន ជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មម្នាក់ឈ្មោះ វ៉ាន់ រិត បានមកកាន់ឃ្លាំងរបស់គាត់ និងបានប្រកាសផ្អាកការហៅឲ្យចូលរួមវគ្គរៀនសូត្រ ដែលកម្មាភិបាលទាំងអស់នោះ បានយល់ថាជាវិធីដំបូងដែលកម្មាភិបាលទាំងឡាយត្រូវបានគេហៅទៅចាប់ខ្លួនហើយ។ តាមរយៈភស្តុតាងនៃការចូលរួមយ៉ាងសកម្មរបស់ ខៀវ សំផន នៅក្នុងការអនុវត្តគោលនយោបាយកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា អង្គជំនុំជម្រះក៏នឹងបានស្តាប់សក្ខីកម្មសាក្សីTCW428 ដែលនឹងរៀបរាប់ពីការណែនាំដោយ ខៀវ សំផន ផ្ទាល់ទាក់ទងទៅនឹងសភាពការណ៍សន្តិសុខនៅក្នុងមន្ទីររបស់គាត់ រួមទាំងការចាប់ខ្លួននិងការដាក់ពន្ធនាគារខ្មាំងទាំងនោះ។

[១១:១៦:១០]

នៅពេលមួយ សាក្សីរូបនោះ បានជម្រាប ខៀវ សំផន ថាប្អូនថ្លៃប្រុសម្នាក់ និងប្អូនថ្លៃស្រីម្នាក់របស់គាត់ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខភូមិភាគឧត្តរ។ ខៀវ សំផន មិនមែនគ្រាន់តែបានដឹងអំពីការចាប់ខ្លួនសាច់ញាតិរបស់គាត់ប៉ុណ្ណោះទេ គាត់ក៏មានសិទ្ធិអំណាចធ្វើអន្តរាគមន៍ និងជួយឲ្យដោះលែងពួកគេទាំងនោះបានថែមទៀតផង។ ខៀវ សំផន បានយល់ព្រម និងបានផ្សព្វផ្សាយគោល

នយោបាយកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងឱកាសមួយចំនួន។ នៅដើមខែកញ្ញា ឆ្នាំ១៩៧៦ នៅក្នុងសន្និបាតនៅក្នុងប្រទេសកូឡុំបូ ប្រទេសមិនចូលបក្សសម្ព័ន្ធ នៅពេលដែលអ្នកកាសែតម្នាក់បានសួរគាត់ ទាក់ទងទៅនឹងភស្តុតាងនៃការស្លាប់ប្រជាជនរាប់រយរាប់ពាន់នាក់នៅក្នុងប្រទេសកម្ពុជា។ ខៀវ សំផន បញ្ជាក់ថា ការសម្លាប់នេះគឺសម្លាប់តែជនក្បត់ ហើយតើអ្នកឯងដែលជាពួកបស្ចិមប្រទេសម៉េចបានជាមានការព្រួយបារម្ភចំពោះពួកក្បត់នេះទៅវិញ។

[១១:១៧:១៧]

នៅក្នុងការសម្ភាសន៍ ខៀវ សំផន បានលើកនូវការគាំទ្រពេញលេញរបស់គាត់នៅក្នុងការបោសសម្អាតគណៈអចិន្ត្រៃយ៍ និងនៅក្នុងគណៈមជ្ឈិម ដោយបញ្ជាក់ថា មានប្រជាជនខ្មែរដែលជាភ្នាក់ងាររបស់យួនបង្កប់ខ្លួន ហើយនិងបានកាន់តួនាទីសំខាន់ៗ ហើយយើងបានដោះស្រាយជាមួយអ្នកទាំងអស់នេះរួចរាល់អស់ហើយនៅក្នុងឆ្នាំ១៩៧៧ និង៧៨។ ហើយនៅក្នុងសុន្ទរកថាឆ្នាំ១៩៧៧ ទៅកាន់មហាមិទ្ទីង ប្រារព្ធខួបលើកទីពីរនៃខួបជ័យជម្នះ១៧ មេសា ខៀវ សំផន បានទទូចឲ្យស្ដាប់ទាំងអស់ បន្តដកស្រង់សម្ដី៖ “ដាច់ខាតត្រូវតែបង្ក្រាបខ្មាំងគ្រប់ប្រភេទ ទប់ស្កាត់កុំពួកវាឲ្យប្រព្រឹត្តិអំពើឈ្លានពាន ឬអំពើចេស ឬវិទ្ធង្សនាប្រឆាំងនឹងយើង។ យើងត្រូវបោសសម្អាតខ្មាំងនៅក្នុងសមត្ថភាពរបស់យើងជាម្ចាស់សភាពការណ៍ អ្វីៗទាំងអស់ត្រូវតែបានធ្វើឲ្យជ្រះស្រឡះ និងហ្មត់ចត់បំផុត”។ យើងត្រូវតែបោសសម្អាតខ្មាំង ខៀវ សំផន បានទទូច ឲ្យបានស្អាត និងជ្រះស្រឡះ។ ដូចអ្នកដឹកនាំដទៃទៀត ដែលគាត់បានឃើញខ្មាំងនៅគ្រប់ទីកន្លែង សូម្បីតែជាក្នុងចំណោមមិត្តភក្តិយូរអង្វែងរបស់គាត់ ដូចជា ហ៊ូ នឹម ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ដែលចោទថាជាជនក្បត់ប៉ុន្មានថ្ងៃមុននោះ។

[១១:១៩:០០]

បន្ទាប់ទៅទៀត ខ្ញុំនឹងលើកឡើងអំពីបញ្ហា នួន ជា។ ការចូលរួមរបស់ នួន ជា នៅក្នុងការចាប់ខ្លួន និងការសម្លាប់ខ្មាំងក៏ត្រូវបានបង្ហាញឲ្យលើសពីការសង្ស័យ ដោយសារតែភស្តុតាងដ៏លើសលប់ដែលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះ។ ក្នុងនាមជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ទទួលបន្ទុកកិច្ចការបក្ស។ នួន ជា បានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការដាក់ពិន័យ និងការបោសសម្អាតកម្មាភិបាលរបស់បក្ស ក្នុងឋានៈជាសមាជិករបស់គណៈកម្មាធិការយោធាបក្ស គាត់បានចូលរួមពាក់ព័ន្ធនៅក្នុងបញ្ហាសន្តិសុខទូទាំងប្រទេស។ តួនាទីដែល នួន ជា បានបំពេញនៅមន្ទីរស-២១ និងជាចំណុចស្នូលនៅក្នុងសំណុំរឿងនេះ។ អៀង ធីរិទ្ធ បានអះអាងច្បាស់ហើយថា គាត់បានពិចារណាថា តើអ្នកណាជាអ្នក

ទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម និងការសម្លាប់សិស្សទាំងឡាយមកពីក្រសួងរបស់គាត់។

[១១:២០:១៤]

*(ការបង្ហាញឯកសារជារូបភាពវីដេអូ ចាប់ពីម៉ោង ១១:២០:១៤ ដល់ម៉ោង ១១:២១:១៦)*

ខ្ញុំបញ្ជាក់ច្បាស់ជូនលោក លោកស្រីចៅក្រមថា ប្រាំបីខែ គឺនៅថ្ងៃប្រាំបី គឺគាត់-- អ្នកជំនាញពីរនាក់បានប្រកាសថាគាត់មានសម្បទាគ្រប់គ្រាន់ចូលរួមក្នុងសវនាការបាន។

តួនាទីរបស់ នួន ជា នៅមន្ទីរស-២១ ក៏នឹងត្រូវបង្ហាញយ៉ាងស៊ីជម្រៅដោយអតីតប្រធាន ស-២១ ឈ្មោះ ឌុច។ គាត់នឹងរៀបរាប់អំពីការបញ្ជាដែលផ្តល់ដោយ នួន ជា ទាក់ទងទៅនឹងការចាប់ខ្លួន និងការសម្លាប់នៅស-២១ ។ ការបញ្ជាជាក់លាក់មួយចំនួនមកពី នួន ជា នោះគឺថា ឌុច នៅចាំ ដែលឌុច នៅចាំនោះរួមមានការសម្លាប់អ្នកទោសបីរយនាក់ពីភូមិភាគបូព៌ា។

[១១:២២:០៦]

នៅក្នុងការសម្លាប់ សហការីដែលជាសមាជិកមជ្ឈិមបក្សឈ្មោះ វន វ៉េត និងការសម្លាប់ជនបរទេសមួយក្រុមដែលឃុំខ្លួននៅមន្ទីរស-២១ ដែល នួន ជា បានបញ្ជាឲ្យដុតអ្នកទាំងនោះទាំងរស់ជាមួយនឹងកង់ ដោយប្រើប្រាស់កង់រថយន្ត។ ឌុច បានធ្វើប្រតិបត្តិការដោយអនុវត្តតាមបទបញ្ជាទូទៅដែលថា អ្នកទាំងឡាយណាដែលត្រូវបានបញ្ជូនទៅស-២១ ត្រូវតែសម្លាប់ចោលក្រោយពីសួរចម្លើយ និងក្រោយពីសារភាពរួចមក។ ឌុច ក៏នឹងផ្តល់សក្ខីកម្មផងដែរ ថាតើ នួន ជា បានក្លាយជាមេរបស់គាត់ផ្ទាល់ ដែលគាត់ត្រូវរាយកាណ៍ជូនក្នុងឆ្នាំ១៩៧៧ ដោយរបៀបណា? ក្រោយពីពេលដែល សុន សេន ត្រូវបានចាត់តាំងឲ្យទៅកាន់សមរភូមិនៅពេលដែលជម្លោះប្រដាប់អាវុធជាមួយវៀតណាមបានកើនឡើងដល់កំពូល។

[១១:២៣:០៧]

ចាប់តាំងពីថ្ងៃនោះមករហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានជួបជាមួយ នួន ជា រៀងរាល់ពីបីទៅប្រាំថ្ងៃម្តង ដើម្បីរាយការណ៍អំពីប្រតិបត្តិការណ៍នៅមន្ទីរស-២១ និងទទួលបទបញ្ជាបន្ថែម។ ឌុច បានរៀបរាប់ថាតើមុខងារសំខាន់បំផុតរបស់មន្ទីរស-២១ នោះ គឺផ្តល់ចម្លើយសារភាពទៅជូនគណៈមជ្ឈិមដែលក្រោយមកត្រូវប្រើដើម្បីធ្វើសេចក្តីសម្រេចក្នុងការចាប់ខ្លួន ដែលពាក់ព័ន្ធនៅក្នុងឯកសារនេះ។

[១១:២៣:៤៤]

ឌុច នឹងផ្តល់សក្ខីកម្មថា គាត់បានផ្ញើចម្លើយសារភាពទាំងអស់នេះទៅឲ្យ នួន ជា ហើយដោយក្រោយមក នួន ជា នឹងបញ្ជូនទៅឲ្យមេអង្គការ នៅអង្គភាពដែលពាក់ព័ន្ធ ដើម្បីធ្វើសេចក្តីសម្រេចរួមគ្នាថាតើអ្នកណាដែលត្រូវចាប់ខ្លួន? សក្ខីកម្មរបស់ ឌុច ទាក់ទងទៅនឹងដំណើរការចាប់ខ្លួននេះគឺ ស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មរបស់សាក្សីដទៃទៀត ក៏ដូចជាចម្លើយសារភាពពីសក្ខីកម្មទាំងនោះ។

សាក្សីសវនាការ TCW617 បានបញ្ជាក់ជូនសហចៅក្រមស៊ើបអង្កេតថា គាត់បានមកផ្ទះរបស់ ឌុច ដើម្បីទទួលចម្លើយសារភាពពីមន្ទីរស-២១ ហើយក្រោយមកបញ្ជូនឯកសារទាំងអស់នោះទៅឲ្យ នួន ជា ។

[១១:២៤:៣៨]

សហព្រះរាជអាជ្ញានឹងស្នើសុំឲ្យដាក់ឯកសារទាំងនេះ ជាភស្តុតាងនូវចម្លើយសារភាពជាងហាសិបដែលមានចំណារដោយ សុន សេន ឬក៏ ឌុច បញ្ជាក់ថាឯកសារនេះ បានផ្ញើជូនទៅ នួន ជា ឬក៏ដែលមានចំណារផ្ទាល់ដៃរបស់ នួន ជា។

ដូចដែល លោក លោកស្រីចៅក្រមនឹងឃើញតាមរយៈខ្សែវីដេអូនេះ ជនជាប់ចោទខ្លួនឯងផ្ទាល់បានសារភាពថា "គាត់ទទួលចម្លើយសារភាពយ៉ាងច្រើន ប៉ុន្តែគាត់មិនអាចអានចម្លើយសារភាពទាំងអស់នោះបានទេ"។

*(ការបង្ហាញឯកសារជារូបភាពវីដេអូ ចាប់ពីម៉ោង ១១:២៥:១៤ ដល់ម៉ោង ១១:២៦:៥៨)*

[១១:២៧:០០]

លោក លោកស្រីចៅក្រម ក៏នឹងបានឃើញនៅគ្របទឹកមុខនៃចម្លើយសារភាព ចំណារនៃចម្លើយសារភាពដែលបង្ហាញជូននូវមន្ទីរ អង្គការ នៃកម្មាភិបាលដែលពាក់ព័ន្ធនៅក្នុងចម្លើយសារភាពនេះ។ ចំណារទាំងនោះនឹងបង្ហាញជូននូវចម្លើយសារភាពដែលផ្ញើជូនទៅភូមិភាគ តំបន់ អង្គភាពយោធា និងក្រសួងនៅទូទាំងប្រទេស។ ហើយលោក លោកស្រីចៅក្រមក៏នឹងឮ បានស្តាប់សក្ខីកម្មពីកម្មាភិបាលភូមិភាគមួយចំនួនដែលបញ្ជាក់ថា គេបានទទួលចម្លើយសារភាពពីមជ្ឈិមបក្ស ហើយគេបានប្រើប្រាស់វា ដើម្បីចាប់ខ្លួនកម្មាភិបាលមូលដ្ឋាននៅក្នុងមូលដ្ឋានរបស់ពួកគេ។

[១១:២៧:៤៤]

ការដឹងឮ និងចេតនារបស់ នួន ជា ទាក់ទងទៅនឹងគោលនយោបាយកម្ទាត់ខ្មាំង គឺបង្ហាញបញ្ជាក់យ៉ាងច្បាស់ដោយចម្លើយសារភាពក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍៖ នៅក្នុងខែ

កក្កដា សុន្ទករថាក្នុងខែកក្កដា ១៩៧៨ ទៅកាន់ប្រតិភូមកពីប្រទេស មកពីបក្សកុម្មុយនីស្តដាណឺម៉ាក នួន ជា បានបញ្ជាក់ពីការខិតខំប្រឹងប្រែងរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីដោះស្រាយខ្មាំងផ្ទៃក្នុង។ ដកស្រង់សម្តី៖ “ចាប់តាំងពីថ្ងៃរំដោះមក បទពិសោធន៍របស់យើងទាក់ទងទៅនឹងសកម្មភាពប្រឆាំងនឹងបក្សដែលរៀបចំឡើងនៅក្នុងបក្សរបស់យើង ជាទូទៅគឺវាពាក់ព័ន្ធទៅនឹងពួក សេ.អ៊ី.អា ពួកភ្នាក់ងារវៀតណាម និងពួក កា.ហ្សេ.បេ។

បទពិសោធន៍របស់យើងនៅក្នុងវិស័យនេះ គឺបទពិសោធន៍យើងទើបមានថ្មីៗនេះ។ ប៉ុន្តែគឺយើងបានដឹងថា ស៊ី.អាយ.អេ និង កា.ហ្សេ.បេ និងភ្នាក់ងារ កេ.ហ្សេ.អា គឺបានកើតឡើងនៅក្នុងបក្សរបស់យើងយូរមកហើយ ទោះបីជាយើងបាននិយាយថា យើងបានកម្ទេចផែនការទាំងងនោះក៏ដោយ ក៏យើងមិនមានមធ្យោបាយគ្រប់គ្រាន់ ហើយក៏ខ្មាំងមិនបានបោះបង់ចោលនោះដែរ។ ហើយក្នុងនាមជាមេដឹកនាំដើម្បីចាប់ខ្លួនអ្នកដែលបានជ្រៀតចូលមកក្នុងបក្សរបស់យើង។

[១១:២៩:១០]

នៅក្នុងកិច្ចសម្ភាសន៍ឆ្នាំ២០០៥ នួន ជា បាននិយាយថាដកស្រង់សម្តី៖ “យើងសម្លាប់តែសមាសភាពមិនល្អតែប៉ុណ្ណោះ ហើយនិងថាហេតុផលដែលយើងបោសសម្អាតគឺ ដោយសារប្រជាជនខ្លះបានទទួលគ្រប់គ្រងថ្នាក់ស្រុក និងថ្នាក់ខេត្តគឺជាខ្មាំងរបស់យើង ពួកក្បត់ទាំងអស់នេះគឺមិនបានដើរតាមមាគ៌ានយោបាយរបស់យើងទេ”។

*(ការបង្ហាញឯកសារជារូបភាពវីដេអូ ចាប់ពីម៉ោង ១១:២៩:៣៨ ដល់ម៉ោង ១១:២៩:៥៧)*

[១១:៣០:០១]

ហើយនៅពេលដែលគាត់បង្ហាញខ្លួនដំបូងនៅចំពោះតុលាការនេះ នួន ជា បានលើកឡើងថា មាន សេ.អ៊ី.អា អាមេរិកាំង ភ្នាក់ងារ កា.ហ្សេ.បេ សូវៀត ខ្មែរសេរី និងភ្នាក់ងារសម្ងាត់វៀតណាមដែលបង្កប់ខ្លួនក្នុងបក្សរបស់យើង ក្នុងចំណោមប្រជាជពលរដ្ឋ និងនៅក្នុងសហករណ៍របស់យើង។ ហើយដែលអ្នកទាំងអស់នេះ បានបណ្តាលឲ្យធ្វើឲ្យមាគ៌ាបក្សនៅនិងខ្លោច ហើយនិងបានបំផ្លិចបំផ្លាញប្រទេស បក្ស និងប្រជាជនរបស់យើង។

ដូច្នេះលោក លោកស្រីចៅក្រមនឹងបានឃើញថាជនជាប់ចោទនីមួយៗបានដើរតួនៅក្នុងការបំភ្លៃ និងគោលនយោបាយប្រកបដោយកិច្ចកលរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅដល់អ្នកដែលគេយល់ថាសត្រូវ ហើយជាលទ្ធផលនៃការអនុវត្តគោលនយោបាយនេះ ប្រជាជនកម្ពុជារាប់រយពាន់នាក់ ហើយបាត់បង់

ជីវិត ហើយនេះគឺជាមូលហេតុចម្បងដែលមានតុលាការនេះនៅថ្ងៃនេះ។

[១១:៣១:០៩]

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់គោលនយោបាយបន្តទៅទៀត គឺចូលគោលនយោបាយទីបួន សហឧក្រិដ្ឋកម្មរួម ដែលមានគោលដៅចំពោះជនជាតិចាម ជនជាតិវៀតណាម និងព្រះពុទ្ធសាសនា។

នៅដើមឆ្នាំ១៩៧៥ លោក លោកស្រីចៅក្រម សហគមន៍កម្ពុជាមានលក្ខណៈស្មុគស្មាញ មានវប្បធម៌ចម្រុះ។ យោងទៅតាមការវិភាគបក្សកុម្មុយនីស្តកម្ពុជា កម្ពុជាគឺមានវណ្ណៈប្រជាជនច្រើនផ្សេងៗ រួមមាន សក្តិភូមិ គហបតី នាយទុន វណ្ណកាល លោកសង្ឃ បញ្ញវន្ត ដូចជាគ្រូបង្រៀន និងនិស្សិត ជាដើម នាយទាហាននិងកូនទាហាន លន់ នល់ កម្មករ កសិករស្តុកស្តម្ភ កសិករថ្នាក់កណ្តាល កសិករក្រីក្រ និងអប្បភាគជន ដូចជាជនជាតិភាគតិច ឡាវ ថៃ ចិន ចាម និងវៀតណាម។

[១១:៣២:២៤]

ជនជាប់ចោទបានសម្រេចថា ពួកគេនឹងនាំភាពចម្រុះនោះឲ្យឈានទៅដល់ទីបញ្ចប់ ដើម្បីឲ្យក្លាយជាសង្គមមួយដែលល្អឥតខ្ចោះ ដែលនឹងមានប្រភេទមនុស្សតែមួយ គឺប្រភេទវណ្ណៈកសិករ កម្មករ។

គោលនយោបាយដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើសាសនា និងទៅលើជនជាតិភាគតិចត្រូវបានរៀបចំឡើងដោយជនជាប់ចោទ និងមេដឹកនាំបក្សជាន់ខ្ពស់ដទៃទៀត នៅក្នុងកិច្ចប្រជុំដ៏តឹងតែងមួយដែលធ្វើឡើងនៅអយស្ម័យយានភ្នំពេញនៅខែមេសា និងឧសភា ឆ្នាំ១៩៧៥ ដូចជានៅស្ថានីយអយស្ម័យយាន និងនៅប្រាសាទព្រះកែវមរកត ដែលហៅថាប្រាសាទប្រាក់។ នួន ជា, អៀង សារី, ខៀវ សំផន ម្នាក់ៗបានចូលរួមនៅក្នុងកិច្ចប្រជុំបង្កើតនយោយបាយនេះ ដែល នួន ជា គឺជាមេដឹកនាំនៃក្រុមពិភាក្សា។

ដូចដែលលោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិបានលើកឡើងកាលពីម្សិលមិញ នូវសេចក្តីសម្រេចដែលធ្វើឡើងដោយជនជាប់ចោទនៅក្នុងកិច្ចប្រជុំនេះ គឺថាក៏ត្រូវបានបញ្ជូនទៅកាន់ភូមិភាគតំបន់ ស្រុក និងមេបញ្ជាការយោធានៅទូទាំងប្រទេស នៅក្នុងមហាសន្និបាត ដែលបានចាប់ផ្តើមពីថ្ងៃទី២០ ខែឧសភា ៧៥ និងបន្តអស់រយៈពេលប្រាំមួយថ្ងៃ។

ប៉ុល ពត, នួន ជា បានបង្ហាញនូវគោលនយោបាយដែលត្រូវយកទៅអនុវត្ត ដែល នួន ជា ជាអ្នកធ្វើបទឧទ្ទេសនាមច្រើនជាងគេបំផុត។ បន្ថែមទៅលើគោលនយោបាយស្តីអំពីសហករណ៍ និងខ្មាំងដូចដែលខ្ញុំបានពិភាក្សារួចមកហើយ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ការដឹកនាំជាក់លាក់ទាំងទៅ

លើសាសនា និងការគ្រប់គ្រងទៅលើជនជាតិភាគតិច។

[១១:៣៤:២៧]

ទាក់ទងនឹងព្រះពុទ្ធសាសនានេះ ប៉ុល ពត, នួន ជា បានណែនាំកម្មាភិបាលឲ្យបិទវត្តអារាមទាំងអស់ និងផ្សឹកព្រះសង្ឃទាំងអស់។ ពួកគេបាននិយាយថា ព្រះសង្ឃគឺជាវណ្ណៈពិសេស ដែលត្រូវតែបំបាត់ចោល ហើយពួកគេមិនត្រូវអនុញ្ញាតឲ្យមានវត្តអារាមទេ។ បន្ទាប់ពីការប្រជុំនេះ លេខាស្រុក លេខាតំបន់ បានត្រឡប់ទៅភូមិភាគរបស់គេវិញ និងបានប្រាប់កម្មាភិបាលមូលដ្ឋាន និងព្រះសង្ឃអំពីនយោបាយបក្ស ដែលតម្រូវឲ្យព្រះសង្ឃលាចាកសិក្ខាបទ និងចាកចេញពីវត្តអារាមរបស់ពួកគេ។

លោក លោកស្រីចៅក្រមជាទីគោរព! ព្រះសង្ឃរូបណាដែលមិនព្រម គឺត្រូវបានគេសម្លាប់។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានចាត់ទុកថា ព្រះសង្ឃគឺជាអបិយជំនឿផុតសម័យ ដែលផ្ទុយពីមាគ៌ាមនោគមវិជ្ជាបក្ស។ បក្សកុម្មុយនីស្តកម្ពុជាបានហៅព្រះសង្ឃថា ជាឈ្លើង ដង្កូវ ប៉ារ៉ាស៊ីតបឺតឈាម និងសក្តិភូមិ ជញ្ជក់ឈាមពីប្រជាជន និងដើម្បីធានាថា កុំឲ្យមានការសង្ស័យ គឺត្រូវលុបបំបាត់ព្រះពុទ្ធសាសនាពីប្រទេសកម្ពុជា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានប្តូរទីវត្តអារាម ដែលជាទីសន្តិភាព និងទីសក្ការបូជា ហើយប្តូរឲ្យទៅជាមន្ទីរសន្តិសុខសម្រាប់ធ្វើទារុណកម្ម និងប្រហារជីវិតមនុស្ស។

[១១:៣៦:២០]

ជាច្រើនទសវត្សរ៍មកហើយ ពុទ្ធសាសនា គឺជាមូលដ្ឋាននៃសង្គមរបស់កម្ពុជា ដែលបានផ្តល់អ្វីៗគ្រប់យ៉ាង ចាប់ពីគោលការណ៍សីលធម៌ ដែលនាំឲ្យសង្គមកម្ពុជារស់នៅជាមួយគ្នាបាន នៅក្នុងទីវត្តអារាម ដែលគេប្រមូលផ្តុំធ្វើពិធីបុណ្យក្នុងក្រុមគ្រួសាររបស់ពួកគេ។

ដូចដែលលោកចៅក្រមបានស្តាប់ពីសហសេវិករបស់ខ្ញុំ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបំផ្លាញខ្សែបណ្តាញឯកភាពនៃវប្បធម៌ ដែលបានក្លាយទៅជាជនរងគ្រោះនៃកម្មវិធីបំបាត់ និងបានកម្ទេចសង្គមចាស់ចោលទាំងស្រុង។

[១១:៣៧:០០]

នៅក្នុងកិច្ចប្រជុំមហាជនថ្ងៃទី២០ ដល់ទី២៥ នៃខែឧសភា ឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានផ្តល់ការណែនាំអំពីចាត់ចែងជនជាតិភាគតិចផងដែរ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានណែនាំពួកគេថាត្រូវជម្លៀសជនជាតិវៀតណាមចេញទាំងអស់ ដោយរាប់បញ្ចូនទាំង វៀតណាមដែលមានប្តីខ្មែរ។ ជាលទ្ធផលផ្ទាល់នៃការណែនាំពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា វៀតណាមប្រហែល

ជា១៥.០០០នាក់ ទៅ២០.០០០នាក់ ត្រូវបានបញ្ជូនចេញពីប្រទេសកម្ពុជានៅថ្ងៃទី-- ខែកញ្ញា ឆ្នាំ ១៩៧៥។ នៅក្នុងការប្រជុំខែឧសភា ឆ្នាំ១៩៧៥ នេះដែរ ឬក្រោយមក ប៉ុល ពត បានប្រាប់កម្មាភិបាល ថា ចាម ត្រូវហាមឃាត់មិនឲ្យប្រតិបត្តិសាសនា ហើយបង្ខំឲ្យចិញ្ចឹមជ្រូក ហើយនិងបរិភោគសាច់ជ្រូក បើអ្នកណាប្រឆាំងនឹងត្រូវស្លាប់ចោល។

[១១:៣៨:១៤]

លោក លោកស្រីចៅក្រមក៏បានស្តាប់អំពីលោកជំទាវ ជា លាង ទាក់ទងទៅនឹងអំពើឧក្រិដ្ឋដ៏គួរឲ្យរន្ធត់ដែលបានប្រព្រឹត្តលើជនជាតិចាម និងវៀតណាមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងភស្តុតាងដែលបង្ហាញថា នេះជាផ្នែកនៃផែនការប្រល័យពូជសាសន៍ ដែលបង្កើតឡើងដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ការញុះញង់របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ចេញផ្សាយក្នុងឆ្នាំ១៩៧៨ ដែលបានណែនាំឲ្យកម្ទេចវៀតណាមដែលនៅសេសសល់ទាំងអស់នៅក្នុងប្រទេស។ ហើយបញ្ជាឲ្យបញ្ឆេះភ្លើងកំហឹងជាតិ និងកំហឹងវណ្ណៈឲ្យបានឆាប់រហ័ស ដែលបានប្រែក្លាយទៅជាការជម្លៀសដ៏ធំធេង ដើម្បីកម្ទេច និងបោសសម្អាតឲ្យបានស្អាតនូវខ្មាំងយួន ដែលមានក្លិនអសោច និងអាក្រក់បំផុតនោះ។

[១១:៣៩:១៥]

នៅទីនេះខ្ញុំនឹងបញ្ជាក់បន្ថែមអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍។ ទីមួយ ខ្ញុំសូមអនុញ្ញាតលោក លោកស្រីចៅក្រមចាប់អារម្មណ៍ទៅលើឯកសារសំខាន់ៗពីររបស់សម័យកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញឲ្យហួសពីការសង្ស័យថា គឺមេដឹកនាំមជ្ឈិមបក្ស ដែលត្រួតត្រា និងដឹកនាំសកម្មភាពដែលបានអនុវត្តប្រឆាំងជនជាតិចាម និងពួកជនជាតិវៀតណាម។

ទីមួយ គឺជាទូរលេខចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៧៥ ដែលលេខាភូមិភាគបូព៌ាបានផ្ញើជូន ប៉ុល ពត និងចម្លងជូនទៅលោក នួន ជា។ និយាយពីការដកចាម៥ម៉ឺននាក់ចេញពីភូមិភាគបូព៌ា។ តួលេខនេះបានយោងជាក់លាក់ទៅរកការណែនាំរបស់អង្គការ ដែលបានណែនាំក្នុងកិច្ចប្រជុំកាលពីកិច្ចប្រជុំលើកមុននោះ។

ខ្ញុំសូមអនុញ្ញាតដកស្រង់៖ "ទស្សនៈដែលបានសម្រេចក្នុងអង្គប្រជុំថែងថា បងប្អូនខ្មែរអ៊ិស្លាម នឹងមិនត្រូវបានបញ្ជូនទៅខេត្តក្រចេះទេ ប៉ុន្តែភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ ត្រូវតែទទួលពួកគេ ដើម្បីបំបែកជនជាតិអ៊ិស្លាម ហើយនិងបំបែកពួកគេឲ្យចេញឆ្ងាយពីដងទន្លេមេគង្គ ដើម្បីបន្ធូរបន្ថយ

បរិយាកាស។ ជាគោលការណ៍ការប្តូរទីលំនៅ គឺការបំបែកពួកគេចេញពីគ្នាស្របតាមទស្សនៈរបស់មិត្ត ដែលសមមិត្តបានពិភាក្សាជាមួយយើងរួចហើយ"។ ចប់សេចក្តីដកស្រង់។

[១១:៤១:០៣]

ដូចគ្នានេះដែរនៅក្នុងរបាយការណ៍ថ្ងៃទី១៧ ឧសភា ឆ្នាំ១៩៧៨ លេខាភូមិភាគពាយ័ព្យបានស្នើសុំអ្វីដែលអង្គការ៨៧០បានសម្រេចថា ចាត់ការលើសមាសភាពយួនដែលមានប្តីខ្មែរ ខ្មែរដែលមានប្រពន្ធយួន ហើយនិងពួកខ្មែរកូនកាត់យួនខ្មែរ។ លោក លោកស្រីចៅក្រមបានជ្រាបនៅថ្ងៃនេះអំពីការអនុវត្តនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅស្វាយរៀងនិងព្រៃវែងនោះ ទាក់ទងទៅនឹងការប្រហារជីវិតជនជាតិដែលមានកូនកាត់ចម្រុះនោះ។ ដូចគ្នានេះដែរនៅឆ្នាំ១៩៧៨ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមញុះញង់កងទ័ពបដិវត្តន៍នូវពាក្យស្លោកថា "មួយទល់នឹងសាមសិប" ទីមួយ។ នយោបាយនេះត្រូវបានផ្សព្វផ្សាយជាឯកជនដោយផ្ទាល់ទៅកងទ័ពបដិវត្តន៍ បន្ទាប់មកបក្សកុម្មុយនីស្តកម្ពុជាបានផ្សព្វផ្សាយជាសាធារណៈតាមវិទ្យុរបស់ខ្លួន។ ខាងក្រោមនេះគឺជាសេចក្តីដង់ស្រង់ចេញពីការផ្សាយតាមវិទ្យុនោះ។

សូមដកស្រង់៖ "និយាយអំពីចំនួន យើងម្នាក់ត្រូវសម្លាប់វៀតណាម៣០នាក់។ ដូច្នេះ កងទ័ពពីរលាននាក់គឺគ្រប់គ្រាន់ដើម្បីប្រយុទ្ធជាមួយវៀតណាមបាន ពីព្រោះវៀតណាមមានប្រជាជនតែ៥០លាននាក់តែប៉ុណ្ណោះ យើងមិនត្រូវការកងទ័ព៨លាននាក់ទេ យើងត្រូវការទ័ពតែពីរលាននាក់ដើម្បីកម្ទេចប្រជាជនវៀតណាម៥០លាននាក់"។ ចប់សេចក្តីដកស្រង់។

[១១:៤២:៥០]

សេចក្តីថ្លែងការណ៍នេះ គឺជាសេចក្តីប្រកាសសាធារណៈរបស់ផែនការបក្សកុម្មុយនីស្តកម្ពុជាដើម្បីបំបាត់វៀតណាមទាំងអស់។ លោក ខៀវ សំផន បានប្រើសុន្ទរកថារបស់គាត់ដើម្បីញុះញង់បទប្រល័យពូជសាសន៍ប្រឆាំងនឹងពួកវៀតណាម ដោយរៀបរាប់ថា ពួកគេគឺជាខ្មាំងគ្មានតម្លៃ ជាខ្មាំងអន្តរជាតិ ហើយអំពាវនាវឲ្យមានការស្អប់ខ្ពើមទូទាំងប្រទេស។ អ្នកខ្លះអាចនឹងសួរថា តើការសម្លាប់រង្គាលជនជាតិវៀតណាម ឬក៏សហគមន៍ចាមជាប្រល័យពូជសាសន៍ឬ? ឬក៏ជាផែនការនៃផែនការបក្សកុម្មុយនីស្តកម្ពុជាដើម្បីកម្ទេចខ្មាំង? ចម្លើយគឺថា លោក លោកស្រីចៅក្រម គឺទាំងពីរនោះឯង។ ជាឧទាហរណ៍ ការសម្លាប់រង្គាលនូវជនជាតិចាម ដែលនៅសេសសល់នៅស្រុកកងមាសក្នុងឆ្នាំ១៩៧៧ បានធ្វើឡើងជាផ្នែកមួយនៃការបោសសម្អាតនៅភូមិភាគកណ្តាលទាំងស្រុង ដោយកងទ័ពបក្សកុម្មុយ-

នីស្តកម្ពុជា ដែលមកពីភូមិភាគនិរតី។

[១១:៤៣:៥៨]

នៅឆ្នាំបន្ទាប់នោះ នៅពេលដែលទ័ពនិរតីបន្តការបោសសម្អាតខ្មាំងរបស់គេ នៅភូមិភាគបូព៌ា ប្រជាជនចាមនៅក្រូចឆ្មារត្រូវបានគេសម្លាប់រង្គាល។ កម្មាភិបាលភូមិភាគកណ្តាលបាននិយាយអំពីវិធីសម្លាប់នោះថា មានការចូលរួមអន្តរាគមន៍ពីអង្គភាពពិសេសរបស់មជ្ឈិម តាមការបញ្ជារបស់សមាជិកគណៈអចិន្ត្រៃយ៍ សុន សេន។ ប៉ុន្តែ មិនមានអ្វីគួរឲ្យសង្ស័យទេនៅក្នុងការបោសសម្អាតនេះ គេមិនបានចាត់ទុកចាមដូចជាខ្មាំងផ្សេងៗទៀតនោះទេ។ បក្សកុម្មុយនីស្តកម្ពុជាមិនបានពិនិត្យប្រវត្តិរូបរបស់ចាមដើម្បីកំណត់ថា តើពួកគេស្ថិតនៅក្នុងវណ្ណៈដែលមានកំហុសដែរឬទេ។ ពួកគេមិនបានកម្រិតការចាប់ខ្លួនចាម ដែលគេបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់អ្នកដទៃនោះទេ។ នៅពេលពួកគេចាប់បានជនជាតិចាម ពួកគេមិនបានសួរចម្លើយ ដើម្បីកំណត់ថា ពួកគេជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ដើម្បីស្វែងរកខ្សែក្បត់របស់ពួកគេទេ។

ប្រជាជនចាមទាំងនោះ ត្រូវបានគេប្រមូលផ្តុំយកទៅវត្តអូរត្រកួន និងសម្លាប់ចោលភ្លាមៗ ដោយសារតែការណែនាំផ្ទាល់ពីបក្សកុម្មុយនីស្តកម្ពុជាដេលជាមេដឹកនាំ ដែលថាបើអ្នកជាចាមគឺអ្នកជាខ្មាំង គឺតែប៉ុណ្ណឹង។ នៅពេលដែលលោក លោកស្រីចៅក្រមបានស្តាប់សក្ខីកម្មរបស់អ្នករស់រានមានជីវិត ហើយនិងសាក្សី មិនមានអ្វីគួរឲ្យឆ្ងល់ទេ អំពើនេះគឺជាប្រល័យពូជសាសន៍។

នយោបាយចុងក្រោយទីប្រាំ គឺការរៀបចំអាពាហ៍ពិពាហ៍។ ការវាយប្រហាររបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅលើសេចក្តីថ្លៃថ្នូរបុគ្គល និងសេរីភាពរបស់កម្ពុជា បានចូលជ្រៅរហូតទៅដល់អំណាចក្នុងការសម្រេចថាតើអ្នកណាត្រូវរៀបការជាមួយអ្នកណា។ ស្ត្រីម្នាក់ឈ្មោះ ធុច ស៊ីថន គឺជាប្រធានឱសថនៅមន្ទីរក្រសួងសុខាភិបាល អនុរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ស៊ិន ផល្គុន ហៅ ស៊ូ បានណែនាំ ស៊ីថន ទៅឲ្យរៀបការជាមួយបុរសម្នាក់ឈ្មោះ ប៉ែន វ៉ាសែ។ ស៊ីថន មិនចង់រៀបការជាមួយ វ៉ាសែ ទេ ប៉ុន្តែ អៀង ធីរិទ្ធ បានបង្ខំគាត់ឲ្យធ្វើបែបនោះ។ ស៊ីថន បានព្យាយាមដើម្បីឲ្យអាពាហ៍ពិពាហ៍មានន័យ។ ភ្លាមៗនោះគាត់ក៏បានស្រឡាញ់ប្តីគាត់។ បន្ទាប់មកនៅចុងខែមីនា ឆ្នាំ១៩៧៨ នួន ជា បានបញ្ជាឲ្យគេចាប់ខ្លួនប្តីរបស់ ស៊ីថន។ អៀង ធីរិទ្ធ បានយល់ស្របជាមួយ នួន ជា ថាគាត់គឺជាខ្មាំង ហើយត្រូវតែដកចេញពីជួរបក្ស។

[១១:៤៧:០៩]

ពីរសប្តាហ៍ក្រោយមក អៀង ធីរិទ្ធ បានកោះហៅ ស៊ីថន ហើយអានឲ្យស្តាប់នូវចម្លើយសារភាពរបស់ វ៉ាសែ ពី ស-២១។ នៅពេល ស៊ីថន តវ៉ាថា គាត់មិនជឿថា ការចោទប្រកាន់ប្តីរបស់គាត់ទេនោះ អៀង ធីរិទ្ធ និយាយដោយកំហឹងថា ដោយសួរនាងថា “តើអ្នកឯងមិនជឿអង្គការទេឬ?”

នេះគឺជាទ្វេគ្រោះ ដែលមិនអាចធ្វើទៅបាន ដែលបង្ហាញម្តងហើយម្តងទៀតចំពោះពលរដ្ឋកម្ពុជាដោយសុបិនអាក្រក់នៃបក្សកុម្មុយនីស្តកម្ពុជានិយមកសិកម្ម។ តើអ្នកឯងជឿអ្នកណា? អ្នកជឿទុកចិត្តអង្គការ ឬអ្នកដែលអ្នកស្រឡាញ់? ចម្លើយគឺនឹងត្រូវស្លាប់ប្រសិនបើឆ្លើយខុស។ នេះជារូបថតមួយរបស់នារីក្មេងម្នាក់ឈ្មោះ ហួត បុប្ផាណា។ រូបថតនេះមិនបានបង្ហាញពីសេចក្តីអាណិតអាសូរគំរូដល់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:៤៨:១៧]

បុប្ផាណា ណាត្រូវបានសម្លាប់នៅ ស-២១។ អ្នកថតភាពយន្តដ៏មានកេរ្តិ៍ឈ្មោះ ឫទ្ធី ប៉ាន់ បានថតខ្សែភាពយន្តអំពីរឿងរបស់គាត់ ដែលមានចំណងជើងថា បុប្ផាណា សោកនាដកម្មកម្ពុជា។ ខ្សែភាពយន្តនោះត្រូវបានបញ្ចាំងជារៀងពីរដងក្នុងមួយថ្ងៃនៅសារមន្ទីរទួលស្លែង។

អ្នកសារព័ត៌មានដ៏ល្បី អេលីហ្សាប៊ែត បេកយ័រ ក៏បានសរសេរសៀវភៅមួយអំពីហួត បុប្ផាណាដែរដែលមានចំណងជើងថា “យើងរកឃើញ បុប្ផាណា”។ តើអ្វីជាបទឧក្រិដ្ឋ បទល្មើសដែលប្រព្រឹត្តឡើងដោយបុប្ផាណា ដែលគាត់រងការសួរចម្លើយ ទារុណកម្មច្រើនឆ្នាំនៅស-២១ បន្ទាប់មកវាយដោយដំបងឲ្យស្លាប់ដោយកម្មាភិបាលខ្មែរក្រហមនោះ?

[១១:៤៩:១០]

លោក លោកស្រីចៅក្រមជាទីគោរព! បទឧក្រិដ្ឋ បុប្ផាណា គឺជាការមានសេចក្តីស្នេហាដោយមិនមានការអនុញ្ញាតពីជនជាប់ចោទ។ ចំពោះបក្សកុម្មុយនីស្តកម្ពុជាសេចក្តីស្នេហាមិនត្រូវបានអនុញ្ញាតដោយអង្គការនោះគឺជាការខាតពេល ហើយគឺជាការក្បត់ចំពោះការស្រឡាញ់អង្គការបក្ស ហើយនិងត្រូវទទួលទោសដោយប្រហារជីវិត។

លោក លោកស្រីចៅក្រមជាទីគោរព! កាលពីម្សិលមិញ លោកជំទាវ ជា លាង បានពិពណ៌នាអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះជាការអនុវត្តនូវអាពាហ៍ពិពាហ៍ដោយបង្ខំដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ទូទាំងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលថានយោបាយនេះគឺមានការណែនាំពីជនជាប់ចោទ ហើយនិងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

ដែលបង្ហាញតាមរយៈសក្ខីកម្ម និងឯកសារភស្តុតាងយ៉ាងច្បាស់ជូនអង្គតុលាការ។

[១១:៥០:១៥]

ឥឡូវនេះខ្ញុំចូលដល់សេចក្តីសន្និដ្ឋាន។ លោក លោកស្រីចៅក្រម ជាគោលការណ៍តុលាការនេះត្រូវបានបង្កើតដើម្បីអនុវត្តវិធានការយុត្តិធម៌ជូនជនរងគ្រោះ ដែលពួកគាត់បានរង់ចាំជាច្រើនឆ្នាំមកហើយ។ ប៉ុន្តែខ្ញុំក៏សូមអនុញ្ញាត សូមលោក លោកស្រីចៅក្រម ដោយគោរពដោយឲ្យពិនិត្យមើលតួនាទីនៅទីនេះក្នុងឋានៈទូលំទូលាយ។ សតវត្សរ៍ទី២០នេះ គឺជាសតវត្សរ៍បង្ហូរឈាមខ្លាំងបំផុតនៃប្រវត្តិសាស្ត្រមនុស្សលោក។ ជនរងគ្រោះ១៥០លាននាក់ កុមារ ស្ត្រី ហើយនិងបុរសត្រូវបានបំផ្លាញទូទាំងពិភពលោក ភាគច្រើនជាជនរងគ្រោះនៃសង្គ្រាម អំពើភេរវកម្ម មិនទាន់បានទទួលយុត្តិធម៌ទេ។ ប៉ុន្តែនៅកម្ពុជានេះ ឱកាសដ៏ពិសេសមួយបានត្រូវផ្តល់ដើម្បីលើកឡើងអំពីបញ្ហានិទណ្ឌភាពដែលស្ថិតនៅ៣០ឆ្នាំមកហើយ ដើម្បីកំណត់នូវឧទាហរណ៍ដ៏មានកម្លាំងមួយ ហើយបង្ហាញអំពីការប្រមានដ៏រឹងមាំពីអតីតកាលទៅអនាគតថា មនុស្សលោកគ្រប់ទីកន្លែងត្រូវគោរពរស់នៅដោយសន្តិភាពក្នុងច្បាប់។ ជាពិសេសការជំនុំជម្រះនេះ គឺការបញ្ជាក់ឡើងវិញនូវការបដិសេធដ៏ដាច់ខាតរបស់មនុស្សថាមិនទទួលនូវលទ្ធភាពដ៏គួរឲ្យស្អប់ខ្ពើមនៃមនុស្សពីជំនាន់មួយទៅជំនាន់មួយ។

[១១:៥១:៥៣]

តុលាការនេះ មិនអាចនឹងសន្និដ្ឋានសុក្រឹតភាព១០០ភាគរយនោះទេ។ យើងមានការព្យាយាមដោយបន្ទុកមួយចំនួន ប៉ុន្តែជាឧបករណ៍តែមួយគត់ដែលយើងមាន ដើម្បីដោះស្រាយបទឧក្រិដ្ឋដ៏ធំធេងគួរឲ្យរន្ធត់ដែលគំរាមកំហែងចំណងដ៏ផុយស្រួយដែលផ្សាភ្ជាប់មនុស្សលោក និងស្វែងរកការដាក់ទណ្ឌកម្មច្បាប់ចំពោះជនទាំងបីរូបនេះ។ យើងមិនជំទាស់ទេថារដ្ឋ បុគ្គលទាំងឡាយខាងក្រៅកម្ពុជាបានចូលរួមក្នុងអ្វីដែលបានកើតឡើងមុន និងក្នុងអំឡុងពេលសម័យស្លាប់រស់របស់កម្ពុជាប្រជាធិបតេយ្យ ១៩៧៥ និង៧៩នោះ។ ប៉ុន្តែការចូលរួមខាងក្រៅនេះ មិនមែនដោះបន្ទុកពីជនជាប់ចោទទាំងបីរូបចំពោះមុខតុលាការនេះទេ ពីអ្វីដែលគេបានធ្វើនោះ។ វាមិនមែនជាការដោះសារពីអ្វីៗដែលពួកគាត់បានប្រព្រឹត្តនោះឡើយទេ។

[១១:៥២:៥៨]

នៅឃុំរលួស ខេត្តសៀមរាប ហើយនិងប្រាសាទបាគង ជាទីកន្លែងមួយគឺគេបានកសាងសាលារៀន មន្ទីរប្រជុំ បណ្ណាល័យបន្ទប់កុំព្យូទ័រកំពុងតែសាងសង់ ហើយដែលនឹងផ្តល់ឱកាសឲ្យកុមារក្រីក្រ

នៅក្នុងខេត្តសៀមរាប នូវការអប់រំមួយដែលគេត្រូវការ ដែលផ្តល់ឲ្យពួកគេនូវឱកាសដែលយើងចង់បាន ក្នុងឋានៈជាមនុស្សលោកនោះ។ ទីកន្លែងនេះ វិទ្យាល័យបច្ចេកទេសបាគង្គ គឺជាទស្សនៈរបស់បុរសម្នាក់ឈ្មោះ វ៉ាណាជិត យឹមស៊ុត រ៉ូនី ហើយនិងមិត្តភក្តិជាច្រើនរបស់គាត់។ យឹមស៊ុត មានមនោសញ្ចេតនាយ៉ាងពិសេសនៅសៀមរាប។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ គ្រួសារ ទាំងមូលរបស់គាត់ បុរស ស្ត្រី កុមារ ជីដូនជីតា មីងមា ហើយនិងបងប្អូនជីដូនមួយ ក្នុងចំណោមប្រជាជនថ្មី៧៩នាក់ត្រូវបានបណ្តើរទៅមាត់ទន្លេមួយ មាត់បឹងមួយដោយកម្មាភិបាលបក្ស ហើយក៏បានវាយសម្លាប់ ហើយកប់ក្នុងរណ្តៅភក់នៅទីនោះទៅ។

[១១:៥៤:៣១]

យឹមស៊ុត គឺជាមនុស្សដែលបានរួចរស់ពីហេតុការណ៍នោះ ថ្ងៃនេះនៅមាត់បឹងដដែលនេះ គាត់បានកសាងសាកលវិទ្យាល័យមួយជាកន្លែងមួយល្អ ជាអំពើដ៏ល្អ កិត្តិយស និងបន្តជារៀងរហូត។ រវាងមនុស្ស១.៧លាន ទៅ២.២លាននាក់ បានស្លាប់មុនអាយុក្នុងសម័យកាល៣ឆ្នាំ៨ខែ២០ថ្ងៃ ដែលជនជាប់ចោទទាំងបីនាក់បានគ្រប់គ្រង។

នេះជាការបាត់បង់ស្មារតី ទេពកោសល្យ និងសក្តានុពលមនុស្សដ៏ធំធេង។ បញ្ញវន្ត វេជ្ជបណ្ឌិត គ្រូវះកាត់ ស្ត្រីបុរសទាំងឡាយជាអាជីវករ មេដឹកនាំសាសនា នេះគឺជាវដ្តនៃសេចក្តីស្លាប់ដ៏គ្មានទីបញ្ចប់ តើមានមន្ទីរពេទ្យ សកលវិទ្យាល័យប៉ុន្មានដែលមិនបានសាងសង? តើគេគួរសង្គ្រោះជីវិតមនុស្សប៉ុន្មាន? តើកុមារប៉ុន្មាន ដែលមិនបានទទួលការអប់រំ? ចំណុចនេះគឺមិនអាចធ្វើឲ្យបុគ្គលណាម្នាក់ដែលថាប្រទេសនេះកំពុងតែតស៊ូរហូតមកដល់ថ្ងៃនេះ ហេតុអ្វី? ដោយសារថាជនជាប់ចោទចំពោះមុខលោកនេះ គឺជាចោរប្លន់ពេលវេលា និងជាឃាតកនៃជនជាតិខ្មែរមួយជំនាន់។ ពួកគេបានប្លន់ការអភិវឌ្ឍច្រើនទសវត្សរ៍ និងភាពរុងរឿងចេញពីប្រទេសនេះ។ ពួកគេបានបន្សល់ទុកចន្លោះប្រហោងគ្រប់គ្រួសារទាំងអស់។ ពួកគេបានផ្តាច់ដង្ហើមពីសញ្ញាណជាតិនានា ដូចជាអាកប្បកិរិយាអរិយធម៌ផ្សេងៗ។

មិនមានអ្នកណាម្នាក់នៅក្នុងប្រទេសនេះ ដែលមិនរងការឈឺចាប់ ឬកបាត់បង់សមាជិកគ្រួសារពីអំពើរបស់ពួកគេគាត់នោះឡើយ។

[១១:៥៦:៣១]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! សាលក្រមរបស់អស់លោកត្រូវចារក្នុងប្រវត្តិសាស្ត្រច្បាប់ និងប្រវត្តិសាស្ត្រតុលាការ និងអាណត្តិរបស់តុលាការនេះផង។ តុលាការត្រូវតែ

សម្រេចអំពីបិសាច អំពើបិសាចដែលបុរសទាំងបីនាក់នេះបានប្រព្រឹត្ត។ ការិយាល័យសហព្រះរាជអាជ្ញាជឿជាក់យ៉ាងច្បាស់ថា យើងនឹងបង្ហាញភស្តុតាងថាជនទាំងបីនាក់នេះ មានពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យ។ យើងនឹងរកឃើញយុត្តិធម៍សម្រាប់ជូនជនរងគ្រោះពីរលាននាក់ ហើយការឈឺចាប់ និងការស្លាប់របស់ពួកគេនឹងមិនក្លាយទៅជាអត់ន័យចំពោះការអភិវឌ្ឍនៃមនុស្សលោកទៀតឡើយ។

សូមអរគុណ លោកប្រធាន។ សូមអរគុណ លោក លោកស្រីចៅក្រម។

[១១:៥៧:២៨]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ សហព្រះរាជអាជ្ញា។ សូមអញ្ជើញមេធាវី!

**លោក ពេជ អង្គ៖**

លោកចៅក្រមប្រធាន! សូមគោរព លោក លោកស្រីចៅក្រម។ ខ្ញុំមានចំណុចពីរចង់លើកពេលនេះ។

ចំណុចទីមួយ ចង់សុំឲ្យលោកចៅក្រមប្រធាន ជួយបញ្ជាក់ថាតើពេលណាដែលលោកចៅក្រមប្រធានអនុញ្ញាតឲ្យខ្ញុំបាទជាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពីមេធាវីចំនួនបីរូបដើម្បីជូនលោកចៅក្រមប្រធានទទួលសិទ្ធិរបស់គាត់ ដើម្បីមានសិទ្ធិពេញលេញជាមេធាវីនៅពេលនេះទីមួយ។

ទីពីរ គឺពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងបើកសវនាការនេះ វាជាឱកាសជាប្រវត្តិសាស្ត្រមួយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះដទៃទៀត។ ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសដ៏ល្អនេះដែលត្រូវបានវិធានផ្ទៃក្នុងនេះ អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងនីតិវិធីតុលាការ។ ក៏ប៉ុន្តែនៅក្នុងឱកាសកម្មវិធីបើកសវនាការនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានសិទ្ធិនៅក្នុងការធ្វើផ្តល់មតិមួយចំនួនទេ ហើយក្នុងឱកាសនេះ ខ្ញុំបាទសូមស្នើសុំលោកចៅក្រមប្រធាន ក៏ដូចជាលោក លោកស្រីទាំងអស់ សាថ្មីដើម្បីឲ្យធ្វើការពិចារណាម្តងទៀត ដើម្បីឲ្យខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកអំពីមតិយោបល់មួយចំនួន។

[១១:៥៩:០២]

រយៈពេល១៥ ឬក៏៣០នាទី រយៈពេលនេះមិនជាច្រើនទេ ក៏ប៉ុន្តែសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីវាមានតម្លៃណាស់ ដែលដើមបណ្តឹងរដ្ឋប្បវេណីមានសំឡេងនៅក្នុងពេល-- ដែលជាប្រវត្តិសាស្ត្រដែល

ជាការបើកសវនាការក្នុងករណី០០២ នេះ ដែលដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះបានរង់ចាំរយៈពេល៣២ឆ្នាំ កន្លងមកនេះ។

សូមលោកចៅក្រមប្រធាន មេត្តាពិចារណាពីករណីនេះ។ សូមអរគុណ។

[១១:៥៩:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ ហើយចំពោះបញ្ហាទីមួយ ដោយពេលវេលាមានកំណត់ ហើយកាលដែលរអាក់រអួលកាលពីម្សិលមិញ ដោយមូលហេតុសំឡេងនោះ។ ឥឡូវនេះ ពេលវេលាដែលបានគ្រោងទុកគឺពេលវេលាសម្រាប់ភាគីសហព្រះរាអាជ្ញា ហើយនិងភាគីដទៃទៀត។ ដូច្នេះទេ ដោយស្ថានភាពមិនទាន់ភាពចាំបាច់នៃការដែលឡើងអាចទទួលសិទ្ធិក្នុងការឡើងផ្តល់មតិយោបល់ ឬក៏សួរសំណួរផ្សេងៗនោះអង្គជំនុំជម្រះបានពិចារណាថា គួរតែត្រូវបានធ្វើការបង្ហាញចំពោះមេធាវីទាំងបីរូប ឬក៏មេធាវីផ្សេងទៀតនៃមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនទាន់បានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនោះគឺនៅចុងនៃកិច្ចដំណើរការសវនាការនេះ។ នេះគឺជាពេលវេលាសមស្របដែលយើងបានពិចារណារួចហើយ។

បញ្ហាទីពីរ អំពីសំណើសុំដែលមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដោយផ្ទាល់មាត់នៅពេលនេះ ទំនងជាមិនខុសគ្នាពីសំណើសុំដែលបានធ្វើរួចមកហើយទេ។ ដើម្បីឲ្យកាន់តែច្បាស់លាស់ទាំងមេធាវី ទាំងសាធារណជន និងភាគីនៅពេលនេះ អនុវត្តតាមវិធាន៨៩ស្ទួន អនុវិធាន២ នៃវិធានផ្ទៃក្នុងដែលចែងអំពីសវនាការលើអង្គសេចក្តីថា នៅមុនពេលសួរចម្លើយជនជាប់ចោទ សហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីបទចោទប្រកាន់ ប្រឆាំងចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬមេធាវីជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន។

[១២:០១:៣១]

ខ្លឹមសារនៃបទបញ្ញត្តិវិធាន៨៩ ស្ទួនពីរ ដែលអង្គជំនុំជម្រះយកមកអនុវត្តនៅពេលនេះពុំមានកំណត់អំពីសិទ្ធិរបស់មេធាវីនាំរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ឬក៏កត់សម្គាល់អ្វីផ្សេងនោះឡើយ។

ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងឯកសារលេខ E131 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ របស់ខ្លួនស្តីពីដីកាកំណត់ការបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និង

សវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២ ថា អនុលោមតាមវិធាន៨៩ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហមេធាវីនាំមុខ ឬចម្លើយតបណាមួយទៅនឹងសេចក្តីសន្និដ្ឋានផ្សេងៗនឹងពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើ ឬលើកយកមកពិនិត្យពិចារណាឡើយ។

[១២:០២:៤១]

៣) ផ្អែកលើសំណើជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សំណើសុំដូចគ្នានេះមកអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានឆ្លើយតបរួចហើយតាមលិខិតលេខE131/4/1 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ថាអង្គជំនុំជម្រះសូមបញ្ជាក់ថា ពុំមានមូលដ្ឋានគតិយុត្តណាមួយក្នុងក្របខ័ណ្ឌគតិយុត្តនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើតាមសំណើរបស់ខ្លួនឡើយ ទោះបីក្នុងរូបភាពណាក៏ដោយ។

[១២:០៣:២៥]

អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធនូវសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ។

ឥឡូវនេះ ដល់ពេលត្រូវសម្រាកពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់។ ហើយចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់បីនិងសាមសិបនាទី បុគ្គល ភាគី និងសាធារណជនសូមអញ្ជើញចូលមកកាន់ទីកន្លែងរៀងៗខ្លួនវិញឲ្យបានមុនម៉ោងដប់បីនិងសាមសិបនាទីនេះ ដើម្បីបន្តកិច្ចដំណើរការនីតិវិធី។

អ៊ីចឹង សូមអញ្ជើញសម្រាកចុះ! ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅបន្ទប់រង់ចាំ ហើយនិងឲ្យនាំគាត់មកកាន់សាលាសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងដប់បី និងសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១នាទី )*

[១៣:៣១:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

កិច្ចដំណើរការឡើងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេប ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាបានបញ្ចប់សព្វគ្រប់ហើយ។ ឥឡូវនេះដល់ពេលដែលអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅជនជាប់ចោទ និងមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ដើម្បីមានឱកាសឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបរបស់សហព្រះរាជអាជ្ញា។

អង្គជំនុំជម្រះសូមជម្រាបជនជាប់ចោទនិងមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមថា នាពេលនេះអនុលោមតាមវិធាន៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុងជនជាប់ចោទ ឬ/និង មេធាវីការពារក្តីជនជាប់ចោទអាចឡើងធ្វើសេចក្តីថ្លែងការណ៍ សេចក្តីសន្និដ្ឋានឆ្លើយតបដោយសង្ខេប ទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់លើរឿងក្តី០០២ទាំងមូល ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា។

[១៣:៣២:៣០]

អង្គជំនុំជម្រះផ្តល់ជូននូវថិរវេលាកន្លះថ្ងៃសម្រាប់ជនជាប់ចោទម្នាក់ៗ រួមនិងក្រុមមេធាវីរបស់ខ្លួន សម្រាប់ការធ្វើឆ្លើយតបដោយសង្ខេបនេះ ដោយចាប់ផ្តើមពីជនជាប់ចោទ នួន ជា និងក្រុមមេធាវីការពារក្តីរបស់ នួន ជា មុនគេ និងបន្ទាប់មក ជនជាប់ចោទ អៀង សារី និងក្រុមមេធាវីការពារក្តីរបស់គាត់ និងចុងក្រោយជនជាប់ចោទ ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់គាត់។

ហើយជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅជនជាប់ចោទ នួន ជា ហើយនិងមេធាវីការពារក្តីរបស់ នួន ជា។ ហើយអង្គជំនុំជម្រះសូមជម្រាបផងដែរថា ប្រសិនបើលោក នួន ជា មានបំណងនឹងការធ្វើការឆ្លើយតបដោយសង្ខេបទៅនឹងការចោទប្រកាន់នោះ អង្គជំនុំជម្រះអនុញ្ញាតដោយអនុញ្ញាតឲ្យគាត់អាចអង្គុយនិយាយបាន ដោយសារវ័យចាស់។ សូមអញ្ជើញ!

[១៣:៣៣:៤៤]

**លោក ម៉ៃខល ផេសមិនៈ**

លោកចៅក្រមខ្ញុំសូមធ្វើ លើកឡើងការណែនាំសេចក្តីផ្តើម ជាដំបូងសិន។ សេចក្តីបើកនេះគឺធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល ជាបឋម ខ្ញុំស្នើសុំទៅដល់អង្គសវនាការថា ឬក៏ស្នើសុំតុលាការថា តើយើងអាចបំបែកការឆ្លើយតបសេចក្តីសន្និដ្ឋានបើករបស់ខ្ញុំជាពីរផ្នែកដែរឬទេ? ជាបឋមគឺខ្ញុំអ្នកធ្វើសេចក្តីសន្និដ្ឋាន ហើយខ្ញុំចង់ឲ្យកូនក្តីរបស់ខ្ញុំធ្វើការឆ្លើយតបផងដែរ។

[១៣:៣៤:២៧]

ដូច្នេះសេចក្តីសន្និដ្ឋាននោះ គឺអាចចំណាយពេល រយៈពេលពីរម៉ោង តែយ៉ាងណាក៏ដោយនៅក្នុង

អំឡុងពេលពីរម៉ោងនេះ ខ្ញុំសូមឲ្យមានការសម្រាករយៈពេលម្ភៃនាទី ក្នុងអំឡុងពេលរយៈពេលពីរម៉ោងនោះ ដោយសារវាមានការពិបាកសម្រាប់គាត់។ ហើយប្រសិនបើអាចនោះ គឺខ្ញុំជាមួយនឹងមេធាវី សុន អរុណ គឺយើងខ្ញុំនឹងលើកឡើងសេចក្តីសន្និដ្ឋានឆ្លើយតបនៅថ្ងៃស្អែកព្រឹក ដោយសារតែនៅក្នុងថ្ងៃនេះ យើងមិនទាន់បានពិភាក្សាសេចក្តីសន្និដ្ឋានបើក ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ជាមួយនឹងកូនក្តីរបស់ខ្ញុំនៅឡើយទេ។ ដូច្នេះ ខ្ញុំសូមថា យើងខ្ញុំធ្វើនៅថ្ងៃស្អែក។ ហើយបញ្ហាបច្ចេកទេស ដែលខ្ញុំឆ្លើយតបនោះ ក៏ខ្ញុំត្រូវការរៀបចំដើម្បីផ្តល់ជូនអ្នកបកប្រែផងដែរ។

[១៣:៣៦:៥៤]

**ប្រធានអង្គជំនុំ៖**

ឆ្លើយតបនឹងអ្វីដែលលោកមេធាវីបានធ្វើការ ហាក់ដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅក្នុងបន្ទប់សវនាការ នេះនោះ អង្គជំនុំជម្រះបញ្ជាក់សាជាថ្មីម្តងទៀត ដើម្បីឲ្យយល់ច្បាស់ថា លោកមេធាវីការពារក្តី រួមទាំងកូនក្តីរបស់លោក គឺ នួន ជា មានពេលវេលាកន្លះថ្ងៃនៅក្នុងការធ្វើសេចក្តីថ្លែងការណ៍តបដោយសង្ខេបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដោយអនុវត្តតាមវិធាន៨៩ស្ទួនពីរ អនុវិធាន២ នៃវិធានផ្ទៃក្នុង។

ទីពីរ យើងរំឭក និងប្រាប់លោកសាជាថ្មីម្តងទៀត ដើម្បីឲ្យបានយល់ច្បាស់ថា នៅក្នុងដីកាកំណត់កាលបរិច្ឆេទ ធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ឯកសារ E131 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះបានកំណត់នៅក្នុងផ្នែកដែលពាក់ព័ន្ធនេះ។ ដូច្នេះ អនុលោមតាមវិធាន៨៩ស្ទួន នៃវិធានផ្ទៃក្នុង ជនជាប់ចោទម្នាក់ៗ ឬមេធាវីរបស់ជនជាប់ចោទរូបនោះ នឹងមានឱកាសធ្វើការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។

[១៣:៣៨:៣១]

អង្គជំនុំជម្រះសាលាដំបូងទុកពេលវេលាចំនួនកន្លះថ្ងៃ សម្រាប់ឲ្យក្រុមមេធាវីការពារក្តីនីមួយៗធ្វើសេចក្តីសន្និដ្ឋានតប។ ប្រសិនបើជនជាប់ចោទមានបំណងធ្វើសេចក្តីសន្និដ្ឋានណាមួយក្នុងអំឡុងពេលនេះ ការធ្វើសេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទរូបនោះ គឺជាផ្នែកមួយនៃពេលវេលាកន្លះថ្ងៃ ដែលអង្គជំនុំជម្រះបានផ្តល់ឲ្យក្រុមមេធាវីនោះ។

ដូច្នេះ នៅក្នុងលិខិតដីកាកំណត់កាលបរិច្ឆេទសវនាការផ្នែកពាក់ព័ន្ធនេះ បានកំណត់ច្បាស់លាស់ហើយ។ ដូច្នេះពេលវេលាដែលផ្តល់ឲ្យលោកនេះ គឺលោកមានពេល ក្រុមរបស់លោកទាំង រួមទាំងកូនក្តី

របស់លោកផង មានពេលវេលាកន្លះថ្ងៃ។ សូមអញ្ជើញ!

[១៣:៣៩:១៧]

**លោក ម៉ៃខល ផេសមិន៖**

ប្រហែលជាខ្ញុំមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ ខ្ញុំមិនមែនស្នើសុំម៉ោងបន្ថែមទេ ក៏ប៉ុន្តែគឺខ្ញុំសូមធ្វើការឆ្លើយតបសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញានោះនៅព្រឹកស្អែក។ ក៏ប៉ុន្តែយើងខ្ញុំក៏ដឹងថា អ្វីដែលខ្ញុំបានទទួលបានតាមដីកាកំណត់កាលបរិច្ឆេទនោះ យើងខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋាននៅថ្ងៃស្អែកឯណោះទេ មិនមែនថ្ងៃនេះទេ។

[១៣:៤០:០០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកមានភស្តុតាងអ្វី ដែលថាបញ្ជាក់ថា អង្គជំនុំជម្រះនឹងផ្តល់ឲ្យលោកនៅព្រឹកថ្ងៃស្អែក?

**លោក ម៉ៃខល ផេសមិន៖**

បាទ, ខ្ញុំទុកឲ្យអង្គសវនាការជាអ្នកសម្រេច គ្រាន់តែខ្ញុំដាក់សំណើតែប៉ុណ្ណោះ។ ដោយសារតែសេចក្តីសន្និដ្ឋានពីសហព្រះរាជអាជ្ញា វាលើកឡើងថ្មីសម្រាប់យើងខ្ញុំ។ ដូច្នេះ យើងខ្ញុំចង់យកសេចក្តីសន្និដ្ឋាននេះទៅពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្ញុំសិន មុនពេលដែលខ្ញុំធ្វើការឆ្លើយតប។

ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណជាមួយនឹងសហការីរបស់ខ្ញុំហ្នឹង គឺមានសេចក្តីថ្លែងអំណរគុណចំពោះអង្គសវនាការ បើធ្វើទៅតាមសំណើរបស់យើងខ្ញុំ។ សូមអរគុណ។

[១៣:៤១:០៨]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះក្រុមមេធាវី នួន ជា ហើយនិងជនជាប់ចោទលោក នួន ជា គឺអង្គជំនុំជម្រះមិនយល់សិទ្ធិព្រមដូចតាមសំណើទេ គឺតម្រូវឲ្យក្រុមរបស់លោក ហើយនិងមេធាវីរបស់លោកធ្វើសេចក្តីសន្និដ្ឋានតបនៅពេលនេះ។ ហើយសូមអញ្ជើញលោក នួន ជា បើសិនជាមានអ្វីចង់ធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបទៅនឹងបណ្តឹងសុំ-- សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

[១៣:៤២:៣៤]

**លោក ម៉ៃខល ផេសមិនៈ**

ខ្ញុំកំពុងតែធ្វើការពិនិត្យទៅលើឯកសារ ដែលយើងគិតថា យើងខ្ញុំត្រូវឆ្លើយតបនៅថ្ងៃស្អែក។ ក៏ប៉ុន្តែនៅពេលនេះខ្ញុំសូមធ្វើការលើកឡើងអំពីចម្លើយតប ពីខាងជនជាប់ចោទ។ ខ្ញុំដឹងថាវាជាការយល់ខុសនៅខាងក្រៅ អំពីវិសាលភាពនៃការជំនុំជម្រះនៅទីនេះ។ គឺការយល់ខុសនោះ គឺដោយសារតែវាពាក់ព័ន្ធទៅនឹងការណែនាំ ដែលអង្គជំនុំជម្រះបានផ្តល់ជូនសហព្រះរាជអាជ្ញា ដែលអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ធ្វើការបង្ហាញបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការណែនាំបែបនោះ គឺមានការយល់ច្រឡំ គឺធ្វើឲ្យសាធារណជន និងសារព័ត៌មានមានការយល់ច្រឡំ ដែលថាគ្រប់បទចោទទាំងអស់ ដែលបានលើកឡើងនោះនឹងយកមកពិភាក្សាដេញដោលនៅទីនេះ។ ក៏ប៉ុន្តែ វាមិនមែនដូច្នោះនោះទេ។

[១៣:៤៣:៤០]

វិសាលភាពនៃការជំនុំជម្រះផ្នែកទីមួយនៅពេលនេះ យើងដឹងថាវាមានលក្ខណៈកម្រិត ហើយវាពិតជាមានលក្ខណៈកម្រិតដែលវាជាប់ពាក់ព័ន្ធទៅនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា ហេតុការណ៍កើតឡើងមុនឆ្នាំ១៩៧៥ ហើយនិងតួនាទីរបស់ជនជាប់ចោទ និងការជម្លៀសប្រជាជនភ្នំពេញ។ ទាំងអស់ក្នុងអង្គហេតុទាំងអស់នោះ គឺជាអង្គហេតុដែលត្រូវយក-- គឺជាអង្គហេតុដែលពាក់ព័ន្ធទៅនឹងការជម្លៀសដំណាក់កាលលើកទីពីរ។

ដូច្នេះ កូនក្តីរបស់ខ្ញុំ រួមទាំងយើងខ្ញុំនឹងធ្វើការបង្ហាញសេចក្តីសន្និដ្ឋានរបស់យើងទៅលើផ្នែកជាក់លាក់តែប៉ុណ្ណោះ។ ហើយយើងនឹងធ្វើការឆ្លើយតបទៅនឹងបទចោទផ្សេងទៀត នៅពេលដែលយើងធ្វើការដេញដោលទៅលើការជំនុំជម្រះដំណាក់កាលផ្នែកទីពីរ។ អត់មានបទប្រល័យពូជសាសន៍ អត់មានបញ្ហាមន្ទីរស-២១ យកមកពិភាក្សាដេញដោលនៅពេលនេះទេ។ ពេលវេលាសម្រាប់កូនក្តីរបស់យើងខ្ញុំវាខ្លីពេកសម្រាប់ឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ។

[១៣:៤៤:៥៥]

ដូច្នេះខ្ញុំស្នើសុំឲ្យកូនក្តីរបស់ខ្ញុំនៅអង្គុយកន្លែងដដែលនេះ ដោយសារតែគាត់ពិបាកក្នុងការបន្ទាស់ទី។ យើងបានដាក់សំណើសុំប្តឹងជិតចិត្តចៅក្រម កាលពីកន្លះម៉ោងមុននេះ គឺយើងបានដាក់ពាក្យសុំនោះជាភាសាខ្មែរ និងអង់គ្លេស ហើយយើងខ្ញុំនឹងទុកឱកាសជូនអង្គសវនាការ ធ្វើការពិនិត្យទៅលើពាក្យសុំប្តឹងជិតចិត្តនោះ។ យើងខ្ញុំដឹងថា សេចក្តីសម្រេចបានធ្វើរួចទៅហើយ ក៏ប៉ុន្តែយើងខ្ញុំស្នើសុំឲ្យចៅក្រម

ដកខ្លួនចេញសិន មុនពេលដែលយើងសម្រេចបញ្ហានោះ។

យើងហាក់ដូចជាមិនឯកភាពនូវអ្វីដែលបានលើកឡើង ដែលថាដើមបណ្តឹងរដ្ឋប្បវេណីមិនពាក់ព័ន្ធនៅក្នុងរឿងក្តីនេះ។ ក៏ប៉ុន្តែសេចក្តីសម្រេចទាំងឡាយបានធ្វើឡើងរួចមកហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីគួរតែផ្តល់ឱកាសឲ្យគាត់ក្នុងការធ្វើសេចក្តីសន្និដ្ឋានផងដែរ។ សូមអរគុណ។

[១៣:៤៨:០៤]

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំ នួន ជា មកកាន់ឈើវាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះ។

*(លោក នួន ជា ចូលមកកាន់វង់ក្រចកសេះ)*

សូមអញ្ជើញលោក នួន ជា! សូមអញ្ជើញ!

**លោក នួន ជា៖**

សេចក្តីផ្តើម៖ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ គោរពបងប្អូន ជនរួមជាតិ អ្នកស្នេហាជាតិទាំងអស់ និងសូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។

ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធបណ្តាវីរបុរសទាំងឡាយ ដែលបានបូជាសាច់ឈាម ឆ្អឹង ជីវិត ដើម្បីការពារជាតិមាតុភូមិកម្ពុជា ជាទីស្នេហាគ្រប់កាលសម័យឲ្យបានគង់វង្ស ស្ថិតស្ថេរជារៀងរហូតមកដល់បច្ចុប្បន្ននេះ និងទៅអនាគតកាលយូរអង្វែងតទៅទៀត។ ជាពិសេសឲ្យរួចផុតពីនយោបាយឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍ពីសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រទេសជិតខាងដទៃទៀត។

[១៣:៥១:១៨]

ថ្ងៃនេះខ្ញុំ នួន ជា ត្រូវបានផ្តល់ឲ្យនូវឱកាសមួយដែលខ្ញុំរង់ចាំយូរមកហើយ គឺការបំភ្លឺជូនជនរួមជាតិ អ្នកស្នេហាជាតិ និងកូនខ្មែរទាំងអស់ អំពីការការពិត ដែលកើតមានឡើងក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។ ដូចខ្ញុំបានបញ្ជាក់ហើយថា ប្រសិនបើសុខភាពរបស់ខ្ញុំអំណោយផល ខ្ញុំនឹងព្យាយាមពន្យល់ និងដោះស្រាយបំភ្លឺនូវរាល់បញ្ហាទាំងអស់ គឺដើម្បីប្រវត្តិសាស្ត្រមួយដ៏ត្រឹមត្រូវ មិនមែនប្រវត្តិសាស្ត្របម្រើខាងផ្នែកនយោបាយនោះទេ។ ខ្ញុំគិតថា តុលាការនេះមានភាពមិនយុត្តិធម៌សម្រាប់ខ្ញុំ តាំងពីដើមដំបូងមកម្ល៉េះ ដោយហេតុថា យកតែបញ្ហាមួយចំណែកប៉ុណ្ណោះមកជំនុំជម្រះ។ ខ្ញុំសូមនិយាយថា សត្វក្រពើមួយទាំងមូល គេយកតែរូបខ្លួនមកនិយាយ តែមិនយកក្បាល និងកន្ទុយ ដែលជាចំណែកសំខាន់ក្នុងការ

បម្រើដល់សកម្មភាពរាល់ថ្ងៃរបស់វា ឬក្នុងន័យម្យ៉ាងទៀត គឺថាឫសគល់ និងបច្ច័យរបស់វា គឺជាអ្វីដែលបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៦។ តែតុលាការនេះមិនយកមកពិចារណាទេ។

[១៣:៥៣:០៧]

ដើម្បីឲ្យទទួលបាននូវយុត្តិធម៌ ដូចដែលតុលាការនេះបានប្ដេជ្ញា ខ្ញុំសង្ឃឹមថា ខ្ញុំនឹងត្រូវបានផ្ដល់ឱកាសនេះ ដើម្បីនិយាយនូវអ្វីដែលខ្ញុំចង់និយាយ ដើម្បីបម្រើដល់ការពិត មានប្រយោជន៍ និងយុត្តិធម៌។ ថ្ងៃនេះ ខ្ញុំមិនឆ្លើយតបទៅនឹងអ្វីដែលចោទទាំងអស់នោះទេ ខ្ញុំនឹងឆ្លើយទៅនឹងការចោទប្រកាន់មានតែក្នុងដំណាក់កាលដំបូងនេះនៃសវនាការនេះតែប៉ុណ្ណោះ។ ចំពោះការចោទផ្សេងទៀត ខ្ញុំនឹងឆ្លើយទៅពេលក្រោយ។

[១៣:៥៣:៥៨]

ជាបន្ត ខ្ញុំសូមរៀបរាប់តាមជាលំដាប់ៗដូចតទៅនេះ៖

ការចែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីបក្ស។ ឆ្នាំ១៩៣០ វៀតណាម ចាត់តាំងបក្សកុម្មុយនីស្តឥណ្ឌូចិនដឹកនាំបញ្ជាដោយវៀតណាម។ ក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលវៀតណាមសរសេរ មានវគ្គមួយនិយាយច្បាស់ថា "ក្រោយពីប្រទេសទាំងបី គឺវៀតណាម កម្ពុជា និងឡាវបានឯករាជ្យហើយ នឹងចាត់តាំងជាសហព័ន្ធឥណ្ឌូចិន"។ សូមជម្រាបថា បក្សកុម្មុយនីស្តឥណ្ឌូចិននេះ រហូតដល់ឆ្នាំ១៩៥០ គ្មានខ្មែរណាម្នាក់ចូលជាសមាជិករបស់បក្សកុម្មុយនីស្តឥណ្ឌូចិនទេ។ មូលហេតុសំខាន់គឺខ្មែរមិនចូលចិត្តវៀតណាម។ ដល់ឆ្នាំ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិន តាមយុទ្ធវិធីរបស់វៀតណាម បានចែកចេញជាបីបក្សទៅវិញ ដើម្បីឲ្យសមស្របទៅតាមសភាពការណ៍របស់ប្រទេសនីមួយៗ។ នៅកម្ពុជាចាត់តាំងជាបក្សប្រជាជនបដិវត្តន៍កម្ពុជា។ នៅលាវ ចាត់តាំងជាបក្សប្រជាជនបដិវត្តន៍ឡាវ។ នៅវៀតណាម ចាត់តាំងជាបក្សពលករវៀតណាម ហៅថា បក្សឡាវដុង។ តែទោះជាចាត់តាំងចែកជាបីបក្សយ៉ាងនេះហើយក៏ដោយ បក្សប្រជាជនបដិវត្តន៍កម្ពុជា និងបក្សប្រជាជនបដិវត្តន៍ឡាវ ពុំមានលក្ខណៈឯករាជ្យអ្វីទេ។ កិច្ចអ្វីទាំងអស់នៅក្រោមការដឹកនាំបញ្ជារបស់បក្សពលករវៀតណាម។ នៅក្នុងប្រទេសវៀតណាមបានចាត់តាំងបក្សមួយផ្សេងដោយស្ងាត់ ហៅថាឈ្មោះ "បក្សប្រជាជនកម្ពុជា"។ សមាជិករបស់បក្សនេះ គឺពួកខ្មែរវៀតមិញ ដែលវៀតណាមយកទៅអប់រំនៅហាណូយ ពីឆ្នាំ១៩៥៤ ក្រោយពីកិច្ចព្រមព្រៀងហ្សឺណែវ។

[១៣:៥៦:២៦]

ពួកនេះសុទ្ធតែចូលអប់រំនៅក្នុងសាលាបក្សកុម្មុយនីស្តវៀតណាម ហៅថា សាលាង្វៀងអាយគួក ឈ្មោះរបស់ ហូ ជីមិញ។ ពួកនេះ ទៅរស់នៅវៀតណាម ១៦ឆ្នាំ ទទួលឥទ្ធិពលពីទស្សនៈគោលជំហរមាគ៌ានយោបាយ មាគ៌ាចាត់តាំងពីបក្សកុម្មុយនីស្តវៀតណាម ហើយយកមកផ្សព្វផ្សាយអនុវត្តនៅកម្ពុជា និងថែមទាំងវាយប្រហារមាគ៌ានយោបាយ មាគ៌ាចាត់តាំង និងយុទ្ធសាស្ត្រ យុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាជាបន្តបន្ទាប់មក ពិសេសតាំងពីឆ្នាំ១៩៦០។ ក្រៅពីនេះ ក្នុងរយៈវេលាតាំងពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧៩ វៀតណាមប្រើល្បិចកលគ្រប់បែបយ៉ាង ដើម្បីបំផ្លាញការបដិវត្តរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍប្រទេសជាតិកម្ពុជាប្រជាធិបតេយ្យមានដូច ចាត់តាំងជាបក្សពួក ក្នុងបក្ខជន អ្នកដឹកនាំពីលើដល់ក្រោមក្នុងបក្សកុម្មុយនីស្តកម្ពុជាដោយសម្ងាត់ ដើម្បីត្រៀមទប់ទល់ប្រឆាំងបក្សកុម្មុយនីស្តកម្ពុជាយ៉ាងចេញមុខក្នុងពេលចំពោះមុខ និងបណ្ដាញ និងចាត់តាំងបណ្ដាញការងារសម្ងាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាសម្រាប់អនាគតតទៅទៀត។ ថែមទាំងវាយប្រហារត្រង់ៗមកលើបក្សកុម្មុយនីស្តកម្ពុជា និងចាក់រុក ញុះញង់ បំបែកបំបាក់ អូសទាញប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជាឲ្យកើតទំនាស់ កើតជាសត្រូវជាមួយបក្ស ដើម្បីបង្កើតឲ្យមានការច្របូកច្របល់បែកបាក់សាមគ្គី បំផ្លាញមាគ៌ានយោបាយអភិវឌ្ឍន៍ប្រទេស ដោយវិធីដុតឲ្យខ្លោច រោចឲ្យឆៅ។ល។

[១៣:៥៨:៣៥]

តាមសកម្មភាពផ្សេងៗរបស់បក្សកុម្មុយនីស្តវៀតណាមនៅលើឆាកអន្តរជាតិ អាចសរុបបានដូចតទៅនេះ៖

គឺពឹងផ្អែកជិតស្និទ្ធសហភាពសូវៀត ខាងសេដ្ឋកិច្ច យោធា ការទូត។ ទាក់ទងអូសទាញសហរដ្ឋអាមេរិកកុំឲ្យរារាំងសកម្មភាពរបស់ខ្លួនមកលើកម្ពុជាប្រជាធិបតេយ្យ។ បំភ័យ អូសទាញ អព្យាក្រឹតបណ្ដាប្រទេសអាស៊ាន និងបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធ។ ប្រឆាំងនឹងចិនដោយមានកម្រិតផងហើយខំសម្រួលអូសទាញផង។ វាយកម្ពុជាប្រជាធិបតេយ្យដោយប្រើកម្លាំងធំពីរសែនប្រាំម៉ឺនាក់តាមយុទ្ធវិធីវាយរហ័ស ឈ្នះរហ័ស គ្រប់គ្រងយូរអង្វែង និងអនុវត្តនយោបាយទុរគតភាវូបនីយកម្មប្រជាជនអាវាសែភាវូបនីយកម្ម ដើម្បីកុំឲ្យកម្ពុជាមានកម្លាំងតស៊ូរំដោះប្រទេសជាតិ។

តើកត្តាអ្វីជាមូលហេតុចម្បងធ្វើឲ្យវៀតណាមមានមហិច្ឆតាត្រួតត្រាគ្រប់គ្រងកម្ពុជា និងឡាវ?

[១៣:៥៩:៥៣]

មានកត្តាមួយចំនួន ដូចតទៅនេះគឺ៖ វៀតណាមមានគំនិតជាជាតិធំ ឬហៅថា លទ្ធិជាតិធំនិយម

លទ្ធិធ្វើចៅហ្វាយលើប្រទេសតូច ប្រជាជនតិច ទន់ខ្សោយមើលងាយមើលថោកប្រទេសតូច ប្រជាជនតិចទន់ខ្សោយ។ វៀតណាមប្រកាន់យកនូវលទ្ធិឈ្លានពាន វាតទីលេបទឹកដីបំបាត់ពូជសាសន៍។ វៀត-ណាមលោភលន់អំណាច និងផលប្រយោជន៍ខាងសេដ្ឋកិច្ច ឬហៅថាផលប្រយោជន៍និយម *អេក្សូអ៊ីស* អំណាចនិយម ចាត់តាំងជាសហព័ន្ធឥណ្ឌូចិនដោយនៅក្រោមការត្រួតត្រារបស់វៀតណាម តាមរូបភាពមិត្តភាពពិសេស និងគំនិតធ្វើវៀមច្បូងនៅក្នុងប្រទេសអាស៊ាន ក៏វៀតណាមនៅមានមហិច្ឆតានេះដែរ។

ដូច្នោះកត្តាវៀតណាមជាបច្ច័យមួយសំខាន់ដែលបង្កឲ្យមានការច្របូកច្របល់ក្នុងប្រទេសកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ខែមេសា ១៩៧៩។

[១៤:០១:១៦]

អំពីការរៀបចំបក្ស និងកសាងកម្លាំងប្រជាជន ក្នុងរយៈពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៥៧ យើងបានស្តាររៀបចំបក្សឡើងវិញ និងកសាងកម្លាំងចាត់តាំងមហាជនបានមួយកម្រិត។ ម្យ៉ាងទៀតពេលនេះបក្សយើងនៅមិនទាន់មានមាគ៌ានយោបាយជាយុទ្ធសាស្ត្រ យុទ្ធវិធី ដោយឯកភាពគ្នាច្បាស់លាស់នៅឡើយ។ យើងត្រូវរៀបចំព្រាងនយោបាយយុទ្ធសាស្ត្រ យុទ្ធវិធី តាំងពីឥឡូវ។ ត្រូវរៀបចំវិភាគសភាព-ការណ៍ទាំងក្នុងប្រទេស ក្រៅប្រទេស ដើម្បីលើកមាគ៌ានយោបាយយុទ្ធសាស្ត្រ យុទ្ធវិធី ដោយឯករាជ្យម្ចាស់ការខ្លួនយើង។

[១៤:០២:១២]

ខ្ញុំ នួន ជា និងប៉ុល ពត យល់ស្របតាមមតិលោកតា គឺលោកតា ទូ សាមុត អំពីបក្សយើងត្រូវមានមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធី លក្ខន្តិកៈបក្សរបស់ខ្លួនឲ្យច្បាស់លាស់កុំឲ្យជំពាក់ជំពិនជាមួយបក្សវៀតណាម។ អំពីមាគ៌ាយុទ្ធសាស្ត្របក្ស ខែមិថុនា ឆ្នាំ១៩៥៨ កងទ័ពវៀតណាមខាងត្បូង ធីវគីបានឈ្លានពានចូលមកក្នុងទឹកដីកម្ពុជា ដោយឥតអៀនខ្មាស។ ខាងថៃ ក៏លើកយកបញ្ហារឿងប្រាសាទព្រះវិហារមកចរចា ដើម្បីបង្ករឿងហេតុតាមព្រំដែនជាមួយកម្ពុជា មានការប្រឆាំងគ្នាតាមកាសែត វិទ្យុយ៉ាងចាស់ដៃ។ ថ្ងៃទី២៨, ២៩, ៣០ កញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍កម្ពុជាបើកធ្វើមហាសន្និបាតបក្សលើកទីមួយ ដើម្បីផ្តងមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធី និងលក្ខន្តិកៈរបស់បក្ស ហើយជ្រើសតាំងគណៈដឹកនាំបក្ស។

[១៤:០៣:៣២]

សមាជិកបក្សដែលមកចូលរួមប្រជុំមានតំណាងខាងភូមិភាគនិរតី បូព៌ា កំពង់ឆ្នាំង ឧត្តរ ពាយ័ព្យ

និងតំណាងបក្សក្រុងភ្នំពេញ។ មហាសន្និបាតបានឯកភាពជ្រើសតាំងលោកតា ទូ សាមុត ជាលេខាបក្ស។ នួន ជា ជាអនុលេខា ប៉ុល ពត និង សមមិត្តមួយចំនួនទៀតជាគណៈអចិន្ត្រៃយ៍ និងជាគណៈមជ្ឈិមបក្ស។ មាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធី ឬហៅម្យ៉ាងទៀតថា មាគ៌ានយោបាយរណសិរ្ស មានខ្លឹមសារសំខាន់ៗជាមូលដ្ឋានដូចខាងក្រោមនេះ៖

១) វិភាគធាតុពិតនៃសង្គមកម្ពុជា។ សង្គមកម្ពុជានាពេលនោះគឺជាសង្គមពាក់កណ្តាលសក្តិភូមិពាក់កណ្តាលអាណានិគម មានការជ្រៀតជ្រែកពីបរទេស សំខាន់ពេលនោះគឺសហរដ្ឋអាមេរិក ដែលប៉ុនប៉ងទាញប្រទេសកម្ពុជាឱ្យចូលក្នុងអង្គការ សេ.អា.តូ។

២) អំពីធាតុពិតនៃបដិវត្តន៍កម្ពុជា បើសភាពការណ៍សង្គមកម្ពុជា មានធាតុពិតដូចពោលខាងលើ តើកម្ពុជាត្រូវធ្វើបដិវត្តន៍អ្វី?

ធាតុពិតនៃបដិវត្តន៍កម្ពុជា គឺបដិវត្តន៍ជាតិប្រជាធិបតេយ្យ។ បដិវត្តន៍ជាតិគឺប្រឆាំងបរទេសឈ្លានពានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងមកពីខាងក្រៅ ប្រជាធិបតេយ្យ គឺបំបាត់នូវរបបពាក់កណ្តាលសក្តិភូមិ ដូចជា ទាមទារបន្ថយឈ្នួលស្រែ បុល បណ្តាក់ ពន្ធដារ ការប្រាក់ ធ្វើឱ្យកសិករមានដីធ្វើស្រែចម្ការរបស់ខ្លួន។ និយាយរួមគឺបំបាត់ការជិះជាន់ខាងសេដ្ឋកិច្ចទៅលើកសិករ កែប្រែជីវភាពកសិករ ឱ្យមានហូបចុក ស្លៀកពាក់សមរម្យ និងមានសិទ្ធិសេរីភាពប្រជាធិបតេយ្យ។

៣) តើអ្នកណាជាសត្រូវរបស់បដិវត្តន៍ជាតិប្រជាធិបតេយ្យ? សត្រូវគឺបរទេសឈ្លានពានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា និងបរិវារឃោរឃៅរបស់បរទេស។

៤) តើរៀបចំកម្លាំងប្រយុទ្ធយ៉ាងម៉េច? គឺប្រយុទ្ធប្រមូលគ្រប់កម្លាំងជនជាតិខ្មែរ ជនជាតិភាគតិចទាំងអស់ ដែលមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ផ្អែកលើមូលដ្ឋាននៃកម្លាំងសម្ព័ន្ធភាពកសិករកម្មករ។

[១៤:០៦:៣៤]

៥) តើប្រើរូបភាពតស៊ូយ៉ាងណា? យើងប្រើរូបភាពតស៊ូស្របច្បាប់ ពាក់កណ្តាលស្របច្បាប់ និងមិនស្របច្បាប់ ហើយបើចាំបាច់ត្រូវប្រើរូបភាពនយោបាយរួមផ្សំអាវុធដោយយករូបភាពនយោ-បាយមូលដ្ឋាន រូបភាពអាវុធជាបន្ទាប់ ដើម្បីការពារកម្លាំងតាមរូបភាពឈ្លប។

៦) កិច្ចដំណើរការតស៊ូ គឺតស៊ូពីជនបទចុងកាត់មាត់ញកទៅកាន់ទីប្រជុំជនតាមរូបភាពតំណក់ប្រេង។

៧) តើអង្គការណាដឹកនាំ? គឺបក្សប្រជាជនបដិវត្តន៍កម្ពុជាដឹកនាំ ដែលប្រែឈ្មោះជាបក្សពលករកម្ពុជា។

៨) តើទិសដៅនៃបដិវត្តន៍ជាតិប្រជាធិបតេយ្យយ៉ាងណា? ទិសដៅគឺកម្ពុជាសន្តិភាព ឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដី អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ មិនអនុញ្ញាតឲ្យបរទេសណាតាំងមូលដ្ឋានទ័ពក្នុងប្រទេសកម្ពុជា។

៩) ពាក្យស្លោករបស់បដិវត្តន៍ជាតិប្រជាធិបតេយ្យ គឺតស៊ូយូរអង្វែង លំបាកវេទនា ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង ហើយទាក់ទងគ្រប់ប្រទេសដែលស្នេហាសន្តិភាព ស្មើភាព គោរពគ្នាទៅវិញទៅមក មានផលប្រយោជន៍រវាងគ្នាទៅវិញទៅមក។

ការកែប្រែសម្រួលមាគ៌ាយុទ្ធសាស្ត្រនេះ គឺមានតែមហាសន្និបាតបក្សទូទាំងប្រទេសទើបមានសិទ្ធិកែប្រែ។

[១៤:០៨:៣៤]

អំពីមាគ៌ាយុទ្ធវិធីបក្ស មាគ៌ារណសិរ្សរួបរួមជាតិកម្ពុជាធ្វើការបដិវត្តន៍ជាតិ ប្រជាធិបតេយ្យ។ ក្នុងការធ្វើមាគ៌ាយុទ្ធវិធីគឺលោកតា ទូ សាមុត បានណែនាំច្បាស់ថា៖

១) ត្រូវឈរលើមូលដ្ឋាននៃមាគ៌ាយុទ្ធសាស្ត្រ ត្រូវក្តាប់មាគ៌ាយុទ្ធសាស្ត្រឲ្យជាប់ ហើយលម្អិតមាគ៌ាយុទ្ធវិធីឲ្យបានជាក់ស្តែងទៅតាមសភាពការណ៍នៃប្រទេសយើង។

២) ប្រមូលកម្លាំងជាតិទាំងអស់ដោយមិនប្រកាន់និន្នាការនយោបាយ ឬបក្ខពួក សាសនា អតីតកាល។

៣) ឯកោឲ្យដល់កម្រិតខ្ពស់បំផុតខ្មាំងសត្រូវរបស់ជាតិ និងពួកបរិវារឃោរឃៅផុតលេខដែលមិនភ្ញាក់រឭក នៅតែក្បាលរឹងជជេសបម្រើខ្មាំងសត្រូវ បំផ្លាញជាតិឯង។

[១៤:០៩:៤១]

ខែកក្កដា ១៩៦២ លោកតា ទូ សាមុត លេខាបក្សត្រូវបាត់ខ្លួនដោយស្ងាត់ៗ តាមខ្សែចាត់តាំងយោធាដែលមានសមានចិត្តជាមួយបក្សឲ្យដឹង ឲ្យដំណឹងថា លោកតា ទូ សាមុត ត្រូវពួកទាហានសម្ងាត់របស់ លន់ នល់ ស្កាត់ចាប់កណ្តាលផ្លូវត្រង់មុខវត្តទួលទំពូង ហើយយកគាត់ធ្វើទារុណកម្មនៅផ្ទះលន់ នល់។ តែលោកតា គ្មានឆ្លើយអ្វីមួយម៉ាត់។ ពីរបីថ្ងៃក្រោយមក វាយកគាត់ទៅសម្លាប់នៅវត្តស្ទឹងមានជ័យ។ ព្រឹត្តិការណ៍នេះជាការខូចខាតយ៉ាងធ្ងន់បំផុតរបស់បក្សកម្ពុជា តែវាក៏បានដុតភ្លើង

កំហឹងឲ្យផ្ទៃក្នុងបក្សកាន់តែឆាបឆេះខ្លាំងឡើង ហើយធ្វើឲ្យសកម្មភាពកាន់តែខ្លាំងឡើងថែមទៀត មិនរាថយ។

ក្នុងឆ្នាំនេះដែរ សហរដ្ឋអាមេរិក ក៏បានបញ្ជូនកងទ័ពមកប្រទេសថៃថែមទៀត រួមទាំងកសាងវាលយន្តហោះដើម្បីធ្វើជាមូលដ្ឋានកងទ័ពអាកាស។ ទិសដៅរបស់អាមេរិក គឺដើម្បីបង្ក្រាបចលនាតស៊ូរំដោះជាតិរបស់ប្រជាជនឥណ្ឌូចិន ជាពិសេសចលនាតស៊ូរំដោះប្រជាជនវៀតណាម ដែលកាន់តែឆេះខ្លាំងឡើងៗ។

[១៤:១១:១៥]

ក្នុងខែឧសភា ឆ្នាំ១៩៦២ បក្សពលករកម្ពុជាធ្វើមហាសន្និបាតលើកទីពីរ ដើម្បីតែងតាំង ប៉ុល ពត ជាលេខាបក្ស នួន ជា ជាអនុលេខាបក្ស ដោយផ្លាស់ឈ្មោះ “បក្សពលករកម្ពុជា” ជា “បក្សកុម្មុយ-នីស្តកម្ពុជា”។

ខែសីហា រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចនរោត្តម សីហនុ ជាព្រះប្រមុខ តវ៉ាទាមទារឲ្យវៀតណាមខាងត្បូង ង៉ោ ឌិន យៀម ឈប់រុករានឈ្លានពានតាមជាយដែនកម្ពុជា។ ការទាមទារនេះមិនបានផល ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាបានកាត់សម្ព័ន្ធខាងផ្លូវទូតជាមួយវៀតណាមខាងត្បូង ង៉ោ ឌិន យៀម។ បក្សសម្រេចចិត្តតស៊ូនយោបាយរួមផ្សំអាវុធ។

[១៤:១២:១២]

ឆ្នាំ១៩៦៨ ពេលនោះ បក្សកុម្មុយនីស្តកម្ពុជាត្រូវចែកចេញជាពីរផ្នែក គឺមួយផ្នែកនៅឯមូលដ្ឋានបង្អែករតនគិរី ដែលមាន ប៉ុល ពត ជាលេខាបក្សដឹកនាំ ហៅថាភូមិភាគឦសាន និងមួយផ្នែកទៀតនៅទីក្រុងភ្នំពេញ រួមមាន ភូមិភាគពាយ័ព្យ និរតី បូព៌ា ឧត្តរ និងបក្សក្រុងភ្នំពេញ មានអនុលេខាបក្ស នួន ជា ទទួលខុសត្រូវដឹកនាំ ហៅថាភូមិភាគកណ្តាល។

ថ្ងៃទី១ ខែមករា ១៩៦៨ ផ្នែកបក្សភូមិភាគកណ្តាលបានប្រមូលប្រជុំលេខាភូមិភាគបូព៌ា និរតី ពាយ័ព្យ ឧត្តរ និងលេខាបក្សទីក្រុងភ្នំពេញ ដើម្បីពិនិត្យសភាពការណ៍ដែលកាន់តឹងតែងខ្លាំងឡើង ហើយដើម្បីលើកវិធានការតស៊ូថ្មីឲ្យសមស្របនឹងសភាពការណ៍បច្ចុប្បន្ន។

[១៤:១៣:១៦]

អង្គប្រជុំបានឯកភាពគ្នាថា សភាពការណ៍បង្ក្រាបរាតត្បាត ចាប់ចង កាប់សម្លាប់ តាមអំពើចិត្តរបស់ពួកកាន់អំណាចឃោរឃៅ ប្រតិកិរិយា លន់ នល់, គូ រុន, អ៊ិន តាំ កាន់តែខ្លាំងឡើងៗ ហើយកាន់

តែឈានទៅខ្លាំងថែមទៀត រហូតដល់បក្សកុម្មុយនីស្តកម្ពុជាទាំងមូលត្រូវរលាយសាបសូន្យ។ តើយើងនៅតែតស៊ូនយោបាយទទេអីចឹងរហូតដល់បក្សរលាយអស់ ដូចជាបក្សឥណ្ឌូនេស៊ីទាំងនោះឬ?

អង្គប្រជុំឯកភាពគ្នាថា យើងត្រូវតស៊ូនយោបាយរួមផ្សំអាវុធ ដោយនៅតែយកនយោបាយជាមូលដ្ឋាន ហើយអាវុធសម្រាប់ការពារកម្លាំងតាមការចាំបាច់។ ភូមិភាគណាដែលសភាពការណ៍ទុំ ហើយឲ្យដំណើរការតស៊ូមុនទៅ ដើម្បីការពារកម្លាំង។ សំខាន់គឺត្រូវការពារកម្លាំងបក្ស កម្លាំងប្រជាជនក្នុងភូមិភាគខ្លួនឲ្យបាន កុំឲ្យពួកកាន់អំណាចប្រតិកិរិយាឃោរឃៅ វាធ្វើអ្វីបានតាមអំពើចិត្តវា។

[១៤:១៤:៣២]

បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសយកថ្ងៃ១២ ខែមករា ឆ្នាំ១៩៦៨ ដែលជាថ្ងៃចាប់ផ្តើមតស៊ូនយោបាយរួមផ្សំអាវុធ ជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា។

ឆ្នាំ១៩៦៩ ប្រធានាធិបតី និចសុន នៃសហរដ្ឋ តាមសេចក្តីស្នើរបស់ឧត្តមសេនីយ៍ឯក អាប្រាហាំ មេបញ្ជាការយោធាសហរដ្ឋនៅវៀតណាមបញ្ជាឲ្យទម្លាក់គ្រាប់បែកលើទីតាំងរបស់វៀតកុង និងលើកងទ័ពវៀតណាមខាងជើង ដែលលួចបោះនៅក្នុងទឹកដីកម្ពុជា។ ដូច្នោះយន្តហោះបេ៥២ របស់សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកយ៉ាងខ្លាំង លើពួកកុម្មុយនីស្តវៀតណាមក្នុងទឹកដីកម្ពុជា ធ្វើឲ្យប្រជាជនកម្ពុជាត្រូវរងគ្រោះថ្នាក់ជាច្រើន ស្រែចម្ការ ផលដំណាំត្រូវខូចខាត ប្រជាជនត្រូវជម្លៀសចេញពីភូមិ ហើយវត្តវាំអារាមនៅតាមស្រុក ភូមិខ្លះក៏ត្រូវខូចខាត ព្រះសង្ឃត្រូវនិមន្តគេចទៅគង់នៅកន្លែងផ្សេង។

[១៤:១៥:៥១]

ក្នុងខែធ្នូ ១៩៦៩ ប៉ុល ពត ដឹកនាំគណៈប្រតិភូមួយ ដើរតាមផ្លូវលំហូជីមិញទៅហាណូយ។ នៅហាណូយមានការប្រជុំរវាងគណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជា និងគណៈមជ្ឈិមបក្សកុម្មុយនីស្តវៀត-ណាមមាន ឡេ យន់ អគ្គលេខា និងសមាជិកប៉ូលិសប៊ុយរ៉ូបក្សកុម្មុយនីស្តមាន ឡេ ឌឹក ថ, វ៉ ង្វៀន យ៉ាប និង ង្វៀង យុយ ទ្រិញ ខាងបក្សកុម្មុយនីស្តកម្ពុជាក្រៅពីលេខា ប៉ុល ពត នៅមាន ស៊ឺន ង៉ុកមិញ ចូលរួមប្រជុំផងដែរ។

តាម ប៉ុល ពត រាយការណ៍ គឺបរិយាកាសប្រជុំតឹងតែងណាស់ មិនមានសេចក្តីសម្រេចអ្វីជាដុំកំភួនទេ ព្រោះបក្សមួយៗឈរលើគោលជំហររបស់បក្សរៀងខ្លួន។ ក្នុងការប្រជុំគោលបំណងសំខាន់របស់បក្សកុម្មុយនីស្តវៀតណាម គឺឲ្យបក្សកុម្មុយនីស្តកម្ពុជាឈប់តស៊ូនយោបាយរួមផ្សំអាវុធ ហើយត្រឡប់ទៅតស៊ូនយោបាយតែម្យ៉ាងវិញ។ ទាំងនេះគឺដើម្បីផលប្រយោជន៍របស់បក្សកុម្មុយនីស្តវៀតណាម។

[១៤:១៧:០៤]

វៀតណាមធ្លាប់និយាយហើយថា ពួកមិត្តមិនបាច់តស៊ូដោយអាវុធទេ ចាំកាលណាវៀតណាមរំដោះអស់ហើយ វៀតណាមនឹងវាយរំដោះភ្នំពេញតែក្នុងម្ភៃបួនម៉ោងប៉ុណ្ណោះ។ ពួកមិត្តចាំតែរកអ្នកនាំផ្លូវឲ្យកងទ័ពវៀតណាមទៅបានហើយ។ ចំពោះទស្សនៈរបស់បក្សវៀតណាមយ៉ាងនេះ ប៉ុល ពត ធ្លាប់ពន្យល់កម្មាភិបាលបក្សថា "អ្នកណាគេធ្វើអ្នកនោះគេយកផលប្រយោជន៍"។ ខែកុម្ភៈ មានកងទ័ពកុម្មុយនីស្តវៀតណាមនៅលើទឹកដីកម្ពុជាប្រមាណជាប្រាំម៉ឺននាក់។ សម្តេចនរោត្តម សីហនុ ទ្រង់ប្រកាសនៅទីក្រុងប៉ារីសថាត្រៀមផែនការតវ៉ាក្នុងក្រុងម៉ូស្គូ និងបេកាំងឲ្យដកកងទ័ពវៀតណាមកុម្មុយនីស្តទាំងអស់ចេញពីទឹកដីកម្ពុជា។

[១៤:១៨:០៥]

ក្នុងខែកុម្ភៈ ខ្ញុំ នួន ជា ធ្វើដំណើរទៅធ្វើសន្និបាត និងបើកវគ្គសិក្សានៅភូមិបូព៌ា ដើម្បីពិនិត្យសភាពការណ៍ ពីលទ្ធភាពធ្វើរដ្ឋប្រហាររបស់បនប្រតិកិរិយា លន់ នល់ និងដាក់វិធានការទប់ទល់រដ្ឋប្រហារនេះ។ កងទ័ព លន់ នល់ ដោយមានការសហប្រតិបត្តិការយ៉ាងជិតស្និទ្ធពីព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ក៏បានធ្វើរដ្ឋប្រហារបានសម្រេចដោយរដ្ឋសភាជាតិ ក្រោមការត្រួតត្រាពួកប្រតិកិរិយា លន់ នល់ បានមានមតិដកសេចក្តីទុកពីសម្តេចព្រះ សីហនុ ក្នុងឋានៈជាព្រះប្រមុខរដ្ឋកម្ពុជា។

បានដំណឹងនេះភ្លាមការប្រជុំសន្និបាតបក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគបូព៌ាបានរំសាយភ្លាមហើយដាក់ផែនការឲ្យកងឈ្លបវាយប៉ុស្តិ៍ប៉ូលិស ទាហានតូចៗនៅតាមព្រំដែនខ្មែរ-វៀតណាមយកអាវុធបំពាក់ឲ្យខ្លួន ឲ្យពួកទាហានប៉ូលិស លន់ នល់ ឲ្យគេត្រឡប់ទៅផ្ទះគេវិញជួបជុំគ្រួសារ។ ម្យ៉ាងទៀតឲ្យបំផុសកម្លាំងប្រជាជនធ្វើបាតុកម្មតាមស្រុក ដើម្បីប្រឆាំងរដ្ឋប្រហារ ឧបត្ថម្ភសម្តេច សីហនុ នៅភូមិភាគនិរតី ក៏រំសាយប៉ុស្តិ៍ប៉មប៉ូលិស នៅតាមស្រុកជាច្រើន រឹបយកអាវុធ គ្រាប់រំសេវបានជាច្រើនធ្វើដើមទុនសម្រាប់ប្រយុទ្ធតទៅមុខទៀត។ ពេលនោះដែរកងទ័ពកុម្មុយនីស្តវៀតណាម រួមមានកងទ័ពដែលមកពីខាងជើងវៀតណាម កងទ័ពរណសិរ្សរំដោះវៀតណាមខាងត្បូង ក៏សម្រុកចូលមកក្នុងទឹកដីកម្ពុជាដូចទឹកបាក់ទំនប់។ គេមកដើរចាត់តាំងរដ្ឋអំណាចតាមភូមិឃុំកម្ពុជា ចាត់តាំងពួកអាណិកជនវៀតណាម ខ្មែរហៅថា "ពួកត្បាញអាយ" ធ្វើជារដ្ឋអំណាចកាន់កាប់ទាំងនយោបាយសេដ្ឋកិច្ចកម្ពុជានៅតាមឃុំជ្រៅៗ។ នៅកំពង់ធំកងទ័ពវៀតណាមកុម្មុយនីស្តបានចាត់តាំងកងទ័ពខ្មែរមួយកងវរសេនាតូចមានមេឈ្មោះ ឃុត ឧត្តម វង្សរតនា កងទ័ពវៀតណាមកុម្មុយនីស្តដែលបាក់ចូលមកកម្ពុជា សុទ្ធតែពាក់

រូបសម្តេចសីហនុ ដើម្បីបន្លំប្រាប់ប្រជាជនថា ខ្លួនជាកងទ័ពសម្តេច តែសកម្មភាពរំលោភលើរដ្ឋអំណាចអធិបតេយ្យភាពកម្ពុជាទាំងប៉ុន្មាននេះ សុទ្ធតែត្រូវប្រជាជនកម្ពុជាប្រឆាំងដាច់ខាត ហើយបណ្តើរៗក៏រសាយបាត់ទៅវិញ ព្រោះប្រជាជនកម្ពុជាប្រឆាំងមិនទទួលនូវការចាត់តាំងដែលបក្សកុម្មុយនីស្តវៀតណាមធ្វើតាមអំពើចិត្តទាំងអស់នេះ។

[១៤:២១:១៣]

សូមរំឭកថា តាមសេចក្តីអំពាវនាវរបស់សម្តេចសីហនុ ឲ្យកូនចៅព្រះអង្គចូលព្រៃម៉ាកគី តស៊ូប្រឆាំងរដ្ឋប្រហាររបស់ លន់ នល់ សិរិមតៈ ប្រតិកិរិយាមានប្រជាជនយុវជនជាច្រើនរត់ចូលព្រៃ មានទាំងអ្នកល្អ អ្នកមិនល្អ ពួកឱកាសនិយម ពួកអ្នកលេង អាវ៉ាសែ ពួកគ្មានការងារធ្វើ ពួកធ្លាប់លួចប្លន់ ។ល។ ឯកម្មាភិបាលបដិវត្តន៍ ឬគេហៅថា ខ្មែរក្រហម ចេះតែទទួលយកដោយមិនបាច់ពិនិត្យប្រវត្តិរូបឲ្យបានហ្មត់ចត់។ ពួកសមាសភាពមិនល្អនេះហើយ តមកថ្ងៃក្រោយបង្កស្មុគស្មាញច្របូកច្របល់ឲ្យចលនាបដិវត្តន៍មិនតិចទេ ខ្លះរត់ចូលទៅសារភាពពួក លន់ នល់ វិញក៏មាន ខ្លះអុកឡុកក្នុងសហករណ៍ ខ្លះធ្វើសកម្មភាពមិនគប្បី ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ប្រជាជន។

[១៤:២២:១៩]

បក្សកុម្មុយនីស្តកម្ពុជាអប់រំកសាង គេញឹកញាប់ណាស់ ឲ្យគេទៅជាអ្នកស្នេហាជាតិ តែអប់រំកសាងមិនបានទាំងអស់ដែរ។ អ្នកដែលអប់រំកសាងមិនបាន ភាគច្រើនជាពួកចារកម្ម ចូលបង្កប់ក្នុងសហករណ៍ និងជាពួកអាវ៉ាសែ ធ្លាប់ស៊ីផឹកកាប់ចាក់ ពួកចូលទៅក្នុងកងទ័ព ក៏ដើម្បីបំផ្លាញសហករណ៍ បំផ្លាញកងទ័ពពីខាងក្នុង។ ឆ្នាំ១៩៧២ ខែកុម្ភៈ តាមសេចក្តីរាយការណ៍របស់គណៈកម្មការជនភៀសសឹករបស់សភាសហរដ្ឋថា ក្នុងខណៈនេះប្រជាជនខ្មែរប្រមាណជាពីរលាននាក់ មិនមានកន្លែងរស់នៅ ហើយខ្វះស្បៀងបរិភោគទៀតផង។ ម៉្យាងទៀត បក្សវៀតណាមប្រាប់បក្សកម្ពុជាថា ឃីស៊ីងហ្គ័ គំរាមថា បើបក្សកម្ពុជាមិនសុខចិត្តឈប់បាញ់ទេ អាមេរិកកម្ទេចទីទាំងកម្ពុជាក្នុង៧២ម៉ោង ដោយយន្តហោះបេ៥២។ ពេលនោះក្រៅពីយន្តហោះបេ៥២ ទម្លាក់គ្រាប់បែករាល់ថ្ងៃរាល់យប់ហើយ នៅមានយន្តហោះអេហ្វ៥ ហោះយាមល្បាតសង្កេតការណ៍ទាំងថ្ងៃទាំងយប់ទៀតផង។

[១៤:២៣:៥៦]

នៅទីក្រុងភ្នំពេញកាន់តែអត់អង្ករ អត់ស្បៀង អត់ថ្នាំពេទ្យ មានការឆក់ប្លន់រាល់ថ្ងៃ។ អសន្តិសុខចាប់ផ្តើមមានជាទូទៅនៅក្រុងភ្នំពេញ។ បន លន់ នល់ មិនអាចកាន់កាប់ស្ថានការណ៍ទាំងនេះបានទេ។

ក្នុងខែឧសភា នេះដែរ សភាជាន់ខ្ពស់សហរដ្ឋបានប្រជុំ មានសំឡេងភាគច្រើនលើសលប់ ឲ្យកាត់ថវិកាដែលប្រើសម្រាប់ទម្លាក់គ្រាប់បែកនៅកម្ពុជា តែដោយការសម្រុះសម្រួលជាមួយប្រធានាធិបតី ក៏បានឲ្យបន្តការទម្លាក់គ្រាប់បែកដល់ត្រឹមកណ្តាលខែសីហា ឆ្នាំ១៩៧៣។

គោរពលោកប្រធាន! ខ្ញុំហាត់សូមអនុញ្ញាតសម្រាក១៥នាទី។

[១៤:២៥:០១]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ឥឡូវនេះពេលវេលាក៏សមល្មមនឹងសម្រាកដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅកន្លែងកៅអីរបស់គាត់នៅក្រោយមេធាវីរបស់គាត់ ហើយនិងឲ្យនាំគាត់ត្រឡប់មកវិញ មុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

*(សវនាការសម្រាកពីម៉ោង ១៤:២៦ នាទី ដល់ម៉ោង ១៤:៤៧ នាទី)*

[១៤:៤៧:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសូមផ្តល់វេទិកាជូនទៅលោក នួន ជា ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។

សូមអញ្ជើញ!

**លោក នួន ជា៖**

វីរភាពដ៏ខ្លាំងក្លារបស់សម្តេចព្រះសីហនុ។ ខែមេសា ឆ្នាំ១៩៧៣ សហរដ្ឋអាមេរិកកំពុងទម្លាក់គ្រាប់បែកតាមយន្តហោះ ប េ៥២ លើកទឹកដីកម្ពុជាយ៉ាងសាហាវឃោរឃៅបំផុត។ សម្តេចព្រះនរោត្តមសីហនុ ពេលនោះគង់នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។ ព្រះអង្គបានទាក់ទងឲ្យរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដើម្បីព្រះអង្គ និងអ្នកម្នាងយាងព្រះរាជដំណើរមកទស្សនាមាតុភូមិរបស់ព្រះអង្គនៅប្រាសាទអង្គរវត្ត និងសួរសុខទុក្ខកូនចៅព្រះអង្គផង។

[១៤:៤៨:៤៨]

ប៉ុល ពត ក្នុងឋានៈជាលេខាបក្ស និងជានាយករដ្ឋមន្ត្រីបានប្រជុំសម្ងាត់ជាមួយអ្នកដឹកនាំសំខាន់ៗមួយចំនួន ដើម្បីសម្រេច។ មានបញ្ហាមួយសំខាន់ គឺវៀតណាមមិនយល់ព្រមឲ្យចិនជូនដំណើរព្រះអង្គដោយអាងលេសថា ខ្លាចបែកផ្លូវលំហូជីមិញ តែការពិត វៀតណាមចង់ដណ្ដើមយកឥទ្ធិលដោយឧត្តមសេនីយ៍វៀតណាម និងកងទ័ពវៀតណាមជូនដំណើរព្រះអង្គវិញ។

ដូច្នេះ វៀតណាមទទួលភារកិច្ចជូនដំណើរព្រះអង្គមកតាមផ្លូវហូជីមិញ ដល់ព្រំដែនកម្ពុជាកាត់ទន្លេមេគង្គ ស្ទឹងត្រែង។ គណៈប្រតិភូកម្ពុជាទៅទទួលព្រះអង្គនៅស្ទឹងត្រែង។ ប៉ុល ពត ទទួលខុសត្រូវក្នុងភារកិច្ចនេះ ពេលព្រះអង្គយាងមកដល់ខេត្តព្រះវិហារ លេខាបក្សលេខាបក្ស និងកងទ័ពបដិវត្តន៍កម្ពុជាទទួលភារកិច្ចការពារព្រះអង្គយ៉ាងម៉ឺងម៉ាត់បំផុត។ លេខា ប៉ុល ពត បានឲ្យខ្ញុំ នួន ជា ទៅរៀបចំផ្លូវពីកំពង់ត្រ ខេត្តព្រះវិហារទៅដល់ប្រាសាទអង្គរវត្ត មានព្រះសង្ឃ កម្មាភិបាល កងទ័ពបដិវត្តន៍ និងប្រជាជនមកទទួលគ្រេកអរសាទរព្រះអង្គយ៉ាងកុះករពាប់ពាន់នាក់ ដោយសេចក្ដីស្វាមីភក្ដិនឹករឭកយ៉ាងខ្លាំង។ ព្រះសង្ឃសូត្រធម៌ថ្វាយព្រះពរជ័យព្រះអង្គ និងអ្នកម្នាង។ ពេលនោះ បើទោះបីជាមានយន្តហោះហ្វេស៥ និងបេ៥២ ហោះសង្កេតការណ៍យ៉ាងណាក៏ដោយក៏មិនបានបង្អាក់បន្ទុចព្រះរាជពិធីស្វាគមន៍ព្រះអង្គឡើយ។

[១៤:៥១:១៨]

បក្សកុម្មុយនីស្តកម្ពុជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានសមត្ថភាពគ្រប់គ្រាន់ ការពារសន្តិសុខថ្វាយព្រះអង្គ ពេលព្រះអង្គគង់នៅក្នុងព្រៃដំណាក់លើភ្នំរហូតដល់ព្រះអង្គយាងត្រឡប់ទៅប្រទេសចិនបន្តព្រះរាជសកម្មភាពរំដោះជាតិមាតុភូមិព្រះអង្គតទៅទៀត។ បើគិតតាំងពីខែកុម្ភៈ ឆ្នាំ១៩៧៣ ដល់ពាក់កណ្ដាលខែសីហា ១៩៧៣ សហរដ្ឋទម្លាក់គ្រាប់បែក បេ៥២ ជាប់គ្នាពីររយថ្ងៃពីររយយប់ នៅក្នុងទឹកដីកម្ពុជាដែលមិនធ្លាប់មានទេក្នុងលោកនេះ។ បើគិតជាចំនួនតោនមិនដឹងជាប៉ុន្មានពាន់ ប៉ុន្មានម៉ឺនតោនទេ។ តាមទំហំនៃការទម្លាក់គ្រាប់បែកយ៉ាងព្រៃផ្សៃរបស់សហរដ្ឋអាមេរិកយ៉ាងនេះ តើប្រជាជនខ្មែរ ភូមិដ្ឋាន វត្តអារាម សាលារៀន សេដ្ឋកិច្ចខ្មែរខូចខាតប៉ុន្មានទៅ? យើងមិនអាចប៉ាន់ប្រមាណបានតែប្រជាជនខ្មែរនៅតែសាមគ្គីងើបឡើងតស៊ូតទៅទៀតយ៉ាងអង់អាចក្លាហានរហូតដល់បានជ័យជម្នះជាបន្តបន្ទាប់ឈានពីជ័យជម្នះមួយទៅកាន់ជ័យជម្នះមួយថ្មីទៀត។

[១៤:៥៣:០២]

ពេលនោះ កងកម្លាំងបដិវត្តន៍កម្ពុជាចេះតែវាយសម្រុកចូលទៅជិតទីក្រុងភ្នំពេញ នៅចម្ងាយពី

វាលយន្តហោះពោធិ៍តុងប្រមាណជា ៦០គីឡូ ខាងទិសពាយ័ព្យ។ ចុងឆ្នាំ១៩៧៤ គណៈមជ្ឈិមបក្សមិនពេញអង្គមួយបានប្រជុំទៀត គឺធ្វើសេចក្ដីសម្រេចចិត្តវាយរំដោះភ្នំពេញ ក្នុងឆ្នាំ១៩៧៥។ អង្គប្រជុំបានសម្រេចយកថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ជាថ្ងៃចាប់ផ្ដើមប្រតិបត្តិការណ៍វាយផ្ដាច់ព្រ័ត្រចុងក្រោយរបស់ខ្លួន។

បក្សបានសម្រេចឲ្យលេខា ប៉ុល ពត និង នួន ជា ទៅចរចាជាមួយ ង្វៀន វ៉ាន់លិញ ប្រាប់ឲ្យគេដឹងពីផែនការវាយរំដោះភ្នំពេញក្នុងឆ្នាំ១៩៧៥ ហើយស្នើសុំឲ្យបក្សវៀតណាមជួយដឹកអាវុធដែលជាជំនួយចិនឲ្យដប់បីឡានតុងហ្វាំង ឲ្យបានឆាប់ព្រោះយើងដឹងថាអាវុធមកដល់យូរខែដែរហើយ តែបក្សវៀតណាមមិនទាន់ប្រគល់ឲ្យ។

[១៤:៥៤:៣៤]

តែយន្តហោះខ្មាំងបីគ្រឿងមកទម្លាក់គ្រាប់បែកចំឡានដាក់អាវុធផ្ទុះខ្ទេចទាំងអស់។ បំបែងគ្រប់បែកហោះទៅចំរោងចក្រក្រដាសនៅឆ្លូងថែមទៀត។ ដើម្បីដឹកនាំការប្រយុទ្ធវាយផ្ដាច់ព្រ័ត្ររំដោះភ្នំពេញឲ្យមានប្រសិទ្ធភាព ប៉ុល ពត លេខាបក្សទៅនៅប្រចាំការជិតសមរភូមិឯភ្នំពេញ គឺនៅភូមិបឹងតាឡុងខាងត្បូងភូមិច្រកស្ដេច ឃុំពាម ឃុំកំពង់ត្រឡាច។ ពេលកងទ័ពបដិវត្តន៍ចូលទៅជិតភ្នំពេញ ប៉ុល ពត ទៅនៅឃុំក្រាំងដូង ហៅ ប-៥ ជាប់ឃុំពាម ស្រុកកំពង់ត្រឡាច នៅភូមិចាន់ទី។ កម្មាភិបាលសមរភូមិភ្នំពេញទៅមកវាយការណ៍រាល់ថ្ងៃ។ ពេលនោះ នួន ជា នៅសមរភូមិក្រោយ នៅមាត់ស្ទឹងជីនិត ដើម្បីបើកវគ្គអប់រំកម្មាភិបាលគ្រប់ភូមិភាគជាប្រចាំ ព្រោះក្រោយរំដោះភ្នំពេញក៏ដូចរំដោះទូទាំងប្រទេស។ បក្សត្រូវការចំនួនកម្មាភិបាលដឹកនាំច្រើនណាស់ទើបដោះស្រាយបញ្ហាបាន ជាពិសេសបញ្ហាគ្រប់គ្រងប្រជាជនបានផងដែរ។

[១៤:៥៦:០៧]

ថ្ងៃទី១៧ ខែមេសា ១៩៧៥ កងទ័ពបដិវត្តន៍កម្ពុជាបានរំដោះទីក្រុងភ្នំពេញនៅវេលាម៉ោងប្រាំបួនសាមសិបនាទីព្រឹក។ វិទ្យុរណសិរ្សរួបរួមកម្ពុជាបានផ្សាយដំណឹងនេះនៅពេលរសៀល ដោយបានប្រកាសថា "ទីក្រុងភ្នំពេញបានរំដោះទាំងស្រុងហើយ នៅវេលាម៉ោងប្រាំបួននិងសាមសិបនាទីព្រឹក"។ សភាពការណ៍ ក្រោយពេលរំដោះភ្នំពេញភ្លាម គឺកងទ័ព លន់ នល់ មួយចំនួនក្រោមការដឹកនាំរបស់ចន្ទរង្សី រត់ទៅព្រំដែនថៃ ដើម្បីទៅរៀបចំកម្លាំងពីព្រំដែនថៃ បង្កការចលាចលនៅខាងបាត់ដំបង។ កងទ័ពមួយផ្នែកទៀត រត់ទៅព្រំដែនវៀតណាមខាងត្បូងដោយមាន សឺង ង៉ុកថាញ់ រង់ចាំនៅវៀតណាមខាង

ត្បូងពីរខែមុនហើយ។ កងទ័ពមួយផ្នែកទៀតនៅទីក្រុងភ្នំពេញ ដោយពួននៅតាមផ្ទះដែលមានដាក់បារខ្សាច់ធ្វើជាបារ៉ែតការពារ។

[១៤:៥៧:២៣]

មានពួកទាហានមួយចំនួនរបស់ លន់ នល់ ក្លែងខ្លួនស្លៀកខ្មៅពាក់ខ្មៅ ធ្វើដូចជាកងទ័ពបដិវត្តន៍កម្ពុជាដើរចាប់អ្នករាជការចាស់ សម័យ លន់ នល់ មន្ត្រីស៊ីវិល ទាហាន ដោយបោកបញ្ឆោតថា "ទៅគាល់សម្តេចសីហនុ" តែពួកវាយកអ្នកទាំងនោះទៅសម្លាប់ចោលអស់ជាចំនួនច្រើន។ ម៉្យាងទៀត ពួកក្លែងខ្លួនធ្វើជាកងទ័ពបដិវត្តន៍នេះ ដើរឧបាយកលស៊ើបរកមនុស្ស ដែលមានបងប្អូនធ្វើកម្មាភិបាលដឹកនាំបដិវត្តន៍ ហើយវាបញ្ឆោតថា "វាទាក់ទងជាមួយកម្មាភិបាលនោះបាន បើចង់ទាក់ទងចង់ជួប វាជួយដោះស្រាយឲ្យបាន"។ អ្នកដែលត្រូវពួកខូចដែលវាបោកបញ្ឆោតនេះជឿតាមវាក៏ប្រាប់វាអស់ថា "មានអ្នកនេះអ្នកនោះជាបងប្អូនធ្វើកម្មាភិបាលបដិវត្តន៍ ដល់វាដឹងហើយ វាក៏ដាក់វិធានការសម្លាប់អ្នកនោះចោលទាំងគ្រួសារៗ"។ នៅទីក្រុង ហាណូយ វៀតណាមមិនជឿថា "ភ្នំពេញបានរំដោះ" ទេ។

[១៤:៥៨:៤៤]

សមមិត្ត អៀង សារី ខ្លួនឯងដែលនៅពេលនោះស្ថិតនៅទីក្រុងហាណូយ បានប្រាប់វៀតណាមថា ទីក្រុងភ្នំពេញបានរំដោះហើយ ប៉ុន្តែវៀតណាមនៅតែមិនជឿទៀត។ វៀតណាមមិនចង់ជឿរឿងនេះទេ ម៉្យាងដោយសារការរំដោះទីក្រុងភ្នំពេញ មុនពេលកាលរំដោះទីក្រុងព្រៃនគរ បានធ្វើឲ្យខូចខាតដល់សេចក្តីសង្ឃឹមរបស់គេក្នុងការសម្រេចបាននូវផែនការរបស់ពួកគេក្នុងការកាន់កាប់កម្ពុជា។

ហើយម៉្យាងទៀតនេះ គឺជាការវាយប្រហារយ៉ាងឈឺចាប់ចំពោះកិត្តិយសរបស់វៀតណាម។ មេដឹកនាំវៀតណាមនៅទីក្រុងហាណូយនៅពេលនោះ មានការខឹងសម្បាយ៉ាងខ្លាំង ដោយសារតាំងពីខែឧសភា ដល់ខែធ្នូ ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍និងកងទ័ពវៀតណាមកុម្មុយនីស្តបានប៉ះទង្គិចគ្នាជាញឹកញាប់នៅតាមកោះផង នៅតាមជាយដែនខ្មែរវៀតណាមផង។ ដូច្នោះសម្ព័ន្ធភាព មិត្តភាពរវាងកម្ពុជានិងវៀតណាមមិនបានដំណើរការទៅតាមធម្មតាទេ។

[១៥:០០:១៣]

នៅខែមិថុនា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជូនគណៈប្រតិភូជាន់ខ្ពស់ទៅកាន់ទីក្រុងហាណូយ។ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដឹងមុនថា មានបញ្ហាស្មុគស្មាញជាច្រើនដែលត្រូវចរចា ដោះស្រាយជាមួយបក្សកុម្មុយនីស្តវៀតណាម។ តែខាងកម្ពុជាត្រូវតែ

ប្រកាន់អាកប្បកិរិយាអត់ធ្មត់ និងរក្សានូវសាមគ្គីភាព មិត្តភាពឲ្យបានល្អ។ ពេលគណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជាសម្រាកនៅផ្ទះទទួលភ្ញៀវ នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង និងមេបញ្ជាការកងទ័ពប្រជាជនវៀតណាម វ៉ៃ ង្វៀន យ៉ាប ទៅសួរសុខទុក្ខ។ ពេលនោះ ផាំ វ៉ាន់ដុង និយាយថា ជ័យជម្នះរបស់កម្ពុជាគឺអស្ចារ្យណាស់។ វ៉ៃ ង្វៀន យ៉ាប សួរ ប៉ុល ពត ថា "តើដីកម្ពុជាអាចបង្កើនផលបានប៉ុន្មានហិកតា?" ប៉ុល ពត ថា "ប្រហែលជាងប្រាំបីលានហិកតា តែដីដែលល្អមានប្រហែលជាងបីលានហិកតា"។ វ៉ៃង្វៀន យ៉ាប ថា "*ង័នក្វា*" ជាភាសាខ្មែរមានន័យថា "ឆ្ងាញ់ណាស់"។ ខ្ញុំគិតពាក្យពីរម៉ាត់របស់ ផាំ វ៉ាន់ដុង និង វ៉ៃ ង្វៀន យ៉ាប សុទ្ធតែមានន័យជ្រៅ។

[១៥:០១:៥២]

ក្នុងឱកាសចរចាជាមួយវៀតណាម គណៈប្រតិភូបក្សកុម្មុយនីស្តកម្ពុជាស្នើសុំឲ្យមានការចុះហត្ថលេខារវាងភាគីទាំងពីរកម្ពុជា-វៀតណាម សន្ធិសញ្ញាមិត្តភាព និងមិនឈ្លានពានគ្នាដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក ដើម្បីឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដី មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក និងដើម្បីផលប្រយោជន៍រវាងទៅវិញទៅមក។ សន្ធិសញ្ញាបែបនេះអាចនាំទៅដោះស្រាយបញ្ហាផ្សេងៗបានជាបណ្តើរៗ ប៉ុន្តែភាគីវៀតណាមមិនបាននិយាយអ្វីទាំងអស់ទាក់ទងនឹងបញ្ហាដែលភាគីកម្ពុជាស្នើ។ ការចរចាមិនបានចេញជាលទ្ធផលអ្វីទាំងអស់។ ការណ៍ដែលវៀតណាមមិនបានឆ្លើយតបនូវសំណូមពររបស់ភាគីកម្ពុជា ព្រោះវៀតណាមត្រូវការឲ្យមានរបស់ដែលហៅថា "មិត្តភាពពិសេសជាមួយបដិវត្តន៍កម្ពុជា" ដែលខ្លឹមសារពិតរបស់វា គឺ "សហព័ន្ធឥណ្ឌូចិន" នោះឯង។

[១៥:០៣:១៨]

ខែសីហា ១៩៧៥ ឡេ យន់ អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម នាំគណៈប្រតិភូមាន ឡេ ឌឹក ថ, ស៊ុន ធុយ, សមាជិកការិយាល័យនយោបាយ និង ង្វៀន វ៉ាន់ លិញ មកធ្វើទស្សនកិច្ចនៅកម្ពុជា តែការចរចានៅតែមិនបានផលអ្វី ព្រោះភាគីវៀតណាមទាមទារធ្វើមិត្តភាពពិសេស ឯភាគីកម្ពុជានៅរក្សាគោលជំហរឯករាជម្ចាស់ការ គោរពគ្នាទៅវិញទៅមក ដោយស្មើភាព។

[១៥:០៤:00]

១៩៧៦ ខែឧសភា មានការប្រជុំរវាងគណៈប្រតិភូកម្ពុជាប្រធិបតេយ្យ និងគណៈប្រតិភូវៀត-ណាមកុម្មុយនីស្ត។ ខាងវៀតណាមិនសុខចិត្តទទួលស្គាល់ខ្សែបន្ទាប់ប្រេប៊ីយ៉េ ដែលបារាំងគូសកាលសម័យ

បារាំងត្រួតត្រាកម្ពុជា។ ការប្រជុំមិនបានផលសម្រេចអ្វី ក៏ផ្អាកសិនទុកនិយាយគ្នាថ្ងៃក្រោយទៀត។

ការប្រយុទ្ធគ្នារវាងកងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពវៀតណាមកុម្មុយនីស្តនៅតែមានបន្តទៅទៀត ជាពិសេសតាមជាយដែនខាងរតនគិរី មណ្ឌលគិរី ខាងបូព៌ា និងខាងភូមិភាគនិរតី។

មានការជួបចរចាគ្នារាល់លើក ដែលមានការប្រយុទ្ធគ្នា តែមិនបានដោះស្រាយជាស្ថាពរទេ ព្រោះទាំងសងខាងរក្សានូវគោលជំហររបស់ខ្លួន។ វៀតណាមនៅតែរក្សាមហិច្ឆតាឈ្លានពានវាតទីលេបទឹកដីកម្ពុជា ឯកម្ពុជារក្សានូវគោលជំហរឯករាជ្យ ម្ចាស់ការ មិនសុខចិត្តធ្វើជារណបវៀតណាម។

ឆ្នាំ១៩៧៧ ខែកុម្ភៈ វៀតណាមបានព្យាយាមធ្វើរដ្ឋប្រហាររំលំកម្ពុជា ប្រជាធិបតេយ្យទៀត តែមិនបានសម្រេច។ នៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានវាយប្រហារដោយទ្រង់ទ្រាយធំ ដើម្បីឈ្លានពានកម្ពុជាប្រជាធិបតេយ្យ។ ពួកគេបានប្រើកម្លាំងយោធា១៤កងពល ដែលរួមទាំងកងពលពិសេសចំនួន៥កងពលផង តែត្រូវបានវាយបកវិញពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ តែនៅខាងភូមិភាគបូព៌ាមានកងទ័ពកម្ពុជាប្រជាធិបតេយ្យមួយចំនួនរត់ចោលជួរ ដោយមានពួកក្បត់បង្កប់ក្នុងកងទ័ពបម្រើនយោបាយបំបែកបំបាក់របស់វៀតណាម។

១៩៧៨ ខែវិច្ឆិកា វៀតណាមកុម្មុយនីស្តបានខំព្យាយាមធ្វើរដ្ឋប្រហារដោយមាន វន វ៉េត ចូលរួម តែត្រូវបរាជ័យ។ ថ្ងៃទី៧ មករា ១៩៧៩ កងទ័ពវៀតណាមកុម្មុយនីស្តឈ្លានពានចំនួន២សែន៥ម៉ឺនក្បាល ចូលដល់ទីក្រុងភ្នំពេញ និងខេត្តខ្លះទៀតនៅកម្ពុជាប្រជាធិបតេយ្យ។ តាមទស្សនៈគោលជំហរអត្តចរិតរបស់វៀតណាមដែលមានមកជាច្រើនសតវត្សរ៍ហើយនេះ អ្នកផងចោទសួរថា តើហេតុផលដែលវៀត-ណាមអាងហេតុផលមករំដោះកម្ពុជា ការពារសិទ្ធិមនុស្ស និងចូលមកឈ្លានពានកម្ពុជាដោយស្របតាមច្បាប់ជាតិអន្តរជាតិនោះវាត្រឹមត្រូវឬទេ?

[១៥:០៧:១២]

វៀតណាមអាងថា ការលើកកងទ័ពចូលឈ្លានពានកម្ពុជាជាការត្រឹមត្រូវស្របច្បាប់មួយ។ ក៏ប៉ុន្តែការដែលវៀតណាមលើកកងទ័ពចូលឈ្លានពានកម្ពុជា កាលថ្ងៃទី៧ មករា ជាការល្មើសច្បាប់អន្តរជាតិ ព្រោះវាមិនចូលក្នុងករណីមាត្រា៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ក្នុងរឿងការពារខ្លួនដោយខ្លួនឯង ឬដោយរួមជាមួយរដ្ឋាភិបាល ដែលស្របច្បាប់ស្នើសុំឲ្យបរទេសជួយនោះទេ។ ប្រទេសទាំងឡាយលើសកលលោក គេប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម។ ក្នុងរយៈ១០ឆ្នាំមក នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ប្រទេសជាសមាជិកមានមតិឲ្យវៀតណាមត្រូវតែដកកម្លាំងទាំង

អស់ចេញពីកម្ពុជា។ មតិអន្តរជាតិក៏ប្រឆាំងនឹងអំពើឈ្លានពានរបស់កងទ័ពវៀតណាមកុម្មុយនីស្ត ហើយទាមទារឲ្យកងទ័ពវៀតណាមកុម្មុយនីស្តដកចេញពីកម្ពុជាឲ្យអស់។

[១៥:០៨:២៥]

កងទ័ពវៀតណាមកុម្មុយនីស្ត និងកម្មាភិបាលវៀតណាម នៅតែរស់នៅដោយស្ងាត់នៅកម្ពុជាតទៅទៀត ដើម្បីធ្វើសកម្មភាពក្តោបក្តាប់ប្រទេសកម្ពុជាតាមមហិច្ឆតា ឈ្លានពាន វាតទី លេបទឹកដី បំបាត់ពូជសាសន៍កម្ពុជា ហើយកាន់តែថែមជនអន្តោប្រវេសន៍ស្របច្បាប់ និងខុសច្បាប់ចូលមករស់នៅក្នុងទឹកដីកម្ពុជារហូតដល់សព្វថ្ងៃនេះ។ ថែមលើនេះទៀត សាធារណរដ្ឋសង្គមនិយមវៀតណាម បានដាក់អង្គការសមាគមវៀតណាម នៅតាមខេត្តផ្សេងៗជាច្រើននៅកម្ពុជា។ ធាតុពិតនៃសមាគមនេះគឺមានសាខាបក្សកុម្មុយនីស្តវៀតណាមដឹកនាំ សម្រាប់ធ្វើសកម្មភាពនយោបាយ សេដ្ឋកិច្ច យោធា មនោគមវិជ្ជា នៅតាមខេត្តនៃប្រទេសកម្ពុជា។ នេះជាយុទ្ធវិធីពស់ថ្លាន់រឹបរួតកូនឈ្លូសឲ្យទន់ឆ្អឹង ហើយលេបយកតែម្តង។

[១៥:០៩:៤២]

ក្នុងសៀវភៅ “ស្រីហិតោបទេស” មានភាសិតមួយសរសេរថា “កុំជឿបរទេស កុំជឿអភិនេស កុំជឿអភិប្រាយ”។ សុំលើកយកសម្តីឈ្មោះ ឡេ ឌឹក ថ សមាជិកការិយាល័យនយោបាយបក្សកុម្មុយ-នីស្តវៀតណាមនិយាយទៅកាន់លោក ប៉ែន សុវណ្ណ អតីតនាយករដ្ឋមន្ត្រីសម័យសាធារណរដ្ឋខ្មែរ ពេលដែល ប៉ែន សុវណ្ណ ត្រូវយួនចាប់យកទៅដាក់គុកក្នុងទីក្រុងហាណូយ។ នៅម៉ោងបួនព្រឹក នៅថ្ងៃទី១៣ ធ្នូ ឆ្នាំ១៩៨១ លោក ឡេ ឌឹក ថ សមាជិកការិយាល័យនយោបាយមជ្ឈិមបក្សកុម្មុយនីស្តវៀតណាមចូលដល់កន្លែងឃុំឃាំង។ ចំណែក ប៉ែន សុវណ្ណ មិនបានដឹងខ្លួនជាមុន ពេលនោះ ប៉ែន សុវណ្ណ អង្គុយត្រៀបលើតុ ស្រាប់តែលើស្ងរទះតុម៉ាំង ធ្វើឲ្យ ប៉ែន សុវណ្ណ ភ្ញាក់ព្រើត។ លោក ឡេ ឌឹក ថ បានលើកដៃចង្អុលមុខ ប៉ែន សុវណ្ណ ហើយចេញសម្តីខ្លាំងៗថា ខ្ញុំស្មានមិនបានថា អ្នកឯងហ៊ានប្រឆាំងជាមួយយើងខ្ញុំ។ អ្នកឯងដឹងទេ សព្វថ្ងៃកងទ័ពយើងខ្ញុំមាន និងកំពុងនៅលើប្រទេសអ្នកឯង ចំនួន១៨ពាន់នាក់។

អ្នកឯងកុំស្មានថាចង់ដោះស្រាយវា វាសនាប្រទេសអ្នកឯងតាមទំនើងចិត្ត។ ពិតមែនប្រទេសអ្នកឯងបានចាត់តាំងជារចនាសម្ព័ន្ធ ជារូបរាងបក្សនិងរដ្ឋមែនពិត ប៉ុន្តែមិនហួសពីរង្វង់ដៃរបស់យើងខ្ញុំដែរ អ្នកឯងចាំមើលថ្ងៃក្រោយ ទោះបីគ្មានកងទ័ពយើងខ្ញុំបោះប្រចាំលើប្រទេសអ្នកឯងក៏ដោយ បើមានអ្នកណាហ៊ានកម្រើកចេញពីរង្វង់ដៃយើងខ្ញុំ យើងខ្ញុំនឹងច្របាច់ឲ្យហ្មត់ តាំងពីកកើតក្នុងពងម្ល៉េះ។ អ្នក

ឯងបានរៀនទ្រឹស្តីច្រើនជាងគេទាំងអស់ ប៉ុន្តែពេលអ្នកឯងកាន់អំណាច អ្នកឯងកសាងប្រទេស កសាងសេដ្ឋកិច្ចជាតិ ចាកចេញពីរបបកុម្មុយនីស្ត និងបោះបង់ចោលលទ្ធិសង្គមនិយម។ នេះហើយ រាល់អ្នកជំនាញការយើងខ្ញុំ ចុះទៅជំនួញនៅប្រទេសអ្នកឯង គេមិនប៉ានធ្វើអ្វីតាមអ្នកឯង ពីព្រោះអ្នកឯងប្រាសចាកក្រឹត្យក្រមនៃសេដ្ឋកិច្ចសង្គមនិយម ព្រោះតែមូលហេតុនេះហើយ បានជាបក្សរបស់អ្នកឯងបណ្តេញនិងបដិសេធមិនឲ្យអ្នកឯងដឹកនាំបក្សនិងរដ្ឋាភិបាល។ គេធ្វើដូច្នេះហើយ ទើបសមនឹងអំពើអ្នកឯង ដែលដឹកនាំអនុវត្តខុសគន្លងសង្គមនិយម។ ដោយទោសកំហុសទាំងនេះ ខ្ញុំសូមប្រកាសឲ្យអ្នកឯងរស់នៅទីនេះហើយគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ អស់មួយជីវិត។

[១៥:១៣:០៨]

មូលហេតុដែលបក្សកុម្មុយនីស្តកម្ពុជា ត្រូវបង្ខំចិត្តជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្ត។ ខែឧសភា ឆ្នាំ១៩៧៣ សភាជាន់ខ្ពស់សហរដ្ឋអាមេរិក បានចុះមតិភាគច្រើនលើសលប់ឲ្យរដ្ឋាភិបាលអាមេរិកឈប់ទម្លាក់គ្រាប់បែកជាស្ថាពរនៅលើទឹកដីកម្ពុជា ចាប់តាំងពីពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៣ ទៅ។ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានវិភាគឃើញច្បាស់ថា បើគ្មានជំនួយខាងយោធា ខាងជើងអាកាសពីសហរដ្ឋទេ ការតស៊ូរំដោះជាតិរបស់ប្រជាជនកម្ពុជានឹងឈានទៅកាន់ជ័យជម្នះក្នុងពេលឆាប់ៗ ខាងមុខនេះជាមិនខាន ព្រោះកងទ័ព លន់ នល់ កាន់តែទន់ខ្សោយខ្លាំងណាស់ហើយ។ ផ្ទៃក្នុងនៃរដ្ឋាភិបាល លន់ នល់ មានទំនាស់គ្នាដោះស្រាយមិនរួច។

[១៥:១៤:២០]

ប្រជាជនកម្ពុជាដែលរស់នៅក្នុង លន់ នល់ កាន់តែប្រឆាំងនឹងរបបសាធារណរដ្ឋ លន់ នល់ ខ្លាំងៗឡើងជារៀងរាល់ថ្ងៃ។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានតាមដានសភាពការណ៍គ្រប់ផ្នែកនៅកម្ពុជាយ៉ាងជិតស្និទ្ធ ក្នុងការប្រជុំគណៈអចិន្ត្រៃយ៍បក្សមិនពេញអង្គមួយ និងនៅពាក់កណ្តាលឆ្នាំ១៩៧៤ អង្គប្រជុំបានលើកបញ្ហាសំខាន់ៗមួយចំនួនមកពិភាក្សាដើម្បីមានវិធានការមុនពេលណារំដោះបានទីក្រុងភ្នំពេញនិងទូទាំងប្រទេស។ របៀបវារៈសំខាន់ៗដែលអង្គប្រជុំលើកឡើងនោះ នាពេលនោះមានជាអាទិ៍គឺ៖

១)មហិច្ឆតាចាត់តាំងសហព័ន្ធឥណ្ឌូចិនក្រោមការត្រួតត្រារបស់វៀតណាម។

២)តើសហរដ្ឋមានវិធានការយ៉ាងណា បើប្រសិនណាជាវៀតណាមវាយលុកកម្ពុជាពេលកម្ពុជាបានរំដោះ។

៣)ការបំផ្លិចបំផ្លាញវិទ្ធង្សនារបស់កងទ័ព លន់ នល់ នៅទីក្រុងភ្នំពេញ និងពួកបាក់ទ័ពដែលរត់ទៅជ្រកនៅជាយដែនថៃ និងវៀតណាមខាងត្បូង។

៤)សភាពការណ៍អត់បាយនៅទីក្រុងភ្នំពេញតាំងពីដើមឆ្នាំ១៩៧៤ មានសភាពយ៉ាងណា។

៥)សភាពការណ៍បង្កបង្កើនផលតាមជនបទ និងសហករណ៍មានសភាពយ៉ាងណា។

៦)ប៉ាន់ប្រមាណមុន អំពីសកម្មភាពបំផ្លាញរបស់ពួកក្បត់បង្កប់ក្នុងផ្ទៃក្នុងបក្ស ក្នុងផ្ទៃក្នុងសហករណ៍។

៧)បើមិនទាន់ចាយលុយ តើមានផលល្អ ផលអាក្រក់យ៉ាងណាចំពោះមុខនេះ។

៨)បញ្ហាផ្សេងៗ។

[១៥:១៦:៣៦]

ក្នុងការប្រជុំពិភាក្សាគ្នាសាចុះសាឡើងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះជាតិ ចំពោះប្រជាជនក្នុងពេលបច្ចុប្បន្ន និងអនាគត អង្គប្រជុំបានឯកភាពលើចំណុចរបៀបវារៈនីមួយៗដូចតទៅនេះ។ របៀបវារៈខទីមួយ វៀតណាមមិនបង់បោះចោលមហិច្ឆតាចាត់តាំងសហព័ន្ធឥណ្ឌូចិន ឬមិត្តភាពពិសេសទេ ទោះជាកម្ពុជាបានរំដោះមុន ឬក្រោយវៀតណាមក៏ដោយ តែកម្ពុជាត្រូវខំវាយផ្តាច់ព្រ័ត្រឲ្យបានឈ្នះមុនវៀតណាម ព្រោះផែនការវៀតណាម គេមានផែនការរំដោះទីក្រុងព្រៃនគរក្នុងឆ្នាំ១៩៧៦។ បើវៀតណាមរំដោះព្រៃនគរបានមុនកម្ពុជា រំដោះភ្នំពេញ វៀតណាមពិតជាយកលេសថា មកជួយវាយរំដោះភ្នំពេញ។ វៀតណាមធ្លាប់និយាយជាញឹកញាប់ប្រាប់អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា ពួកសមមិត្តមិនវាយរំដោះភ្នំពេញទេ ពួកមិត្តត្រៀមអ្នកនាំផ្លូវឲ្យកងទ័ពវៀតណាមទៅបានហើយ វៀតណាមនឹងចូលវាយរំដោះភ្នំពេញតែក្នុងម្ភៃបួនម៉ោងប៉ុណ្ណោះ។ មតិនេះផ្សាយធំទូលាយទូទៅនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុល ពត អប់រំសមាជិកបក្សថា អ្នកណាគេធ្វើ អ្នកនោះគេចាត់ចែងវា។ ដូច្នោះ យើងត្រូវខំវាយឲ្យឈ្នះមុនវៀតណាមរំដោះព្រៃនគរ វៀតណាមមិនត្រឹមតែមានមហិច្ឆតាចាត់តាំងសហព័ន្ធឥណ្ឌូចិនប៉ុណ្ណោះទេ តាមឯកសារបរទេសខ្លះនិយាយថា នៅក្នុងសាលារៀន ង្វៀន អាយ គួក វៀតណាមនៅនិយាយអំពីគំនិតចាត់តាំងសហព័ន្ធសាធារណរដ្ឋអាស៊ី-អាគ្នេយ៍ទៀតផង។ ស្តែងឲ្យឃើញថាវៀតណាមមានមហិច្ឆតាធំទូលាយក្រៅពីឥណ្ឌូចិនទៅទៀត។

[១៥:១៨:៥០]

ឡៅ ឌឹក ថ សមាជិកប៉ូលិសប៊ុយរ៉ូបក្សកុម្មុយនីស្តវៀតណាម ពេលចរចាជាមួយ យីស៊ីងហ្គី

នៅទីក្រុងប៉ារីសឆ្នាំ១៩៦៨-១៩៧៣ និយាយថា វាជាព្រំលិខិត-- *ខេសធីនី* របស់វៀតណាម ដែលមានអំណាចគ្របដណ្ដប់មិនគ្រាន់តែឥណ្ឌូចិនប៉ុណ្ណោះទេ តែគ្របដណ្ដប់ទាំងអាស៊ី-អាគ្នេយ៍ទៀតផង។

កាលពីឆ្នាំ១៩៧៣ ផាំ វ៉ាន់ដុង នាយករដ្ឋមន្ត្រីសាធារណរដ្ឋសង្គមនិយមវៀតណាម ពេលនិយាយអំពីឋានៈ និងតួនាទីរបស់វៀតណាមនៅអាស៊ី-អាគ្នេយ៍ ផាំ វ៉ាន់ដុង និយាយដល់ប្រទេសថៃ ហ្វីលីពីន និងម៉ាឡាយូ ថាគង់តែរួមជាមួយវៀតណាម ព្រោះថាយើងប្រជាជនវៀតណាមមានកម្លាំងចិត្តខ្ពស់ជាង មានកម្លាំងច្រើនជាង ហើយឆ្លាតជាងទៀតផង។

[១៥:២០:០៦]

ដូច្នេះ មហិច្ឆតារបស់វៀតណាមក្នុងការចាត់តាំងសហព័ន្ធឥណ្ឌូចិនឬមិត្តភាពពិសេសវៀតណាមកម្ពុជា មិនមែនរឿងគ្រាន់តែថាចោលនោះទេ ថាវាជាការពិតដែលវៀតណាមត្រូវតែសម្រេចឲ្យបាន។

អំពីរបៀបវារៈទីពីរ និយាយអំពីសហរដ្ឋអាមេរិក។ អង្គប្រជុំបានវិភាគដោយឈរលើមូលដ្ឋាននៃទំនាស់រវាងសហរដ្ឋវៀតណាមនិងកម្ពុជា។ អង្គប្រជុំឯកភាពគ្នាថា បើបក្សកុម្មុយនីស្តកម្ពុជាដឹកនាំតស៊ូរំដោះជាតិ រំដោះប្រជាជនបាន គឺយើងសម្រេចបានភារកិច្ច ធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យបានមួយចំនួនសំខាន់ហើយ គឺយើងបានដោះស្រាយទំនាស់បដិបក្ខ គឺទំនាស់ស្លាប់រស់ ជាមួយសហរដ្ឋ និងបន លន់ នល់ បានជាដំបូង។ សហរដ្ឋមិននៅជាតួអង្គបដិបក្ខទៀតទេ។ ពេលនោះទំនាស់បដិបក្ខប្រែប្រួលហើយ តើអ្នកជាអ្នកទំនាស់បដិបក្ខ? អង្គប្រជុំបានវិភាគឯកភាពគ្នាថា គឺវៀតណាម ដែលយើងធ្លាប់ចាត់ទុកថា ជាមិត្តមានទំនាស់ និងក្លាយទៅជាទំនាស់បដិបក្ខទៅវិញ។ មូលហេតុគឺមកពីបក្សកុម្មុយនីស្តកម្ពុជា មិនសុខធ្វើជារណបវៀតណាម ហើយវៀតណាម គេមានមហិច្ឆតាត្រួតត្រាកម្ពុជា បើវៀតណាមគេឯកភាពប្រទេសជាតិគេពេលណា មហិច្ឆតាត្រួតត្រាកម្ពុជាក៏គាត់តែឡើងកម្រិតខ្ពស់ឡើង ព្រោះគេមានកម្លាំងកាន់តែខ្លាំង។ បើគេប្រើនយោបាយមិនបានសម្រេចទេ វៀតណាមមុខនឹងប្រើកម្លាំងយោធាវាយយកកម្ពុជាមិនខាន។

បញ្ហានេះ បក្សកុម្មុយនីស្តកម្ពុជាត្រូវម្ចាស់ការអប់រំផ្ទៃក្នុងបក្ស ក្នុងកងទ័ព ក្នុងប្រជាជន ឲ្យឃើញច្បាស់ថា វៀតណាមគឺជាតួអង្គនៃទំនាស់បដិបក្ខ គឺទំនាស់ស្លាប់រស់ តែបក្សកុម្មុយនីស្តកម្ពុជាត្រូវខិតខំដោះស្រាយគ្រប់បញ្ហាជាមួយវៀតណាមដោយសន្តិវិធី ដែលអាចដោះស្រាយបានជាក់ស្តែងគឺគ្រប់បញ្ហាទំនាស់ជាមួយវៀតណាម គឺត្រូវដោះស្រាយដោយការចរចា ដោយអត់ធ្មត់ អំណត់អត់ធ្មត់។

[១៥:២២:៥៣]

អំពីរបៀបវារៈខទីបី អង្គប្រជុំបានវិភាគឃើញថា បើយើងរំដោះបានភ្នំពេញកងទ័ព លន់ នល់ ដែលភាគច្រើនជាខ្មែរសេរី មុខជាបែកខ្ចាត់ខ្ចាយ ដោយមួយចំនួនសម្ងំនៅក្នុងទីក្រុង ហើយមួយចំនួនរត់ទៅព្រំដែនថៃ-កម្ពុជា។ ពួកបាក់ទ័ពទាំងនេះ គ្មានអ្វីសម្រាប់ផ្គត់ផ្គង់ជីវភាពបានទេ។ ពួកវាមុខជាលួច ឆក់ប្លន់ កាប់សម្លាប់ ដុតផ្ទះសម្បែងភូមិករណ៍របស់ប្រជាជនយើងជាមិនខាន យើងពុំមានកម្លាំងគ្រប់គ្រាន់ដើម្បីការពារប្រជាជនយើងបានទេ។ ពួកវានឹងប្រើវិធីវាយកងទ័ព វាយប្រជាជនយើងតាមបែបកងចោរព្រៃ ធ្វើឲ្យកងទ័ពយើងត្រូវរត់តាមវា ហើយប្រជាជនយើងក៏គ្មានសុខសន្តិភាពក្នុងការបង្កបង្កើនផល ឬក៏ប្រកបរបរចិញ្ចឹមជីវិតដែរ។

[១៥:២៤:២៣]

អំពីរបៀបវារៈខទីបួន បញ្ហានេះមានសារៈសំខាន់ណាស់ ព្រោះទាក់ទងនឹងស្រូវអង្ករ ស្បៀងអាហារសម្រាប់ប្រជាជនរាប់លាននាក់នៅទីក្រុងភ្នំពេញ និងនៅតាមទីរួមខេត្ត។

អង្គប្រជុំបានក្តាប់បាននូវសភាពការណ៍ស្រូវអង្ករ ស្បៀងអាហារនៅទីក្រុងភ្នំពេញ និងនៅតាមខេត្តដែលបន លន់ នល់ កាន់កាប់បណ្តោះអាសន្នបានខ្លះៗ។ នៅទីក្រុងភ្នំពេញមានប្រជាជនប្រមាណជាងបីលាននាក់ ប្រជាជនប្រមាណជា៩០ភាគរយហូបមិនគ្រប់គ្រាន់ទេ។ ប្រជាជនមួយចំនួនទៀត ដាច់ពោះជាបណ្តើរៗទៅហើយ។ បន លន់ នល់ ពឹងផ្អែកទៅលើជំនួយស្បៀងបរទេស។ ជំនួយឯទៀតក៏ពុំមានគ្រប់គ្រាន់ដែរ។ មានដំណឹងថាមានប្រជាជនដាច់ពោះស្លាប់ពិសេសកូនក្មេងស្លាប់ច្រើន។

របៀបវារៈខទីប្រាំ អង្គប្រជុំបានពិនិត្យឃើញថា នៅក្នុងតំបន់រំដោះយើង និងនៅតាមសហករណ៍យើងមានការលំបាកដែរ ព្រោះម្យ៉ាងការទម្លាក់គ្រប់បែករបស់សហរដ្ឋបានបំផ្លាញដីធ្លី ស្រែចម្ការ ផលដំណាំ ដែលអាចហូបធ្វើជាស្បៀងបានអស់មួយចំនួនសំខាន់។ សហករណ៍យើងខ្វះកម្លាំងពលកម្ម ព្រោះយុវជន យុវនារីទៅធ្វើកងទ័ពអស់ពីរភាគបី សល់តែកម្លាំងមនុស្សចាស់ដែលធ្វើពលកម្មបានមិនពេញលេញ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ជីវភាពរបស់ប្រជាជនយើងនៅរំដោះមានសភាពគ្រាន់បើជាងបងប្អូនប្រជាជនយើងនៅតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្ន។

[១៥:២៦:៣២]

របៀបវារៈខទីប្រាំមួយ អំពីការប៉ាន់ប្រមាណមុន អំពីសកម្មភាពបំផ្លាញរបស់ពួកក្បត់ក្នុងផ្ទៃក្នុងបក្ស ក្នុងសហករណ៍អង្គប្រជុំឯកភាពគ្នាថា បើប្រសិនជាយើងបានរំដោះភ្នំពេញមុនវៀតណាម រំដោះព្រៃនគរ វៀតណាមពិតជាបំផុសឲ្យពួកក្បត់ផ្ទៃក្នុងបក្ស និងក្នុងខណៈសហករណ៍ធ្វើសកម្មភាពបំផ្លាញ

ទាំងរូបភាពសម្ងាត់ រូបភាពចំហច្រើនបែបច្រើនយ៉ាង។ ព្រោះពួកវាពេលអស់បង្អែកសហរដ្ឋទៅហើយ វាពិតជាផ្អែកលើវៀតណាមហើយ។ បញ្ហានេះយើងត្រូវមានវិធានការអប់រំ អូសទាញ អំពាវនាវឲ្យពួកនេះបោះបង់ចោលសកម្មភាពក្បត់ ហើយត្រឡប់មកនៅជាមួយប្រជាជនឯងវិញ។ សេចក្តីអំពាវនាវត្រូវឆ្លុះបញ្ចាំងឲ្យឃើញនូវគោលជំហរមហាសាមគ្គីជាតិ ប្រជាជាន មហាសាមគ្គីក្នុងផ្ទៃក្នុងបក្សឲ្យច្បាស់ដើម្បីឲ្យអ្នកទាំងអស់ណាដែលបានភ័ន្តច្រឡំមានការទុកចិត្ត កត់ក្តៅចំពោះមាគ៌ានយោបាយរបស់បក្ស។

[១៥:២៨:១៣]

របៀបវារៈខទីប្រាំពីរ បើមិនទាន់ចាយលុយ តើមានផលល្អ ផលអាក្រក់យ៉ាងណា? ក្នុងរបៀបវារៈនេះ អង្គប្រជុំបានដកពិសោធថា លុយជាអាវុធសំខាន់ និងមានប្រសិទ្ធភាពណាស់របស់ខ្មាំង ហើយតាមពិសោធន៍កន្លងមកកាលដែលយើងមិនចាយលុយនៅក្នុងតំបន់រំដោះរបស់យើង ធ្វើឲ្យយើងរក្សាការពារបានតំបន់រំដោះដ៏ធំទូលំទូលាយ។ ខ្មាំងមិនអាចវាយដណ្តើមយកតំបន់រំដោះពីយើងបានវិញទេ។ ផ្ទុយទៅវិញយើងកាន់តែពង្រីកតំបន់រំដោះយើងបានកាន់តែធំទូលាយ។ ពួកចារកម្មមិនអាចប្រើលុយមកទិញកម្មាភិបាល ទិញកងទ័ពយើងបានទេ។ តំបន់ល្ហបកាន់តែពង្រីក និងប្រែក្លាយជាតំបន់រំដោះច្រើនឡើង។ តំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្នកាន់តែរួមក្តោប។ ការមិនប្រើយុទ្ធវិធីមិនទាន់ចាយលុយ វាប៉ះពាល់ដល់ប្រជាជនអ្នកមានលុយចំនួនតិច ឯប្រជាជនកសិករទូទៅ ជាពិសេសកសិករក្រមិនមានប៉ះពាល់អ្វីទេ។ ដោយមានមូលហេតុទាំងប៉ុន្មានដូចពោលមកពីខាងលើយ៉ាងនេះ អង្គប្រជុំបានធ្វើសេចក្តីសម្រេចចិត្តជាឯកច្ឆន្ទថា៖

១)ក្នុងករណីដែលទីក្រុងភ្នំពេញបានរំដោះ យើងត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្ន ដើម្បីតាមដានពិនិត្យសភាពការណ៍មួយរយៈសិន ជាពិសេសពិនិត្យអំពីសកម្មភាពជាក់ស្តែងរបស់វៀតណាម។

២)ផ្អាកចាយលុយបណ្តោះអាសន្នសិន ចាំពិនិត្យមើលសភាពការណ៍បង្កបង្កើនផល តើដំណើរទៅយ៉ាងណា? ទាល់តែការបង្កបង្កើនផលពិសេសបញ្ហាធ្វើស្រែបានទទួលផលល្អ ទើបមានមូលដ្ឋានរឹងមាំក្នុងការធានាដល់តម្លៃលុយរបស់យើង។

៣)គ្រប់បញ្ហាទាំងអស់ក្នុងរបៀបវារៈត្រូវពន្យល់អប់រំ បើកវគ្គរៀនសូត្រ នៅក្នុងបក្ស ក្នុងសហករណ៍ ក្នុងប្រជាជនឲ្យបានហ្មត់ចត់ ពិសេសបញ្ហាសាមគ្គីភាពរវាងប្រជាជនក្នុងមូលដ្ឋានចាស់

និងប្រជាជនដែលជម្លៀសមកថ្មី ត្រូវជួយឧបត្ថម្ភគ្នា ត្រូវចែកគ្នាហូបចុកដាច់ខាត កុំឲ្យមានការបែកចែកជាអ្នកចាស់អ្នកថ្មីឲ្យសោះ។

[១៥:៣១:១៦]

កម្មាភិបាលដឹកនាំ ពិសេសថ្នាក់ភាគ ថ្នាក់ស្រុក ត្រូវចុះតាមសហករណ៍ តាមឃុំភូមិដើម្បីណែនាំផ្ទាល់។ បញ្ហាចុងក្រោយ គឺបញ្ហាផ្សេង។ អង្គប្រជុំបានមានមតិឲ្យសមាជិកមជ្ឈិមបក្សដែលបានមកចូលរួមប្រជុំទៅពិភាក្សាជាមួយគណៈភាគ គណៈតំបន់ គណៈស្រុក ក្រោមការដឹកនាំរបស់ខ្លួនឲ្យបានច្បាស់លាស់ថា តើភូមិភាគណាមានលទ្ធភាពទទួលយកប្រជាជន អ្នកជម្លៀសប៉ុន្មាននាក់? តើសហករណ៍មួយក្នុងក្របខ័ណ្ឌដែលខ្លួនទទួលខុសត្រូវអាចទទួលយកអ្នកជម្លៀសក្នុងមួយសហករណ៍បានប៉ុន្មាននាក់? តាំងពីពេលនេះទៅត្រូវខំពង្រឹងសហករណ៍ និងពង្រីកសហករណ៍ឲ្យជំរុញការដាំដុះពិសេសពង្រីកស្រែចម្ការ ដំណាំស្បៀងអាហារឲ្យបានច្រើនថែមទៀត។ អង្គប្រជុំបានពិនិត្យឃើញថាយើងពិតជាត្រូវឆ្លងកាត់ការលំបាកមួយរយៈ ពិសេសការខ្វះស្បៀង ខ្វះថ្នាំសង្កូវ បញ្ហាសុខភាពរបស់ប្រជាជន អ្នកមកថ្មី ព្រោះគេមិនធ្លាប់រស់នៅតាមជនបទ។

[១៥:៣២:៥២]

ឃើញការលំបាកមុនយ៉ាងនេះ ដើម្បីបក្សគ្រប់ថ្នាក់ កម្មាភិបាលគ្រប់ថ្នាក់ កងទ័ពគ្រប់អង្គភាពយកចិត្តទុកដាក់ជាអតិបរមា រួមសាមគ្គីគ្នាដោះស្រាយគ្រប់ការលំបាកឲ្យបាន។

សន្និដ្ឋាន៖ចំពោះអ្វីទាំងប៉ុន្មានដែលបានចោទនោះសុទ្ធតែជារឿងមិនពិត គោលជំហរតស៊ូរបស់ខ្ញុំក្នុងបដិវត្តន៍ គឺដូចបានរៀបរាប់មកជាហូរហែនេះ គឺដើម្បីផលប្រយោជន៍ជាតិនិងប្រជាជនជាធំ។

ខ្ញុំសូមជម្រាបថា ការរស់នៅក្រោមការគាបសង្កត់ និងឃើញភាពអយុត្តិធម៌សង្គមគ្រប់បែបយ៉ាងបានជំរុញឲ្យខ្ញុំផុសចេញនូវគំនិតលះបង់គ្រួសារដើម្បីទៅតស៊ូរំដោះជាតិមាតុភូមិពីនឹមអាណានិគម គឺការឈ្លានពានគាបសង្កត់ពីពួកចោរបរទេសលួចទឹកដី ចង់លុបបំបាត់ព្រះពុទ្ធសាសនា និងពូជសាសន៍ខ្មែរ។

[១៥:៣៤:០៦]

មាគ៌ានយោបាយរបស់កុម្មុយនីស្តកម្ពុជា គឺដើម្បីរំដោះប្រទេសជាតិពីខ្ញុំកញ្ជះបរទេស និងកសាងសង្គមមួយដែលស្អាតស្អំ ឯករាជ្យ គឺមិនមែនកាប់សម្លាប់ ប្រល័យពូជសាសន៍ស្អីនោះទេ។ ខ្ញុំគិតថា នេះជាសេចក្ដីថ្លែងការណ៍ និងការបកស្រាយបំភ្លឺជារួមមួយចំណែកទេ ហើយនិងសូមធ្វើសេចក្ដីថ្លែងការណ៍

ផ្សេងៗទៀត ដើម្បីឆ្លើយតបទៅតាមដំណាក់កាលដែលរៀបចំដោយតុលាការនេះ។

ជាទីបញ្ចប់ ខ្ញុំសូមបញ្ជាក់ថាប្រជាជនកម្ពុជាជាប្រជាជនស្នេហាសន្តិភាព ស្នេហាឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដីរបស់ខ្លួន។ប្រជាជនកម្ពុជាចង់មានចំណងមិត្តភាពជាមួយគ្រប់ប្រទេសទាំងអស់ដោយឈរលើមូលដ្ឋានឯករាជ្យ ស្មើភាពគ្នាទៅវិញទៅមក មានផលប្រយោជន៍ទាំងសងខាង។ ចំពោះវៀតណាម ប្រជាជនកម្ពុជាធ្វើសំណូមពរឲ្យវៀតណាមលះបង់ចោលគំនិតវៀមច្បង ហើយរស់នៅដោយសុខសន្តិភាពជាមួយគ្នាជាយូរអង្វែង។ ឯប្រជាជនកម្ពុជាយើងវិញក៏ត្រូវលះបង់ចោលគំនិតគុំកួនស្អប់វៀតណាមរឿងកំពប់តែអុង វាកន្លងផុតទៅហើយ។ ប្រទេសនីមួយៗអភិវឌ្ឍប្រទេសជាតិខ្លួនតាមមាគ៌ានយោបាយតែរៀងៗខ្លួន សម្រេចវាសនាជាតិខ្លួនឯង អ្វីដែលជួយឧបត្ថម្ភគ្នាបានក៏ជួយគ្នាក្នុងឋានៈជាមនុស្សជាតិរស់នៅជិតគ្នាដោយស្ងប់សុខ សន្តិភាព និងគោរពគ្នាទៅវិញទៅមក។

សូមគោរពលោកប្រធាន។

[១៥:៣៦:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណ លោក នួន ជា អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅកាន់កៅអីនៅពីក្រោយមេធាវីរបស់គាត់ចុះ។ ឥឡូវនេះនៅមានពេលមួយចំនួន អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី នួន ជា ដើម្បីមានលទ្ធភាពអាចធ្វើ ឡើងធ្វើសេចក្តីសន្និដ្ឋានតប។

**លោក ម៉ៃខល ផេសមិន៖**

នៅពេលរសៀលនេះ នៅពេលដែលខ្ញុំសូមឲ្យអង្គជំនុំជម្រះ-- សម្រាប់ចម្លើយតបរបស់យើងគឺខ្ញុំបានទទួលឯកសារមួយដែលថា ក្រុមខ្ញុំត្រូវនិយាយនៅថ្ងៃពុធ ប៉ុន្តែមិនត្រូវនិយាយថ្ងៃនេះទេ ប៉ុន្តែត្រូវលើកឡើងនៅថ្ងៃស្អែក ខ្ញុំសូមបង្ហាញនូវឯកសារD131 ដែលសហព្រះរាជអាជ្ញា ដែលបាន សហព្រះរាជអាជ្ញាបានទទួលទៅដល់ពីរថ្ងៃ ហើយមេធាវីការពារក្តីបានទទួលតែកន្លះថ្ងៃទេសម្រាប់ក្រុមនីមួយៗ។ ដូច្នេះ បើយោងទៅតាមពេលវេលាដែលបានកំណត់នៅថ្ងៃទី១៥ តុលា ហើយសេក្តីសម្រេចនេះគឺត្រូវបានគេហទំព័រនៅក្នុងដីកាសម្រេចនោះ។ ខ្ញុំសូមដកស្រង់សម្តី៖ “អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក គឺនឹងបើកសវនាការប្រឆាំងនឹង ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ដែលមានកំណត់កាលបរិច្ឆេទនៅថ្ងៃច័ន្ទ សម្រាប់ការបើកសេចក្តីផ្តើមចោទប្រកាន់ និងថ្ងៃអង្គារ គឺថ្ងៃនេះឯងសម្រាប់សហព្រះរាជអាជ្ញា ហើយនិងបន្តទៅថ្ងៃពុធសម្រាប់ចម្លើយតបបើករបស់មេធាវីការពារក្តី។ ហើយប្រហាក់

ប្រហែលនឹងគ្នានេះដែរ ហើយកម្មវិធីនេះក៏ត្រូវបានផ្សព្វផ្សាយនៅខែវិច្ឆិកា នៅលើគេហទំព័រ ខ្ញុំដីកាសម្រេចនេះនៅក្នុងដៃ។

[១៥:៣៩:៤១]

ខ្ញុំមានដីកាសម្រេចនេះទាំងជាភាសាខ្មែរនិងភាសាអង់គ្លេស។ អ៊ីចឹងយោងទៅតាមឯកសារដីកាសម្រេចនេះគឺយើងខ្ញុំត្រូវធ្វើបទបង្ហាញនេះនៅថ្ងៃស្អែក មិនមែនតែយើងខ្ញុំជឿជាក់ថា ត្រូវនិយាយនៅថ្ងៃស្អែកនោះទេ ក៏ប៉ុន្តែសាធារណជនគាត់ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយ គឺអ្នកដែលនៅខាងក្រៅតុលាការនេះជឿជាក់ថា ជឿជាក់ដោយមានហេតុថា គឺយើងខ្ញុំត្រូវធ្វើបទបង្ហាញនេះនៅថ្ងៃស្អែក។ អ៊ីចឹង ខ្ញុំចង់ផ្តល់ឱកាសអ្នកដែលត្រូវមកថ្ងៃស្អែកនេះ គឺថាមកស្តាប់សេចក្តីថ្លែងបើករបស់ក្រុមយើងខ្ញុំ។

អ៊ីចឹង យើងខ្ញុំសុំស្នើទៅដល់អង្គជំនុំជម្រះដើម្បីឲ្យខ្ញុំធ្វើការបង្ហាញនៅថ្ងៃស្អែកវិញ។

[១៥:៤១:០២]

**ប្រធានអង្គជំនុំ៖**

គួរឲ្យស្តាយដែរ ដោយសារមេធាវីបានលើកឡើងនូវអំណះអំណាងថាខ្លួនមិនមានលទ្ធភាពក្នុងការធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅរសៀលនេះទេ ប៉ុន្តែផ្ទុយទៅវិញ ជនជាប់ចោទ នួន ជា ផ្ទាល់ខ្លួនរបស់គាត់បែរជាមានលទ្ធភាព និងមានសមត្ថភាពអាចរៀបចំនូវសេចក្តីសន្និដ្ឋានឆ្លើយតបបានសមរម្យ សមល្មមទៅនឹងពាក្យថា "សេចក្តីសន្និដ្ឋានតបដោយសង្ខេប ទៅនឹងសេចក្តីសន្និដ្ឋានសង្ខេប ចោទប្រកាន់ដោយសង្ខេបរបស់សហព្រះរាជអាជ្ញា"។ ហើយអង្គជំនុំជម្រះបានផ្តល់ពេលវេលាហើយៗដោយសារមេធាវីមិនប្រើ នោះជារឿងរបស់គាត់។

ឥឡូវដើម្បីកុំឲ្យខាងពេល ហើយដោយពីថ្ងៃមុនយើងបានលើកបញ្ហាមួយទុកមួយអន្លើ គឺការទទួលស្គាល់មេធាវីបរទេស មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ។ ឥឡូវនេះសួរទៅលោកមេធាវី សហមេធាវីជាតិនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីថា តើមេធាវីដែលមិនទាន់បានទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះហ្នឹងមានវត្តមានដែរទៀតទេនៅពេលនេះ?

[១៥:៤២:៥៤]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោកមេធាវីបរទេសទាំងបីរូបនោះមានវត្តមាននៅទីនេះ ហើយប្រសិនបើលោកប្រធានអនុញ្ញាត យើងខ្ញុំអាចស្នើសុំនៅពេលនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ឥឡូវនេះគឺយើង ជាការបំពេញកិច្ចនីតិវិធីទទួលស្គាល់មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយកាលពីថ្ងៃដំបូងនោះយើងមានការរអាក់រអួលផ្នែកខាងបច្ចេកទេស ប្រព័ន្ធសំឡេង ហើយបានលើករបៀបវារៈនេះទុកមួយអន្លើ តែឥឡូវនេះយើងមានពេលសមស្របក្នុងការធ្វើដូច្នេះ ដោយអនុលោមតាមវិធាន២២(២) ចំណុច(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ជាសហមេធាវីជាតិនៃមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើងស្នើសុំការទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមាននៅទីនេះ ហើយដែលគាត់មិនទាន់បានទទួលស្គាល់ពេលអង្គជំនុំជម្រះសាលាដំបូងពីកន្លងមក។

សូមអញ្ជើញលោក ពេជ អង្គ!

[១៥:៤៣:៥៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រមសាជាថ្មី សូមគោរពអស់លោកជំទាវ ព្រះរាជអាជ្ញា លោកព្រះរាជអាជ្ញា អស់លោក លោកស្រី ដែលជាសហភាតាដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសាធារណជន។ ថ្ងៃនេះ មានវត្តមានមេធាវីអន្តរជាតិ ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប ហើយដែលលោកមេធាវីទាំងបីនេះ បានស្បថរួចហើយនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ ហើយដែលថ្ងៃនេះខ្ញុំបាទសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់មេធាវីទាំងអស់នោះ ដើម្បីឲ្យមានសិទ្ធិជាមេធាវីពេញសិទ្ធិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។

មេធាវីអន្តរជាតិទាំងបីរូបនោះ រួមមានលោក បាណាបេ ណោគ្វី ជាមេធាវីអន្តរជាតិ ដែលមានសញ្ជាតិកាម៉ារូន ដែលលោកជាសមាជិកក្រុមមេធាវីផងដែរ នៃក្រុមមេធាវីឥតព្រំដែនបារាំង ហើយដែលនៅក្នុងពេលនេះ គឺលោកនៅក្នុងអន្តរាគមន៍ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌជាមេធាវីអន្តរជាតិខាងមេធាវីគ្មានព្រំដែនបារាំង។

[១៥:៤៥:៣២]

មេធាវីទីពីរ គឺលោក មេធាវី ប៉ាទ្រីក បូឌូន ជាសហមេធាវីអន្តរជាតិ ដែលមានសញ្ជាតិបារាំង មកពីសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ នៃប្រទេសបារាំង *ហ្វេីឌែរ៉ាស្យុង អាំងទែណាស្យូណាល់ ប៊ឺទ័រ ឌឺឡូម* (ភាសាបារាំង) ហើយមេធាវីទីបី គឺលោកស្រី ម៉ារី ហ្គីរ៉ូដ ជាសហមេធាវីអន្តរជាតិដូចគ្នាផងដែរ ដែល

មានសញ្ជាតិបារាំង និងមកពីសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិប្រទេសបារាំងផងដែរ។

ក្នុងនាមជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើដោយគោរព ជូនអង្គជំនុំជម្រះទទួលស្គាល់សហមេធាវីអន្តរជាតិទាំងបីរូបនេះ ដែលត្រូវបានណែនាំនេះ ដើម្បីឱ្យលោកមេធាវីទាំងបីរូបមានគុណភាពជាមេធាវីពេញសិទ្ធិនៅក្នុងការការពារកូនក្តីរបស់លោក ជាមួយនឹងមេធាវីនាំមុខចាប់ពីពេលនេះតទៅ។ សូមអរគុណ។

[១៥:៤៦:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ពេជ អង្គ។

លោក បាណាបេ ណេគ្វី លោក ប៉ាទ្រីក បូឌួន លោកស្រី ម៉ារី ហ្គីរ៉ូដ លោក លោកស្រីត្រូវបានអង្គជម្រះសាលាដំបូងទទួលស្គាល់ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ។ ហើយអនុលោមតាមការទទួលស្គាល់នេះ លោក លោកស្រីមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែរ។

សូមអញ្ជើញលោក អាង ឧត្តម។ សូមអញ្ជើញលោកមេធាវី!

[១៥:៤៧:២៥]

**លោក អាង ឧត្តម៖**

ជាបឋម ខ្ញុំសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមសមាជិក។ សូមគោរពអង្គសវនាការ ហើយសូមក្រាបថ្វាយបង្គំព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ ដែលមានព្រះរាជវត្តមាននៅទីនេះផង។ ដោយសារតែពេលវេលានៅសល់ ហើយដើម្បីសង្គ្រោះពេលវេលាកុំឱ្យសាលាក្តីខាតពេលវេលាច្រើនផង ខ្ញុំបាទសុំឆ្លៀតយកឱកាសនេះដើម្បីបន្តកិច្ចការរបស់យើងខ្ញុំដែលនឹងធ្វើបន្ទាប់។

សូមលោកប្រធានមេត្តាអនុញ្ញាត។

[១៥:៤៨:១៣]

ទាក់ទងនឹងបទបង្ហាញលើការបើកក្តី លើសំណុំរឿងចោទប្រកាន់លោក អៀង សារី នៅក្នុងដំណើរការនីតិវិធីនេះ សហមេធាវីលោក អៀង សារី គឺលោក ម៉ៃខល កាណាវាស និងខ្ញុំបាទ នឹងមិនធ្វើសេចក្តីថ្លែង ឬក៏ការកត់សម្គាល់ ឬក៏ធ្វើបទបង្ហាញទាក់ទងនឹងការបើកក្តីនេះ ដូចដែលសហព្រះរាជ

អាជ្ញាបានធ្វើ និងក្នុងការឆ្លើយតបនឹងសហព្រះរាជអាជ្ញានោះទេ។

សូមជម្រាបថា សេចក្ដីថ្លែងបើកក្ដីមិនមែនជាភស្តុតាងទេ យើងខ្ញុំសហមេធាវីរបស់ អៀង សារី សង្ឃឹម ហើយជឿថាតុលាការមិនពឹងផ្អែក មិនជឿ មិនអាស្រ័យទៅលើទឡ្ហីករណ៍ទាំងឡាយដែលសហព្រះរាជអាជ្ញាបានលើកក្នុងអំឡុងពេលពីរថ្ងៃនេះទេ។ អង្គហេតុដែលថា យើងខ្ញុំសម្រេចមិនធ្វើសេចក្ដីថ្លែងបើកក្ដីរបស់យើងខ្ញុំនៅក្នុងដំណើរការនីតិវិធីនេះ មិនមានន័យថា យើងខ្ញុំយល់ស្រប ឬក៏យល់ព្រមទៅលើទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលបានលើកកន្លងនេះទេ។ នេះជាការកត់សម្គាល់ទីមួយ។ បន្ថែមទឡ្ហីករណ៍នៅក្នុង*អូធិននឹងស្មោគមិន* នៅក្នុងសេចក្ដីថ្លែងបើកក្ដីរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេលពីរថ្ងៃនេះ។ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ជាច្រើន ក៏ប៉ុន្តែសំអាងហេតុទាំងឡាយអត់ត្រូវបានបង្ហាញឱ្យយើងដឹង។ យើងដឹងហើយថា វិធានការការពារសាក្សីមិនតម្រូវឱ្យនិយាយឈ្មោះសាក្សីទេ ប៉ុន្តែអាចលើកយកឈ្មោះជារហស្សនាម ឬជាលេខសម្ងាត់មកអះអាងបាន។ យើងអត់ដឹងថាឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញាដែលលើកមកនោះ វាយ៉ាងម៉េចទេ។ ដូច្នេះ នៅថ្ងៃទី២១ ម្សិលមិញនេះ យើងបានធ្វើលិខិតសួរទៅសហព្រះរាជអាជ្ញាដោយផ្ទាល់ឱ្យសហព្រះរាជអាជ្ញាប្រាប់មកយើងថា ឯកសារណា សាក្សីណា សំអាងហេតុណា ដែលលោកបានប្រើនៅអំឡុងពេលធ្វើសេចក្ដីថ្លែងបើកក្ដីរបស់អស់លោក។

[១៥:៥១:៤៦]

នៅថ្ងៃនេះ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅក្នុងអនុស្សរណៈមួយមកដល់ក្រុមមេធាវីរបស់លោក អៀង សារី ថាឯកសារទាំងអស់នោះវាសុទ្ធតែនៅក្នុងសំណុំរឿង ហើយលោកប្រាកដថាឯកសារទាំងអស់នោះ នឹងមានពាក់ព័ន្ធនៅក្នុងសំណុំរឿង។ អ៊ីចឹង យើងជឿថាឯកសារទាំងអស់នោះនៅក្នុងដៃរបស់សហព្រះរាជអាជ្ញារួចទៅហើយ គួរតែឱ្យយើងដឹង យ៉ាងណាវិញ សហព្រះរាជអាជ្ញាតម្រូវ ឬណែនាំឱ្យយើងឆែកមើលនៅក្នុងសំណុំរឿង ដែលយើងគ្មានកាតព្វកិច្ចក្នុងការឆែករកគ្រប់សំណុំរឿងឯកសារដ៏ច្រើនគរគោកនេះបានឡើយ។

[១៥:៥២:៥៣]

ម្យ៉ាងវិញទៀត យើងអត់ជឿ អត់ដឹងថា ឯកសារភស្តុតាង សាក្សី ដែលព្រះរាជអាជ្ញាបានលើកមកសំអាងហេតុនេះ ត្រូវបានទទួលស្គាល់ហើយឬនៅ ក៏យើងអត់បានដឹងដែរ។ អ៊ីចឹង សូមតុលាការមេត្តាចាត់ការ ឬបង្គាប់បញ្ជាឱ្យបង្ហាញឯកសារដែលព្រះរាជអាជ្ញា បានប្រើក្នុងការយោងទៅក្នុងសេចក្ដី

ថ្លែងការណ៍បើកក្តីរបស់ព្រះរាជអាជ្ញា ពីព្រោះថា មិនសុទ្ធតែឯកសារទាំងអស់នៅក្នុងសំណុំរឿងហ្នឹងត្រូវបានទទួលស្គាល់នៅឡើយនោះទេ។ ហើយសហមេធាវីក៏គ្មានកាតព្វកិច្ច ដូចខ្ញុំបានជម្រាបរួចហើយថា ទៅស្រាវជ្រាវរកព័ត៌មានទាំងអស់នោះ។ ព័ត៌មានទាំងនេះ បើសិនជាព្រះរាជអាជ្ញាឲ្យយើងដឹងគឺវាងាយស្រួលជួយសម្រួលការងារយើងទាំងអស់គ្នា ជាពិសេសការងាររបស់មេធាវីផង។

[១៥:៥៤:២៣]

ដូចដែលមេធាវីបានធ្លាប់បានធ្វើកិច្ចសហការខ្លះៗដល់សហព្រះរាជអាជ្ញាដែរ។ អ៊ីចឹង កំណត់សម្គាល់របស់យើងខ្ញុំមានតែប៉ុណ្ណឹង គឺសូមរំឭកឡើងវិញថា យើងខ្ញុំមិនធ្វើសេចក្តីថ្លែងបើកក្តីនៅក្នុងនីតិវិធីនេះទេ មួយ។ ទីពីរ សុំឲ្យព្រះរាជអាជ្ញាបញ្ចេញឯកសារសាក្សីដែលលោកបានប្រើក្នុងការយោងទៅលើទឡ្ហីករណ៍ដែលបានប្រើក្នុងពេលបើកក្តីនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការបង្ហាញនូវជំហររបស់ខ្លួន នៅក្នុងការមិនអនុវត្តនូវសិទ្ធិក្នុងការធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់ដោយសង្ខេបដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ដែលវាមិនខុសអ្វីទៅនឹងបទប្បញ្ញត្តិដែលចែងនៅក្នុងវិធាន៨៩ ស្ទួន អនុវិធាន២ ទេ ពីព្រោះនៅក្នុងវិធាន៨៩ ស្ទួន អនុវិធាន២ បានចែងជាក់លាក់អំពីថា ជនជាប់ចោទ មេធាវីរបស់ជនជាប់ចោទ អាចធ្វើការតបដោយសង្ខេបបាន ក្នុងន័យនេះ ការបកស្រាយគឺមានន័យថា មិនធ្វើក៏បានដែរ។ ឥឡូវនេះ គឺច្បាស់លាស់ហើយថាមេធាវីរបស់លោក អៀង សារី មិនធ្វើ ប៉ុន្តែឥឡូវនេះដើម្បីឲ្យច្បាស់លាស់ពីព្រោះងាយក្នុងការអង្គជំនុំជម្រះរៀបចំនូវកាលវិភាគសម្រាប់ស្អែក។ ហើយចុះជនជាប់ចោទ អៀង សារី តើលោកមានត្រូវការធ្វើការ និយាយ ឬឆ្លើយតបទៅនឹងការចោទប្រកាន់ដែរឬទេ?

[១៥:៥៦:៣៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! ទាំងលោក អៀង សារី ក៏មិនធ្វើសេចក្តីថ្លែងការណ៍បើកក្តីនេះដែរ ក៏ប៉ុន្តែគាត់នៅតែមានចេតនាចង់ទទួលការអនុញ្ញាតពីលោកប្រធាន ដើម្បីគាត់បានអានសេចក្តីប្រកាសរបស់គាត់ដែលគាត់មានបំណងយ៉ាងមុតមាំក្នុងការអានសេចក្តីប្រកាសនេះតាំងពីថ្ងៃដំបូងនៅព្រឹកដំបូង ប៉ុន្តែត្រូវបានតុលាការរារាំងនិងហាមឃាត់។ អ៊ីចឹង ខ្ញុំសូមលោកប្រធាន អនុញ្ញាតឲ្យមានការអានសេចក្តីប្រកាសរបស់លោក អៀង សារី ឬនៅពេលនេះ ឬនៅព្រឹកស្អែក ជាជំនួសសេចក្តីថ្លែងការណ៍បើកក្តី

របស់គាត់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោកមេធាវីដែលបានបញ្ជាក់ច្បាស់លាស់លើបញ្ហានេះ ហើយអង្គជំនុំជម្រះសូមជម្រាបថា មូលហេតុដែលអង្គជំនុំជម្រះមិនអនុញ្ញាតពីព្រោះ អង្គជំនុំជម្រះគ្រប់គ្រងនៅក្នុងកិច្ចដំណើរការសវនាការសំណុំរឿងក្តីដ៏ធំធេងរបៀបនេះ ត្រូវតែគ្រប់គ្រងជាក់លាក់នូវរបៀបវារៈដែលបានកំណត់ ហើយពេលវេលា សម្រាប់ អៀង សារី គឺពេលវេលានេះ បានន័យថា បន្ទាប់ពីពេលវេលាដែលបានប្រគល់ទៅឱ្យមេធាវី ក្រុមមេធាវីការពារក្តី នួន ជា និង នួន ជា ចប់ គឺជាក្រុមរបស់មេធាវី អៀង សារី នេះយើងបានកំណត់ច្បាស់លាស់ក្នុងការណែនាំ ចង់ធ្វើ ចង់ថ្លែងការណ៍យ៉ាងម៉េចនោះជារឿងរបស់គាត់។ ប៉ុន្តែឥឡូវនេះដើម្បីឱ្យ-- ដោយសារមានពេលវេលាវាហាក់ដូចជាយឺតដែលហើយ ក្រែងលោមានការថ្លែងការណ៍ច្រើន អ៊ីចឹងអង្គជំនុំជម្រះសម្រេចថា ទុកលទ្ធភាពឱ្យគាត់ធ្វើនៅថ្ងៃស្អែកនៅពេលដែលចាប់ផ្តើមកិច្ចដំណើរការនៃសវនាការដំបូងតែម្តង។ ហើយជាបន្តនេះដោយសារ លោកស្រីចៅក្រមមានបំណងចង់បញ្ជាក់អ្វីម្យ៉ាងនៅក្នុងទីនេះ ដើម្បីច្បាស់។ សូមអញ្ជើញលោកស្រីចៅក្រម។

[១៥:៥៨:៥៧]

**លោក អាង ឧត្តម៖**

សូមកាត់ប្រសាសន៍ទាន! សេចក្តីថ្លែងការណ៍របស់លោក អៀង សារី មានយ៉ាងតិចប្រហែលជាបីនាទី ឬក៏ក្រដាសប្រហែលជាមួយទំព័រកន្លះទេ បើអានប្រហែលជាពីរនាទីអីប៉ុណ្ណឹងទេ។ បើសិនលោកប្រធានអនុញ្ញាត ខ្ញុំអាចអានជូនលោក អៀង សារី នៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បានហើយ យើងបានសម្រេចរួចហើយអំមិញណ៎ា។ អ៊ីចឹង ថាមិនកែប្រែទេ យើងសម្រេចឱ្យគាត់ត្រូវធ្វើនៅថ្ងៃស្អែក។ សូមអញ្ជើញលោកស្រីចៅក្រម ខាតរាយច៍ ដើម្បីបំភ្លឺបញ្ជាក់បន្ថែមចំពោះក្រុមមេធាវី នួន ជា។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន យើងបានដឹងច្បាស់ ហើយយើងក៏គិតឃើញថា ភាសាអង់គ្លេសដែលបានបកប្រែមកនេះ គឺមតិរបស់លោកប្រធានទាក់ទងនឹងមេធាវីការពាររបស់ នួន ជា នឹងឆ្លើយតបរបស់គាត់នៅថ្ងៃស្អែកព្រឹក។ ប៉ុន្តែខ្ញុំយល់អាចច្បាស់អាចច្បាស់ជាងមុន ខ្ញុំចង់បំភ្លឺថា អង្គជំនុំជម្រះ

សាលាដំបូងបានសម្រេចថា ហើយបានយល់ឃើញថា មេធាវីការពារ នួន ជា មិនឆ្លើយទៅនឹងការសន្និដ្ឋានបើកការចោទប្រកាន់នោះទេ ហើយថ្ងៃស្អែកអង្គជំនុំជម្រះសាលាដំបូងនឹងបន្តទៅសេចក្តីថ្លែងការណ៍របស់ អៀង សារី ហើយនិងការឆ្លើយតបរបស់លោក ខៀវ សំផន បើភាគីទាំងពីរនោះបានធ្វើដូច្នោះ។ ប្រសិនជាក្រុមមេធាវីការពារ នួន ជា មិនមាននិយាយនឹងលើកទេ គឺថានៅពេលនោះ បើសិនលោកចង់ គឺថា អាចនឹងបញ្ជាក់នៅពេលនេះ បើមិនអ៊ីចឹងទេនឹងបាត់ឱកាសនៅក្នុងពេលក្រោយ។

[១៦:០១:០២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយខ្លីទៅនឹងមតិរបស់លោកស្រីចៅក្រមនេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

នេះមិនមែនសេចក្តីសង្កេតទេ ជាសេចក្តីសម្រេចពីចៅក្រម។

**ប្រធានអង្គជំនុំ៖**

ឃើញថា ពេលវេលាសមល្មមនឹងត្រូវសម្រាកហើយ សម្រាប់សវនាការថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅថ្ងៃស្អែក ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សូមភាគី និងសាធារណជនជ្រាប និងចូលរួមសវនាការ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់។

សូមសម្រាក ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅមន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ ហើយឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*